ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរ
# ផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិ
# ក្នុងខេត្តតាកែវ

# The Situation of Teaching and Learning Khmer Language in Reading Skill at Lower-Secondary Schools in Takeo Province


ដោយ/ by

**នូ សុខលៀប**

NOU SOKLEAP


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧

ឯកទេស ៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៨-២០២០

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរ ផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តតាកែវ

## The Situation of Teaching and Learning Khmer Language in Reading Skill at Lower-Secondary Schools in Takeo Province

ដោយ/ by

**នូ សុខលៀប**

NOU SOKLEAP

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧**

**ឯកទេស ៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៨-២០២០**

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៥៣០/៧ អយក.ឧទ

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។
-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នូវ រ៉ៃ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ិន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចាប តេនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន រ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នូ ចន្នី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ច័ន្ទ ៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២០
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

កន្លែងទទួល៖
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ វជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

# សេចក្ដីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើង «**ស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តតាកែវ**» សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧នៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះ ពុំមានខ្លឹមសារដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះ ពិតជាត្រូវបានស្រាវជ្រាវ និងចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន

ថ្ងៃ......................ខែ...............ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី .......ខែ.............ឆ្នាំ ២០២០

**ហត្ថលេខាបេក្ខជន**

**នូ សុខលៀប**

# លិខិតបញ្ជាក់

លោកស្រី **នូ ចន្ធី** គ្រូដឹកនាំបង្គោល

លោកបណ្ឌិត **អាន វ៉ូប្រាថ** គ្រូដឹកនាំរង

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោក **នូ សុខលៀប** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ « **ស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ** » ពិតប្រាកដមែន។

ថ្ងៃ..........................ខែ...............ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី .......ខែ.............ឆ្នាំ ២០២០

…………………….　　　　……………………………..

**លោកស្រី នូ ចន្ធី**　　　　**លោកបណ្ឌិត អាន វ៉ូប្រាថ**

(គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ)　　　　( គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ)

# សេចក្តីថ្លែងអំណរគុណ

ស្នាដៃសិក្សាស្រាវជ្រាវដែលអាចសម្រេចជាលទ្ធផលនៅពេលនេះ គឺដោយសារការផ្តល់ទាំងកម្លាំងកាយ កម្លាំងបញ្ញា ការលើកទឹកចិត្ត និងផ្តល់ជាសម្ភារៈពីបណ្តាមនុស្សជាទីគោរពដ៏ខ្ពង់ខ្ពស់ និងស្រឡាញ់រាប់អានដ៏ស្មោះស្ម័គ្ររបស់ខ្ញុំ។

ខ្ញុំសូមសម្តែងនូវការដឹងគុណ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកឪពុកអ្នកម្តាយរបស់ខ្ញុំដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា ហើយតែងតែផ្តល់ជាកម្លាំងកាយចិត្ត និងថវិកាដល់ខ្ញុំសម្រាប់ផ្គត់ផ្គង់ការសិក្សារៀនសូត្រ ព្រមទាំងលោកសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូគ្រប់កម្រិតថ្នាក់ចាប់ពីបឋមសិក្សា រហូតដល់កម្រិតសាកលវិទ្យាល័យ ដ៏ខ្ពង់ខ្ពស់ជាទីគោរពស្រឡាញ់ទាំងអស់។ ជាពិសេសសូមគោរពដឹងគុណចំពោះ៖

ឯកឧត្តមបណ្ឌិត **ម៉ុក សារ៉ុម** និងឯកឧត្តម សាស្ត្រាចារ្យ លោក លោកស្រី ជាថ្នាក់ដឹកនាំនៃវិទ្យាស្ថានជាតិអប់រំ(NIE) ដែលបានផ្តល់ជាចំណេះដឹង និងបទពិសោធន៍ល្អៗដល់ខ្ញុំសម្រាប់ជាទុនក៏ដូចជាផ្តល់ឱកាសក្នុងការសិក្សាស្រាវជ្រាវក្រេងស្នាដៃនេះឡើង។

លោកស្រី **នូ ចន្នី** ជាគ្រូដឹកនាំបង្គោល និងលោកបណ្ឌិត **អាន វ៉ូប្រាថ** ជាគ្រូដឹកនាំរង ដែលបានផ្តល់ជាឯកសារ និងបានជួយបង្ហាត់បង្ហាញត្រួសត្រាយផ្លូវ និងលើកទឹកចិត្តដល់ខ្ញុំបាទក្នុងការស្រាវជ្រាវចងក្រងស្នាដៃនេះឡើង។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលបានខិតខំអភិវឌ្ឍសង្គមជាតិ រក្សានូវស្ថេរភាពនយោបាយ សន្តិសុខសង្គម ក្នុងនោះដែរវិស័យអប់រំកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស នាំឱ្យពួកយើងទទួលបានឱកាសស្មើៗគ្នាសម្រាប់ការសិក្សាអប់រំ។

ជាអវសាន ខ្ញុំបាទសូមគោរពជូនពរដល់លោកគ្រូ អ្នកគ្រូ បុគ្គលិក និស្សិតរួមជំនាន់ទាំងអស់លោកសាស្ត្រាចារ្យ គណៈគ្រប់គ្រង រាជរដ្ឋាភិបាល ជាពិសេសលោកអ្នកមានគុណ ឱ្យជួបប្រទះតែសេចក្តីសុខ និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងឈ្វេងយល់ពីដំណើរការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាន និងបញ្ហាប្រឈមដែលទាក់ទងនឹងបំណិននៃការអានរបស់សិស្សនៅសាលាមធ្យមសិក្សាបឋមភូមិខេត្តតាកែវ។

វិធីសាស្ត្រដែលអ្នកសិក្សាស្រាវជ្រាវយកមកប្រើដើម្បីប្រមូលទិន្នន័យនេះ គឺវិធីសាស្ត្របែបបរិមាណវិស័យ (Quantitative Method)។ ក្នុងការសិក្សាស្រាវជ្រាវបែបបរិមាណវិស័យ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់នូវកម្រងសំណួរបែបពហុជ្រើសរើសសម្រាប់សួរគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និងសិស្សានុសិស្ស។ ម្យ៉ាងទៀត អ្នកស្រាវជ្រាវចងក្រងជាកម្រងសំណួរបែបសំណួរបើកសម្រាប់សម្ភាសគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និងសិស្សានុសិស្សដើម្បីងាយទទួលបានព័ត៌មានបន្ថែមសម្រាប់គាំទ្រដល់ចម្លើយមួយចំនួននៅក្នុងកម្រងសំណួរបែបបរិមាណវិស័យ។ ភាគសំណាកដែលបានចូលរួមនៅក្នុងការស្រាវជ្រាវនេះ ត្រូវបានជ្រើសរើសចេញពីអនុវិទ្យាល័យចំនួនបី ក្នុងស្រុកសំរោង ខេត្តតាកែវ។ ភាគសំណាកទាំងអស់មានចំនួន២០៤នាក់ ដោយក្នុងនោះរួមមានគណៈគ្រប់គ្រងសាលារៀនចំនួន០៦នាក់ គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គមចំនួន១៨នាក់ និងសិស្សានុសិស្សថ្នាក់ទី៧ ទី៨ ទី៩ ចំនួន១៨០នាក់។

លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះបានបង្ហាញថា ការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ មានស្ថានភាពល្អប្រសើរ ដែលតម្លៃមធ្យមចង្អុលបង្ហាញកម្រិតជាវិជ្ជមាន ឬ (**តម្លៃមធ្យម=៣.៦២**) និងមានបញ្ហាប្រឈមខ្លះៗ។ សូចនាករនានាក្នុងការគាំទ្ររួមមាន ការអនុវត្តកម្មវិធីសិក្សា(**តម្លៃមធ្យម=៣.៨៤**) ការអនុវត្តវិធីសាស្ត្របង្រៀន(**តម្លៃមធ្យម=៣.៤៩**) ដំណើរការ និងសកម្មភាពបង្រៀន និងរៀនអំណានជាក់ស្តែង(**តម្លៃមធ្យម=៣.៦៨**) ការប្រើប្រាស់សម្ភារៈបង្រៀន និងសម្ភារៈឧបទេស(**តម្លៃមធ្យម=៣.៧២**) និងការវាយតម្លៃលទ្ធផលសិក្សា(**តម្លៃមធ្យម=៣.៤០**)។

ទន្ទឹមនឹងចំណុចវិជ្ជមានខាងលើ ក្នុងនោះក៏មានចំណុចខ្វះខាតសំខាន់ៗមួយចំនួនដែលជាបញ្ហាប្រឈមទាមទារឱ្យមានដំណោះស្រាយផងដែរ។ បញ្ហាទាំងនោះមានដូចជា មិនទាន់មានម៉ោងបណ្ណាល័យដើម្បីលើកកម្ពស់គុណភាពបង្រៀនអំណាន(**តារាង៤.២២**) មិនមានវគ្គបំប៉នស្រាវជ្រាវបន្ថែមលើវិធីសាស្ត្រនៃការបង្រៀនអំណានភាសាខ្មែរ(**តារាង៤.២២**) គ្មានការរៀបចំកម្មវិធីបំប៉នបន្ថែមចំពោះសិស្សខ្សោយអំណាន(**តារាង៤.២២**) គ្មានការផ្លាស់ប្ដូរវិធីសាស្ត្រដោយប្រើល្បែងសិក្សាពីអំណាន(**តារាង៤.២២**) គ្មានការរៀបចំកម្មវិធីការប្រឡង ប្រកួតប្រជែងផ្នែកអំណានតាមកម្រិត(**តារាង៤.២២**)។

ក្រៅពីនេះ កត្តាមួយចំនួនដែលជះឥទ្ធិពលអវិជ្ជមានផ្សេងទៀតគឺ សិស្សខ្លះខ្សោយអំណានប្រកបពាក្យមិនចេញ មិនចេះស្រៈនិងព្យញ្ជនៈបានគ្រប់គ្នា(**តារាង៤.៩**) ខ្លឹមសារអត្ថបទអំណានក្នុងសៀវភៅសិក្សាគោលមិនសូវសមស្របនឹងរយៈពេលកំណត់(ពេលខ្លី) (**តារាង៤.១៥**)

# Abstract

This research aims to understand the teaching and learning process of Khmer language subjects in reading and the challenges related to the reading skills of students at the lower secondary school in Takeo province.

The method used by the researchers to collect these datas is the Quantitative Method. In the quantitative study, the researchers used a multiple-choice questionnaire to ask school administrators, social science teachers, and students. Researchers also compiled an open-ended questionnaire for interviews with school administrators, social science teachers, and students to provide additional information to support some of the answers in the quantitative questionnaire. The samples were selected from three secondary schools in Samrong district, Takeo province. There were 204 sample items, including 6 school management, 18 social science teachers and 180 7th, 8th and 9th grade students.

The results of this study show that the actual situation related to the teaching and learning of Khmer language in reading at the lower secondary school in Takeo province is positive or very good (Mean=3.62) and there are some challenges. Supporting indicators include curriculum implementation (Mean = 3.84), implementation of teaching methods (Mean = 3.49), teaching and learning activities (Mean = 3.68), use of teaching materials (Mean = 3.72) and evaluation of academic results (Mean = 3.40).

Along with the above positive points, there are also some major shortcomings that are challenges that need to be addressed. These problems include lack of library time to

improve the quality of reading instruction (**Table 4.22**), lack of additional research sessions on Khmer language teaching methods (**Table 4.22**), lack of supplementary programs for students Poor reading (**Table 4.22**) No change in approach using reading games (**Table 4.22**) No program preparation for level reading competitions (**Table 4.22**).

In addition, the challenge that has a negative impact is that some students are weak in reading, spelling, vowel and alphabet (**Table 4.9**), the content of the text in the textbook is not suitable for the time limit (short time). ) (**Table 4.15**).

# មាតិកា

**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ** ............ ii
**សេចក្តីប្រកាសអះអាងរបស់បេក្ខជន** ............ iii
**លិខិតបញ្ជាក់** ............ iv
**សេចក្តីថ្លែងអំណរគុណ** ............ v
**មូលន័យសង្ខេប** ............ vi
**ជំពូកទី១ ៖ សេចក្តីផ្តើម** ............ 2
១.១. លំនាំបញ្ហានៃការស្រាវជ្រាវ ............ 2
១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ ............ 4
១.៣. គោលបំណងនៃការស្រាវជ្រាវ ............ 5
១.៤. សំណួរស្រាវជ្រាវ ............ 5
១.៥. សារៈសំខាន់នៃការស្រាវជ្រាវ ............ 6
១.៦. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ............ 6
១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............ 7
**ជំពូកទី២ ៖ រំលឹកទ្រឹស្តី** ............ 10
២.១. និយមន័យ ............ 10
២.១.១. តើការបង្រៀន និង រៀន គឺជាអ្វី? ............ 10
២.១.២. អំណានជាអ្វី? ............ 11
២.១.៣. ស្ថានភាពអំណាននៅកម្ពុជា ............ 13
២.២. លក្ខណៈសម្បត្តិរបស់នាយក នាយិកាសាលារៀនល្អ ............ 13
២.៣. តួនាទីគ្រូបង្រៀនក្នុងការដឹកនាំមេរៀនភាសាខ្មែរ ............ 16
២.៣.១. អ្នកជំរុញទឹកចិត្តសិស្ស ............ 16
២.៣.២. អ្នកផ្សព្វផ្សាយ ............ 17
២.៣.៣. អ្នកផ្តើមគំនិត និងដឹកនាំ ............ 17
២.៣.៤. អ្នកវិភាគ ............ 18

២.៣.៥. អ្នកកែតម្រូវ ........................................................................ 18
២.៤. ការអនុវត្តតាមដំណាក់កាលផ្សេងៗនៃការបង្រៀនមុខវិជ្ជាភាសាខ្មែរ ........................ 19
២.៤.១. ការរៀបចំ ........................................................................ 19
២.៤.២. ការដឹកនាំមេរៀន........................................................................ 19
២.៤.៣. ការប្រតិបត្តិ ........................................................................20
២.៤.៤. វង្វាយតម្លៃ ........................................................................20
២.៤.៥. ការពង្រីកចំណេះដឹង ........................................................................ 21
២.៥. សម្ភារៈឧបទេសសម្រាប់ដំណើរការបង្រៀន និងរៀនភាសាខ្មែរ........................ 21
២.៦. វិធីសាស្ត្របង្រៀនភាសាខ្មែរផ្នែកអំណាន ........................................23
២.៦.១. លំនាំនៃការបង្រៀនសមត្ថភាពអាន(អំណាន) ........................................23
២.៦.២. សង្ខេបប្លង់វិធីបង្រៀនអំណាន........................................24
២.៧. ការរៀបចំសិស្សក្នុងដំណើរការបង្រៀន និងរៀនអំណាន ........................................26
២.៧.១. ការងារក្រុមធំ(ក្រុមថ្នាក់ទាំងមូល) ........................................26
២.៧.២. ការងារក្រុមតូច........................................................................26
២.៧.៣. ការងារជាដៃគូ........................................................................27
២.៧.៤. ការងារបុគ្គល ........................................................................27
២.៨. បំណែងចែកខ្លឹមសារ និងម៉ោងសិក្សាអំណាននៅមធ្យមសិក្សាបឋមភូមិ ........................28
២.៩. ការរៀបចំមេរៀន ឬកិច្ចតែងការបង្រៀន ........................................28
២.១០. បរិមាណសិស្សក្នុងថ្នាក់........................................................................29
២.១១. ការលើកទឹកចិត្ត ........................................................................30
**ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ** ........................................................................32
៣.១. គម្រោងវិភាគ ........................................................................32
៣.២. ការប្រមូលទិន្នន័យ........................................................................32
៣.៣. ឧបករណ៍ស្រាវជ្រាវ........................................................................33

៣.៣.១. កម្រិតចង្អុលបង្ហាញ ....................................................................33
៣.៣.២. កម្រងសំណួរ...................................................................................34
៣.៤. ការជ្រើសរើសភាគសំណាក...................................................................36
៣.៥. ការវិភាគទិន្នន័យ ...............................................................................37
**ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា**...........................................................39
៤.១. លទ្ធផលលើកម្រងសំណួររបស់គណៈគ្រប់គ្រងសាលារៀន ....................................39
៤.១.១. ដំណើរការនៃការបង្រៀន និងរៀនអំណាន...................................................39
៤.១.២. ទស្សនៈគណៈគ្រប់គ្រងសាលាចំពោះបញ្ហាប្រឈមក្នុងការជំរុញអំណាន ........................43
៤.១.៣. ទស្សនៈគណៈគ្រប់គ្រងសាលាចំពោះយុទ្ធសាស្ត្រក្នុងការជំរុញអំណាន.........................43
៤.២. លទ្ធផលលើកម្រងសំណួររបស់គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គម ...............................44
៤.២.១. ដំណើរការនៃការបង្រៀន និងរៀនអំណាន...................................................44
៤.២.២. បញ្ហាប្រឈមក្នុងការបង្រៀនអំណាន .......................................................51
៤.៣. លទ្ធផលលើកម្រងសំណួររបស់សិស្ស.......................................................52
៤.៣.១. ដំណើរការនៃការបង្រៀន និងរៀនអំណាន ..................................................52
៤.៣.២. បញ្ហាប្រឈមក្នុងការរៀនអំណាន.............................................................58
៤.៤. លទ្ធផលរួមនៃការស្រាវជ្រាវ .................................................................59
៤.៤.១. ស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាន ...............................59
៤.៤.២. បញ្ហាប្រឈមលើការបង្រៀន និងរៀនអំណាន...............................................65
៤.៥. ការពិភាក្សា .......................................................................................67
៤.៥.១. ការពិភាក្សាលើសំណួរស្រាវជ្រាវទី១ .........................................................67
៤.៥.២. ការពិភាក្សាលើសំណួរស្រាវជ្រាវទី២..........................................................68
**ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និង សំណូមពរ**..............................................71
៥.១. សេចក្តីសន្និដ្ឋាន ................................................................................71
៥.២. សំណូមពរ........................................................................................72

៥.៣. ការស្រាវជ្រាវបន្ត ........................................................................................................73
**ឯកសារយោង**........................................................................................................75
**ឧបសម្ព័ន្ធ**........................................................................................................78

# បញ្ជីតារាង

**តារាង៣.១៖** ចំនួនភាគសំណាក ....................................................................................................37
**តារាង៤.១៖**លទ្ធផលកម្រងសំណួរគណៈគ្រប់គ្រងសាលារៀនទាក់ទងនឹងការអនុវត្តកម្មវិធីសិក្សា .......39
**តារាង៤.២៖** លទ្ធផលលើកម្រងសំណួររបស់គណៈគ្រប់គ្រងសាលារៀនទាក់ទងនឹងការអនុវត្តវិធីសាស្ត្របង្រៀន.........................................................................................................................40
**តារាង៤.៣៖** លទ្ធផលលើកម្រងសំណួររបស់គណៈគ្រប់គ្រងសាលារៀន ទាក់ទងនឹងការបង្រៀនអំណានជាក់ស្តែង ...............................................................................................................41
**តារាង៤.៤៖** លទ្ធផលលើកម្រងសំណួររបស់គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គម ទាក់ទងនឹងការអនុវត្តកម្មវិធីសិក្សា.....................................................................................................................44
**តារាង៤.៥៖** លទ្ធផលលើកម្រងសំណួររបស់គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គម ទាក់ទងនឹងការអនុវត្តវិធីសាស្ត្របង្រៀនអំណាន...................................................................................................45
**តារាង៤.៦៖** លទ្ធផលលើកម្រងសំណួររបស់គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គម ទាក់ទងនឹងស្ថានភាពអនុវត្តជាក់ស្តែងក្នុងដំណើរការ និងសកម្មភាពបង្រៀនអំណាន.............................................47
**តារាង៤.៧ ៖** លទ្ធផលលើកម្រងសំណួររបស់គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គម ទាក់ទងនឹងការប្រើប្រាស់សម្ភារៈបង្រៀន និងសម្ភារៈឧបទេសក្នុងការបង្រៀនអំណាន .............................................48
**តារាង៤.៨ ៖** លទ្ធផលលើកម្រងសំណួររបស់គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គម ទាក់ទងនឹងការវាយតម្លៃលទ្ធផលក្នុងការបង្រៀនអំណាន ................................................................................49
**តារាង៤.៩ ៖** លទ្ធផលលើកម្រងសំណួររបស់គ្រូបង្រៀនវិទ្យាសាស្ត្រសង្គម ទាក់ទងនឹងបញ្ហាប្រឈមក្នុងការបង្រៀនអំណាន ..................................................................................................51
**តារាង៤.១០៖** លទ្ធផលលើកម្រងសំណួររបស់សិស្សានុសិស្ស ទាក់ទងនឹងការអនុវត្តកម្មវិធីសិក្សា ......52
**តារាង៤.១១៖** លទ្ធផលលើកម្រងសំណួររបស់សិស្សានុសិស្ស ទាក់ទងនឹងរបៀបរៀនអំណាន ...........53
**តារាង៤.១២៖** លទ្ធផលលើកម្រងសំណួររបស់សិស្សានុសិស្ស ទាក់ទងនឹងសកម្មភាពបង្រៀនអំណានភាសាខ្មែរ....................................................................................................................54
**តារាង៤.១៣៖** លទ្ធផលលើកម្រងសំណួររបស់សិស្សានុសិស្ស ទាក់ទងនឹងការប្រើប្រាស់សម្ភារៈក្នុងការបង្រៀនអំណានភាសាខ្មែរ......................................................................................................56
**តារាង៤.១៤៖** លទ្ធផលលើកម្រងសំណួររបស់សិស្សានុសិស្ស ទាក់ទងនឹងការវាយតម្លៃលទ្ធផលក្នុងការបង្រៀនអំណានភាសាខ្មែរ......................................................................................................57

**តារាង៤.១៥៖** លទ្ធផលលើកម្រងសំណួររបស់សិស្សានុសិស្សទាក់ទងនឹងបញ្ហាប្រឈមនានាក្នុងការរៀនអំណានភាសាខ្មែរ........58
**តារាង៤.១៦៖** លទ្ធផលរួមនៃដំណើរការបង្រៀន និងរៀនអំណាន........59
**តារាង៤.១៧ ៖** ការអនុវត្តកម្មវិធីសិក្សា........60
**តារាង៤.១៨ ៖** ការអនុវត្តវិធីសាស្ត្របង្រៀន........61
**តារាង៤.១៩៖** ដំណើរការ និងសកម្មភាពបង្រៀន និងរៀនអំណាន(ជាក់ស្តែង)........62
**តារាង៤.២០៖** ការប្រើប្រាស់សម្ភារៈបង្រៀន និងសម្ភារៈឧបទេស........63
**តារាង៤.២១៖** ការវាយតម្លៃលទ្ធផលសិក្សា........64
**តារាង៤.២២៖** បញ្ហាអវិជ្ជមាននានា(ចំណុចមិនសូវអនុវត្ត) លើការបង្រៀនអំណានភាសាខ្មែរ........65

# ជំពូក ១

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១. លំនាំបញ្ហានៃការស្រាវជ្រាវ

កាលណានិយាយដល់ភាពរីកចម្រើននៃប្រទេសមួយ គាត់តែងតែស្រមៃដល់ធនធានមនុស្សនៃប្រទេសនោះ។ ក្នុងន័យនេះដែរ ដើម្បីជានាបាននូវការអភិវឌ្ឍប្រទេសប្រកបទៅដោយនិរន្តរភាព ភាពសុខដុមរមនា និងចីរភាព ប្រទេសនីមួយៗនៅលើពិភពលោកតែងតែខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើវិស័យអប់រំជាគ្រឹះនៃការផលិតធនធានមនុស្ស។ ជាមួយគ្នានេះ អង្គការយូណេស្កូបានកំណត់ចក្ខុវិស័យរបស់ខ្លួនថា ការអប់រំនៅសតវត្សទី២១គឺជាការផ្លាស់ប្តូរជីវិតឱ្យប្រសើរឡើង ដោយទទួលស្គាល់តួនាទីយ៉ាងសំខាន់នៃការអប់រំថា ជាក្បាលម៉ាស៊ីនចម្បងមួយនៃការអភិវឌ្ឍដោយចីរភាពផ្សេងទៀត។ ចំណុចដៅ៤.៤នៃសេចក្តីប្រកាសទីក្រុងIncheonបានកំណត់ថា ត្រឹមឆ្នាំ២០៣០រដ្ឋាភិបាលត្រូវបង្កើនឱ្យបានច្រើននូវចំនួនយុវជន និងមនុស្សពេញវ័យដែលមានជំនាញពាក់ព័ន្ធរួមមានជំនាញបច្ចេកទេស និងវិជ្ជាជីវៈសម្រាប់ឱកាសទទួលបានការងារសមរម្យ និងសហគ្រិនភាព (យូណេស្កូ, ២០១៥)។

ដើម្បីឆ្លើយតបនឹងនិន្នាការពិភពលោកដែលកំពុងយកចិត្តទុកដាក់ខ្ពស់លើការលើកកម្ពស់វិស័យអប់រំនេះ សមាគមន៍អាស៊ានបានឯកភាពគ្នាបន្តពង្រឹង និងពង្រីកសកម្មភាពអប់រំ ដើម្បីរួមគ្នាដោះស្រាយ និងបំពេញភាពខ្វះខាតទាំងឡាយដែលនៅសេសសល់ ដូចជាការកាត់បន្ថយគម្លាតអភិវឌ្ឍន៍ ការតភ្ជាប់អាស៊ានទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ទាំងផ្នែកស្ថាប័ន ទាំងផ្នែកសហគ្រាសខ្នាតតូច និងមធ្យម។ កត្តាទាំងនេះទាមទារឱ្យមានការបណ្តុះបណ្តាលធនធានមនុស្សផ្នែកចំណេះដឹង និងជំនាញបច្ចេកទេសដែលមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងតំបន់ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៥)។

ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ នីតិកាលទី៦នៃរដ្ឋសភា ដែលបានផ្តល់អាទិភាពលើវិស័យអប់រំដោយបានលើកឡើងពីការអភិវឌ្ឍ

ធនធានមនុស្សនៅក្នុងមុំយុទ្ធសាស្ត្រទីមួយ រួមមាន ១)ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកទេស ២)ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស ៣)ការលើកកម្ពស់សេវាសុខភាពសាធារណៈនិងអាហារូបត្ថម្ភ និង៤)ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម (រាជរដ្ឋាភិបាលកម្ពុជា, ២០១៨)។ នេះបញ្ជាក់ឱ្យឃើញថា ដើម្បីធានាឱ្យបាននូវការអភិវឌ្ឍជាតិ និងការប្រកួតប្រជែងខ្ពស់នៅសម័យសាកលភាវូបនីយកម្មទំនើបនេះ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងលើគុណភាពនៃវិស័យអប់រំ។

នៅអំឡុងឆ្នាំ២០១៦ គឺពាក់កណ្ដាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៤-២០១៨ ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការពិនិត្យឡើងវិញ និងបានធ្វើការកែសម្រួលគោលនយោបាយអប់រំមកត្រឹមពីរវិញ ក្នុងគោលបំណងឱ្យមានសង្គតិភាពជាមួយនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ស្ដីពីការអប់រំនៅកម្ពុជាដែលមាន៖

- **គោលនយោបាយទី១៖** ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា
- **គោលនយោបាយទី២៖** ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩)។

ក្នុងផ្នែកចម្បងមួយនៃការលើកស្ទួយវិស័យអប់រំនេះផងដែរ ភាសា និងអក្សរសាស្ត្រខ្មែរក៏បានដើរតួនាទីយ៉ាងសំខាន់ផ្នែកវិស័យអប់រំ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាពិសេសរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រាទី៥បានកំណត់ថា«ភាសា និងអក្សរដែលប្រើជាផ្លូវការ គឺភាសា និងអក្សរខ្មែរ» (រាជរដ្ឋាភិបាលកម្ពុជា, ២០០៨)។ បច្ចុប្បន្ននេះ តម្រូវការនៃការប្រើប្រាស់ភាសា និងអក្សរសាស្ត្រខ្មែរមានការកើនឡើងខ្ពស់ផងដែរ ជាពិសេសក្នុងវិស័យពាណិជ្ជកម្ម ទេសចរណ៍ បរិស្ថានបច្ចេកវិទ្យាគមនាគមន៍ សង្គម និងសេដ្ឋកិច្ច (រាជរដ្ឋាភិបាលកម្ពុជា, ២០១៩)។

ក្នុងការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរ ត្រូវផ្ដោតលើសមត្ថភាពសំខាន់ៗ៤គឺ សមត្ថភាពស្ដាប់ សមត្ថភាពនិយាយ សមត្ថភាពអាន(អំណាន) សមត្ថភាពសរសេរ (ក្រសួងអប់រំ យុវជន និងកីឡា,

២០១០)។ ក្នុងនោះដែរ ដោយមើលឃើញពីសារៈសំខាន់នៃសមត្ថភាពអំណានជាផ្នែកមួយដ៏សំខាន់ក្នុង ចំណោមសមត្ថភាពទាំងបួននៃភាសាខ្មែរ ទើបរាជរដ្ឋាភិបាលកម្ពុជាកំណត់យកថ្ងៃទី១១ ខែមីនា រៀងរាល់ឆ្នាំ ជាទិវាជាតិអំណាននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបណ្តុះទម្លាប់អាន ជំរុញវប្បធម៌អាន លើកកម្ពស់សមត្ថភាពអាន និងការតែងនិពន្ធ រួមចំណែកការពារ និងពង្រឹងវប្បធម៌ខ្មែរ (រាជរដ្ឋាភិបាលកម្ពុជា, ២០១៥)។

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ក្នុងពេលបច្ចុប្បន្ន ការប្រើភាសាខ្មែរដូចជាសំណេរ ការបន្លឺសូរភាសា ក្បួនវេយ្យាករណ៍ខ្មែរជាដើម នៅពុំទាន់មានលក្ខណៈស្តង់ដារគ្រប់គ្រាន់នៅឡើយ ថ្វីដ្បិតតែយើងបានយកវចនានុក្រមខ្មែរបោះពុម្ពគ្រាទី ៥ ដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យឆ្នាំ១៩៦៧-១៩៦៨ជាគោលក៏ដោយ។ (រាជរដ្ឋាភិបាលកម្ពុជា, ២០១៩)

ក្នុងផ្នែកនៃការប្រើភាសាខ្មែរនេះ អំណានមានសារៈសំខាន់ណាស់ក្នុងការរួមចំណែកកាត់បន្ថយអនក្ខរភាព ទទួលយកចំណេះដឹង ឬព័ត៌មានមកពីគ្រប់ទិសទី ដើម្បីបើកគំនិតឱ្យបានទូលំទូលាយ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី អំណាននៅកម្ពុជាមិនមានភាពប្រសើរនៅឡើយទេ។ ទោះបីជាថ្មីៗនេះមានការលើកកម្ពស់ប្រសិទ្ធភាពអំណានសម្រាប់កុមារកម្ពុជា ហើយតាំងពីមានការកែទម្រង់កម្មវិធីសិក្សាទូទៅថ្នាក់ជាតិមកពីឆ្នាំ ២០១០ ដល់ ២០១៣ ក៏ដោយ តាមរបាយការរបស់ World Bank កាលឆ្នាំ ២០១៤ ថា ជាទូទៅពិន្ទុអំណាននៅតែទាបមិនអាចទទួលយកបាន ព្រមទាំងឃើញថា កុមារជាង ២៥% នៅតែមានសមត្ថភាពអានទាបជាងស្តង់ដា ។ ដោយសារតែសមត្ថភាពអាន គឺជាមូលដ្ឋានគ្រឹះសម្រាប់រៀនមុខវិជ្ជាដទៃទៀត ហើយការធ្លាក់ចុះនៃប្រព័ន្ធអប់រំក្នុងការសម្រេចបានប្រសិទ្ធភាពខ្ពស់នៃអំណាននៅថ្នាក់ដំបូង (ទី១ ទី២ និងទី៣) ធ្វើឱ្យលទ្ធផលសិក្សាធ្លាក់ចុះនៅឆ្នាំបន្តបន្ទាប់ ។ ផ្អែកតាមទំព័រហ្វេសប៊ុកផ្លូវការ **MoEYS Cambodia** របស់ក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧ ស្តីពីវប្បធម៌អំណាននៅកម្ពុជា និងតួនាទីអំណានក្នុងវិស័យអប់រំ បានបញ្ជាក់ថា ការសិក្សាស្រាវជ្រាវតាមសាលាស្តីពីតេស្តស្តង់ដាថ្នាក់ទី៣(ឆ្នាំ២០១១) ស្រាវជ្រាវលើការអនុវត្តម៉ោងបង្រៀនសាលាបឋមសិក្សាថ្នាក់ទី១ ដល់

ទី៦(ឆ្នាំ២០១០) និងស្រាវជ្រាវលើការអនុវត្តម៉ោងបង្រៀនសាលាមធ្យមសិក្សាបឋមភូមិថ្នាក់ទី៧ ដល់ទី៩(ឆ្នាំ២០០៩)ឃើញថា ការអានរបស់សិស្សបានស្រុតចុះយ៉ាងខ្លាំង។ ដោយមើលឃើញថា ផ្នែកអំណាននៅប្រទេសកម្ពុជានៅមានកម្រិតនៅឡើយ ទើបរាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ១២០អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីទិវាជាតិអំណាន ដោយកំណត់យកថ្ងៃទី១១ ខែមីនា រៀងរាល់ឆ្នាំជាទិវាជាតិអំណាននៃព្រះរាជាណាចក្រកម្ពុជា។ ទាំងនេះបង្ហាញឱ្យឃើញថា ការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅមានចំណុចខ្វះខាតនៅឡើយ។

ដោយសង្កេតឃើញនូវបញ្ហា និងសូចនាករនានាដែលពាក់ព័ន្ធនឹងផ្នែកអំណាននេះហើយ ទើបប្រធានបទ **ស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ** ត្រូវបានជ្រើសរើសយកមកធ្វើការសិក្សាស្រាវជ្រាវ។

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

ដោយសារមានចម្ងល់ជាច្រើនពាក់ព័ន្ធនឹងគុណភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាន ទើបធ្វើឱ្យអ្នកស្រាវជ្រាវសម្រេចចិត្តជ្រើសរើសយកបញ្ហានេះមកធ្វើជាប្រធានបទស្រាវជ្រាវ។ ការសិក្សាស្រាវជ្រាវនេះមានគោលបំណងធំៗពីរគឺ៖

១. សិក្សាឈ្វេងយល់ពីដំណើរការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅកម្រិតមធ្យមសិក្សាបឋមភូមិ

២. រកឱ្យឃើញពីបញ្ហាប្រឈមដែលទាក់ទងនឹងការបង្រៀន និងរៀនសមត្ថភាពអំណាននៅកម្រិតមធ្យមសិក្សាបឋមភូមិ

## ១.៤. សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងខាងលើ សំណួរស្រាវជ្រាវពីរត្រូវបានលើកឡើង៖

១. តើការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរលើសមត្ថភាពអំណាននៅសាលាមធ្យមសិក្សាបឋមភូមិមានស្ថានភាពយ៉ាងដូចម្តេច?

២. តើការបង្រៀន និងរៀនសមត្ថភាពអំណាននៅកម្រិតមធ្យមសិក្សាបឋមភូមិមានបញ្ហាប្រឈម អ្វីខ្លះ?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវពីស្ថានភាពជាក់ស្តែងនៃដំណើរការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាន មានសារៈសំខាន់ណាស់ក្នុងការជួយអភិវឌ្ឍបំណិននៃការអានរបស់កុមារ និងបញ្ហាប្រឈមជាក់ស្តែងទាក់ទងនឹងអំណាននៅសាលាមធ្យមសិក្សាបឋមភូមិ។ ទន្ទឹមនឹងនេះ វាអាចបង្ហាញពីផលលំបាកក្នុងការសិក្សាភាសាខ្មែររបស់សិស្ស និងតម្រូវការនៃការសិក្សាភាសាខ្មែរឱ្យទទួលបានលទ្ធផលល្អប្រសើរ។ ម៉្យាងទៀត ការសិក្សានេះនឹងក្លាយជារបកគំហើញថ្មីមួយសម្រាប់លោកគ្រូ អ្នកគ្រូដែលកំពុងបង្រៀនមុខវិជ្ជាភាសាខ្មែរ ដើម្បីឱ្យពួកគាត់យល់ដឹងពីចំណុចខ្វះខាតរបស់ខ្លួននិងសិស្ស និងតម្រូវការនៃការបង្រៀន និងរៀនភាសាខ្មែរប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ ជាងនេះទៅទៀត អាចជាប្រទីបបំភ្លឺផ្លូវសម្រាប់អ្នកអភិវឌ្ឍ និងរៀបចំកម្មវិធីសិក្សាក្នុងការអភិវឌ្ឍ និងរៀបចំកម្មវិធីសិក្សាភាសាខ្មែរថ្នាក់ជាតិឱ្យស្របទៅតាមតម្រូវការរបស់សិស្ស បរិបទសង្គម តម្រូវការទីផ្សារការងារ និងមានភាពឆ្លើយតប។ ជាពិសេស ការសិក្សាស្រាវជ្រាវនេះក៏ចូលរួមជាវិភាគទានដល់អ្នកសិក្សាស្រាវជ្រាវក្រោយៗ ដើម្បីឱ្យពួកគាត់ធ្វើការសិក្សាស្រាវជ្រាវបន្តទៀតពាក់ព័ន្ធនឹងប្រធានបទស្រដៀងគ្នានេះ។

## ១.៦. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

នៅក្នុងខេត្តតាកែវមានស្រុកប្រាំបួន និងក្រុងមួយ។ អ្នកស្រាវជ្រាវបានសម្រេចជ្រើសរើសយកតែស្រុកមួយគឺស្រុកសំរោង ដោយផ្តោតលើសាលាមធ្យមសិក្សាបឋមភូមិចំនួនបីក្នុងស្រុកសំរោង ខេត្តតាកែវជាសាលាគោលដៅសម្រាប់ការសិក្សាស្រាវជ្រាវ ដើម្បីឈ្វេងយល់ពីស្ថានភាពជាក់ស្តែង និងបញ្ហាប្រឈមនៃដំណើរការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិ។ អ្នកសិក្សាស្រាវជ្រាវយល់ថា ជាស្រុកកំណើត បង្កលក្ខណៈងាយស្រួលក្នុងការចុះប្រមូលព័ត៌មាន ទើបបានជ្រើសរើសយកសាលាមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកសំរោង ខេត្តតាកែវមកធ្វើសំណាកស្រាវជ្រាវ ព្រោះខេត្ត

តាកែវមានការរីកចម្រើនខ្លាំងទាំងផ្នែកអប់រំ ទីផ្សារការងារ សេដ្ឋកិច្ចជាដើម។ ដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះមានតម្លៃ និងស៊ីជម្រៅគ្រប់ជ្រុងជ្រោយ អ្នកស្រាវជ្រាវជ្រើសរើសយកគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គមនៅសាលាមធ្យមសិក្សាបឋមភូមិ សិស្សថ្នាក់ទី៧ ទី៨ ទី៩ ចេញពីអនុវិទ្យាល័យចំនួនបី ក្នុងស្រុកសំរោង ខេត្តតាកែវ។ ក្នុងនោះសិស្សចំនួន១៨០នាក់ និងគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គមកម្រិតមធ្យមសិក្សាបឋមភូមិចំនួន១៨នាក់ ត្រូវជ្រើសរើសឱ្យបំពេញកម្រងសំណួរដាច់ដោយឡែកពីគ្នា ដែលរៀបចំឡើងដោយអ្នកសិក្សាស្រាវជ្រាវ។ ក្រៅពីនេះ គណៈគ្រប់គ្រងសាលារៀនចំនួន០៦នាក់ទៀតនៃអនុវិទ្យាល័យគោលដៅនីមួយៗ ក៏ត្រូវបានអញ្ជើញឱ្យបំពេញកម្រងសំណួរពហុជ្រើសរើស ឆ្លើយជាសំណួរទម្រង់បើក និងឆ្លើយតាមរយៈការសម្ភាសផ្ទាល់មាត់ផងដែរ។

## ១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានបែងចែកជា ៥ ជំពូកធំៗ៖

**ជំពូកទី១៖** ***សេចក្តីផ្តើម*** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានលើកឡើងពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការសិក្សាស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវលើប្រធានបទ "**ស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ**"។

**ជំពូកទី២៖** ***រំលឹកទ្រឹស្តី*** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានប្រមូលយកនូវទ្រឹស្តីដែលមានពីមុន ពាក់ព័ន្ធនឹងប្រធានបទ ជាពិសេសមុខវិជ្ជាភាសាខ្មែរដោយផ្តោតសំខាន់លើផ្នែកអំណាន។ ទន្ទឹមនឹងនេះ ដែរមានទ្រឹស្តីពីអ្នកសិក្សាស្រាវជ្រាវមុនៗតាមរយៈសៀវភៅ កម្រងអត្ថបទស្រាវជ្រាវជាតិនិងអន្តរជាតិ រដ្ឋធម្មនុញ្ញ លិខិតបទដ្ឋានគតិយុត្ត សេចក្តីប្រកាស សារាចរណែនាំ និងឯកសារពាក់ព័ន្ធនានារបស់ក្រសួងអប់រំ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីធ្វើជាគំនិតនិងជាទុនសម្រាប់ស្រាវជ្រាវ និងបង្កើតជាស្នាដៃថ្មី។

**ជំពូកទី៣៖** ***វិធីសាស្ត្រស្រាវជ្រាវ*** ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ វិធីសាស្ត្រជ្រើសរើសសំណាក និងប្រភេទសំណាក ព្រមទាំងវិធី

សាស្ត្រក្នុងការវិភាគទិន្នន័យរកតម្លៃមធ្យម និងគម្លាតស្តង់ដា តាមរយៈកម្មវិធី SPSS និងកម្មវិធី MS. EXCEL សម្រាប់សង់តារាង និងផ្ដុំទិន្នន័យបញ្ចូលគ្នា។

**ជំពូកទី៤៖** ***លទ្ធផលនៃការស្រាវជ្រាវ*** ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងយកទិន្នន័យដែលប្រមូលបានមកធ្វើការវិភាគ និងធ្វើការបកស្រាយឱ្យបានយ៉ាងក្បោះក្បាយដើម្បីរកឱ្យឃើញនូវចំណុចល្អ ចំណុចដែលត្រូវកែលម្អនៅក្នុងបរិបទជាក់ស្តែងនៃការសិក្សាភាសាខ្មែរផ្នែកអំណានរបស់សិស្សនៅកម្រិតមធ្យមសិក្សាបឋមភូមិ និងតម្រូវការសម្រាប់នាយក គ្រូ និងសិស្សដែលបម្រើឱ្យការបង្រៀន និងរៀនអំណានទទួលបានលទ្ធផលល្អប្រសើរ។

**ជំពូកទី៥៖** ***សេចក្តីសន្និដ្ឋាន និងសំណូមពរ*** ជាផ្នែកមួយដែលអ្នកសិក្សាស្រាវជ្រាវត្រូវធ្វើការសន្និដ្ឋានលើចំណុចរួមទាំងអស់ដែលបានវិភាគ ព្រមទាំងផ្តល់ជាសំណូមពរមួយចំនួនដល់ក្រសួងអប់រំ មន្ទីរអប់រំខេត្ត ការិយាល័យអប់រំស្រុក គណៈគ្រប់គ្រងសាលា គ្រូបង្រៀន អាជ្ញាធរក្នុងសហគមន៍ អ្នកសិក្សាស្រាវជ្រាវក្រោយៗ និងភាគីពាក់ព័ន្ធក្នុងគោលបំណងចូលរួមចំណែកអភិវឌ្ឍ និងធ្វើឱ្យស្ថានភាពនៃការបង្រៀន និងរៀនភាសាខ្មែរផ្នែកអំណានរបស់សិស្សមានភាពល្អប្រសើរជាងមុន។

# ជំពូក ២

# រំលឹកទ្រឹស្តី

# ជំពូកទី២

# រំលឹកទ្រឹស្តី

## ២.១. និយមន័យ

### ២.១.១. តើការបង្រៀន និង រៀន គឺជាអ្វី?

**ការបង្រៀន** ជាការញ៉ាំងអ្នកដទៃឱ្យរៀន ប្រៀនឱ្យចេះ ឱ្យមានចំណេះដោយការបង្ហាត់ និងបង្ហាញឱ្យចេះ (ជួន ណាត, ១៩៦៧)។

**ការបង្រៀន** ជាសកម្មភាពសម្របសម្រួលការរៀនរបស់សិស្ស លើកទឹកចិត្តឱ្យចេះរៀនដោយខ្លួនឯង ពង្រឹង និងពង្រីកចំណេះ ដឹងបទពិសោធន៍ដល់សិស្សគ្រប់រូប។ សកម្មភាពនៃការបង្រៀនរួមមានការពន្យល់ ការដាក់ចំណោទ ការសួររកហេតុ និងផល ការសួរសំណួរ ការលើកទឹកចិត្ត ការតាមដានសាវតារបស់សិស្ស ការប្រឡង ឬការវាយតម្លៃអំពីការរីកចម្រើនរបស់សិស្ស។ល។ ក្រៅពីមានចំណេះដឹងខាងផ្នែកចិត្តគរុកោសល្យ គ្រូបង្រៀនក៏ដូចជាអ្នកដ៏ទៃទៀតដែរ ចាំបាច់ត្រូវតែបន្តស្រាវជ្រាវរកអ្វីដែលថ្មីអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួន និងបង្កើតអ្វីដែលថ្មីពេញមួយជីវិតការងារ (នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា, ២០១៥)។

ទ្រឹស្តីនៃគំនិតបែបទំនើប(Modern Concept) បានលើកឡើងថា ការបង្រៀនគឺជាបុព្វហេតុដែលជំរុញឱ្យសិស្សខិតខំរៀនសូត្រ និងទទួលបានចំណេះដឹង បទពិសោធន៍ និងមធ្យោបាយសម្រាប់ការរស់នៅរបស់ខ្លួនជាមួយសង្គមឱ្យសមស្របទៅតាមបំណងប្រាថ្នាដែលពួកគាត់ចង់បានផងដែរ។ ទិដ្ឋភាពដ៏សំខាន់បំផុតនៃដំណើរការបង្រៀន គឺសិស្ស និងអ្វីដែលពួកគាត់រៀន (Dr. A. H. Sequeira, 2002)។ ការបង្រៀនគឺជាការយកចិត្តទុកដាក់ទៅលើសម្មភាពរបស់សិស្ស រួមមាន សកម្មភាពលេង និងការបង្កើតថ្មី ឬរបកគំហើញថ្មី (Paul H. Hirst, 2004) ។

**ការរៀន** មានន័យថា ការសិក្សា ខំសង្កេតឱ្យចេះ ទទួលយកចំណេះ ហាត់ហ្វឹក ដោយទន្ទេញស្វាធ្យាយឱ្យចងចាំ (ជួន ណាត, ១៩៦៧)។

**ការរៀន** គឺជាទង្វើនៃការទទួលបានអ្វីដែលថ្មី ឬការកែប្រែ និងពង្រឹងចំណេះដឹង អាកប្បកិរិយា បំណិន គុណតម្លៃ ឬចំណង់ចំណូលចិត្តដែលមានស្រាប់ ហើយអាចពាក់ព័ន្ធនឹងការសំយោគព័ត៌មានប្រភេទផ្សេងៗគ្នាសម្រាប់ការប្រើប្រាស់ (នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សានៃក្រសួងអប់រំ យុវជន និង កីឡា, ២០១៥)។

ការសិក្សាគឺជាសកម្មភាពរបស់មនុស្សម្នាក់ៗ ដែលចង់បានចំណេះសម្រាប់យកទៅប្រើប្រាស់ក្នុងជីវភាពរស់នៅរបស់ខ្លួន និងធ្វើយ៉ាងណាឱ្យកាន់តែប្រសើរឡើង ពោលគឺធ្វើឱ្យមានការផ្លាស់ប្ដូរជីវិតរស់នៅទាំងឥរិយាបទ និងស្មារតី។ ការសិក្សាគឺជាដំណើរការនៃការទទួលយកនូវអ្វីដែលថ្មី និងអភិវឌ្ឍទៅលើអ្វីដែលមានស្រាប់ឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីទទួលបានការផ្លាស់ប្ដូរទាំងស្រុងដែលឆ្ពោះទៅរកពលរដ្ឋពេញលេញ។ ការរៀនអាចកើតឡើងបានអាស្រ័យលើគម្រោង ឬកាលវិភាគនៃការសិក្សាដែលជាគ្រឿងជំរុញឱ្យត្រូវតែមករៀន។ ឥរិយាបថនៃការរៀនរបស់សិស្ស ក៏អាចឈានទៅដល់ចំណុចទីបញ្ចប់នៃគម្រោងការណ៍នេះផងដែរ (ThreeTypes of Learning, 2015)។

**មធ្យមសិក្សាមបឋមភូមិ** ជាកម្រិតសិក្សាបន្តពីបឋមសិក្សាដែលមានកម្រិតថ្នាក់ចាប់ពីថ្នាក់ទី ១ ដល់ថ្នាក់ទី ៦ ។ មធ្យមសិក្សាមបឋមភូមិនេះ គឺជាកម្រិតសិក្សាដែលរាប់ចាប់ពីថ្នាក់ទី ៧ ដល់ថ្នាក់ទី ៩ ។ ការសិក្សាកម្រិតនេះ គឺជាការរៀបចំសិស្សឱ្យត្រៀមខ្លួនរួចរាល់ដើម្បីបន្តការសិក្សាចូលដល់ថ្នាក់មធ្យមសិក្សាទុតិយភូមិដែលចាប់ពីថ្នាក់ទី ១០ ដល់ទី ១២ (ក្រសួងអប់រំ យុវជន និង កីឡា ,២០០២)។

### ២.១.២. អំណានជាអ្វី?

ក្នុងការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរ គឺមានសមត្ថភាពសំខាន់ៗ៤គឺ សមត្ថភាពស្ដាប់ សមត្ថភាពនិយាយ សមត្ថភាពអាន(អំណាន) សមត្ថភាពសរសេរ (នាយកដ្ឋានបណ្ដុះបណ្ដាល និងក្រឹត្រការនៃក្រសួងអប់រំ យុវជន និង កីឡា, ២០១០)។ ក្នុងន័យនេះយើងអាចនិយាយបានថា អំណានគឺជាសមត្ថភាពមួយក្នុងចំណោមសមត្ថភាពទាំងបួននៃមុខវិជ្ជាភាសាខ្មែរ។

តាមវចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត ភាគ១ និងភាគ២បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧ លោកបានពន្យល់ «**អំណាន ឬការអាន**»មានន័យថា ការមើលថាតាមអក្សរ។

តាមសៀវភៅភាសាអង់គ្លេស (Arab Ideal) លោកបានពន្យល់ថា៖- «អំណាន ឬ ការអាន» គឺសំដៅដល់ការសម្លឹងមើល និងយល់ដឹងពីន័យសេចក្ដីនៃពាក្យពេចន៍ ដែលបានសរសេរ ឬបោះពុម្ព។ «ការអាន»គឺជាការនិយាយឮៗនូវពាក្យដែលបានសរសេរ ឬបោះពុម្ព ផ្សាយ។ «ការអាន ឬ អំណាន» មានន័យថា ការស្វែងយល់ពីអត្ថន័យពាក្យពេចន៍ដែលបានបង្កប់ ដែលមិនបានបង្ហាញឱ្យឃើញភ្លាមៗ។«អំណាន» មានន័យថា ជាសកម្មភាពនៃការស្វែងយល់ពីអត្ថន័យនៃពាក្យពេចន៍ដែលបានសរសេរ ឬបោះពុម្ពផ្សាយ។

តាមការសង្កេត យើងអាចចែកអំណានជាបួនប្រភេទគឺ (មនោរម្យ អាំងហ្វូ, ២០១២)

**ក. អំណានក្នុងចិត្ត ឬអំណានស្ងាត់**

គឺជាការអាន ដែលប្រើប្រាស់សកម្មភាពយល់ដឹងពីពាក្យពេចន៍ ឃ្លាប្រយោគ ល្បះ អត្ថបទ កាយវិការ រូបភាព សូរសំឡេង ឬរលកគំនិតទាំងឡាយតែក្នុងចិត្ត ពោលគឺមិនប្រើប្រាស់សំឡេងខ្លួនឯងចេញមកក្រៅអ្វីឡើយ។

**ខ. អំណានខ្សឹប**

គឺជាការអានដែលប្រើប្រាស់សកម្មភាពយល់ដឹងពីពាក្យពេចន៍ ឃ្លាប្រយោគ ល្បះ អត្ថបទ កាយវិការ រូបភាព សូរសំឡេង ឬរលកគំនិតទាំងឡាយ ដោយប្រើប្រាស់សំឡេងតិចៗ ឬខ្សឹបៗចេញមកក្រៅ។

**គ. អំណានឮ**

គឺជាការអានដែលប្រើប្រាស់សកម្មភាពយល់ដឹងពីពាក្យពេចន៍ ឃ្លាប្រយោគ ល្បះ អត្ថបទ កាយវិការ រូបភាព សូរសំឡេង ឬរលកគំនិតទាំងឡាយ ដោយប្រើប្រាស់សំឡេងខ្លាំងៗចេញមកក្រៅ។

**ឃ. អំណានស្ទាប**

គឺជាអំណានដែលភាគច្រើនត្រូវបានប្រើប្រាស់ដោយជនពិកាភ្នែក។ ពួកគាត់អានសៀវភៅ តាមរយៈសញ្ញាអក្សរស្ទាប។ អំណានប្រភេទនេះ គឺអ្នកអានអាចធ្វើតាមរយៈអំណានស្ងាត់ អំណានខ្សឹប ឬអំណានឮក៏បាន។

### ២.១.៣. ស្ថានភាពអំណាននៅកម្ពុជា

ទោះបីជាមានការលើកកម្ពស់ប្រសិទ្ធភាពអំណានសម្រាប់កុមារកម្ពុជា ហើយតាំងពីមានការកែទម្រង់កម្មវិធីសិក្សាទូទៅថ្នាក់ជាតិមកពីឆ្នាំ ២០១០ ដល់ ២០១៣ ក៏ដោយ តាមរបាយការរបស់ World Bank កាលឆ្នាំ ២០១៤ ថា ជាទូទៅពិន្ទុអំណាននៅតែទាបមិនអាចទទួលយកបាន ព្រមទាំងឃើញថា កុមារជាង ២៥% នៅតែមានសមត្ថភាពអានទាបជាងស្តង់ដា ។ ពីព្រោះថា សមត្ថភាពអាន គឺជាមូលដ្ឋានគ្រឹះសម្រាប់រៀនមុខវិជ្ជាដ៏ទៃទៀត ហើយការធ្លាក់ចុះនៃប្រព័ន្ធអប់រំក្នុងការសម្រេចបានប្រសិទ្ធភាពខ្ពស់នៃអំណាននៅថ្នាក់ដំបូង (ទី១ ទី២ និងទី៣) ធ្វើឱ្យលទ្ធផលសិក្សាធ្លាក់ចុះនៅឆ្នាំបន្តបន្ទាប់។

ផ្អែកតាមទំព័រហ្វេសប៊ុកផ្លូវការ MoEYS Cambodia របស់ក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១៧ ស្តីពីវប្បធម៌អំណាននៅកម្ពុជា និងតួនាទីអំណានក្នុងវិស័យអប់រំ បានបញ្ជាក់ថា ការសិក្សាស្រាវជ្រាវតាមសាលាស្តីពីតេស្តស្តង់ដាថ្នាក់ទី៣(ឆ្នាំ២០១១) ស្រាវជ្រាវលើការអនុវត្តម៉ោងបង្រៀនសាលាបឋមសិក្សាថ្នាក់ទី១ ដល់ទី៦(ឆ្នាំ២០១០) និងស្រាវជ្រាវលើការអនុវត្តម៉ោងបង្រៀនសាលាមធ្យមសិក្សាបឋមភូមិថ្នាក់ទី៧ ដល់ទី៩(ឆ្នាំ២០០៩)ឃើញថា ការអានរបស់សិស្សបានស្រុតចុះយ៉ាងខ្លាំង។

ដោយមើលឃើញថា ផ្នែកអំណាននៅប្រទេសកម្ពុជានៅមានកម្រិតនៅឡើយ ទើបរាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ១២០អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីទិវាជាតិអំណានដោយកំណត់យកថ្ងៃទី១១ ខែមីនា រៀងរាល់ឆ្នាំជាទិវាជាតិអំណាននៃព្រះរាជាណាចក្រកម្ពុជា។ ទាំងនេះបង្ហាញឱ្យឃើញថា ការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅមានចំណុចខ្វះខាតនៅឡើយ។

## ២.២. លក្ខណៈសម្បត្តិរបស់នាយក នាយិកាសាលារៀនល្អ

នាយក ឬនាយិកាគឺជាតួអង្គដ៏សំខាន់សម្រាប់ដឹកនាំ និងគ្រប់គ្រងការអនុវត្តដំណើរការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៅក្នុងសាលារៀន។ ដូចនេះ គុណភាពនៃការបង្រៀន និងរៀន ទាមទារឱ្យមាននាយក ឬនាយិកាដែលមានគុណសម្បត្តិគ្រប់គ្រាន់ទាំងផ្នែករដ្ឋបាល

និងបច្ចេកទេសក្នុងការជួយពិនិត្យកែលម្អការបង្រៀន និងរៀនរបស់គ្រូ និងសិស្ស។ យោងតាមឧបករណ៍វាយតម្លៃនាយក នាយិកាសាលារៀនល្អ ក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសលេខ៧៦១អយក.ប្រក ចុះថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ២០១៦ បានចែងថា នាយក នាយិកាសាលារៀនល្អ ត្រូវបានកំណត់លក្ខណៈវិនិច្ឆ័យដោយសូចនាករ១១ មានដូចជា៖

១. **គុណវុឌ្ឍិ** ជាលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃដោយគិតលើកម្រិតសញ្ញាបត្រ ដែលនាយក នាយិកាបានទទួលនៅក្នុងក្របខ័ណ្ឌ ក្នុងពេលបំពេញការងាររបស់ខ្លួន។

២. **សមត្ថភាពជំនាញ** សំដៅលើការយល់ដឹងពីគោលនយោបាយអប់រំក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ការដឹកនាំ គ្រប់គ្រង សម្របសម្រួល ច្នៃប្រតិដ្ឋ ការងារអធិការកិច្ច ចំណេះដឹងមូលដ្ឋានផ្នែកព័ត៌មានវិទ្យា ភាសាបរទេស ប្រវត្តិ និងបទពិសោធន៍ក្នុងការងារ ការអភិវឌ្ឍស្ថាប័ន ជំនាញវិភាគ និងការបកស្រាយលើព័ត៌មាន ការលើកទឹកចិត្តសិស្ស គ្រូ និងបុគ្គលិកអប់រំឱ្យចូលរួមក្នុងសកម្មភាពអប់រំជាប្រចាំ។

៣. **ការរៀបចំផែនការ** សំដៅលើចក្ខុវិស័យ បេសកកម្ម គោលបំណងច្បាស់លាស់ ការរៀបចំផែនការដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ការអនុវត្តការងារប្រកបដោយគុណតម្លៃ ការផ្សារភ្ជាប់នឹងសាលារៀន និងសហគមន៍ និងផែនការអភិវឌ្ឍន៍សាលារៀន។

៤. **ការដឹកនាំការរៀន និងបង្រៀន** សំដៅលើការផ្តួចផ្តើម និងការគាំទ្រក្រុមបច្ចេកទេស ការត្រួតពិនិត្យ និងការវាយតម្លៃការរៀន និងការបង្រៀនជាប្រចាំ ការបំប៉នវិធីសាស្ត្រ និងការផ្តល់ប្រឹក្សាបច្ចេកទេសដល់គ្រូបង្រៀន ការអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន ការប្រើវិធីសាស្ត្រដោយមានភាពឆ្លើយតប និងមានភាពច្នៃប្រតិដ្ឋសម្រាប់ការរៀន និងការបង្រៀន ការលើកទឹកចិត្ត និងការធ្វើការជាក្រុម ដើម្បីបង្កើតវប្បធម៌ចែករំលែក និងធានាឱ្យមានសម្ភារៈសិក្សា និងសម្ភារៈឧបទេស។

៥. **ការអភិវឌ្ឍខ្លួនឯង** សំដៅលើការកសាងវប្បធម៌សហការ និងការចូលរួម ពង្រឹងអភិបាលកិច្ចល្អស្វ័យវាយតម្លៃ ការបន្តអភិវឌ្ឍវិជ្ជាជីវៈសម្រាប់ខ្លួនឯង និងគ្រូបង្រៀន ការច្នៃប្រតិដ្ឋ និងការបង្កើតថ្មីដើម្បីឧត្តមភាពការងារ។

៦. **ការគ្រប់គ្រងសាលារៀន** សំដៅលើការរៀបចំរចនាសម្ព័ន្ធ និងបំណែងចែកភារកិច្ច ការអនុវត្តនូវផែនការអភិវឌ្ឍន៍សាលារៀន ការគ្រប់គ្រងធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស ការរៀបចំនូវសេវាគ្រូបង្រៀន និងបុគ្គលិកបានសមស្រប ការរៀបចំបរិស្ថានសាលារៀនល្អ អនាម័យស្អាត ឯកសណ្ឋានសិស្សគ្រូ ការប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យាក្នុងដំណើរការគ្រប់គ្រងសាលារៀន និងធានាសុវត្ថិភាពគ្រូបង្រៀន និងសិស្ស។

៧. **ការធានាគណនេយ្យភាព** សំដៅលើការគ្រប់គ្រងរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ការឆ្លើយតបទៅនឹងព័ត៌មានទាន់ពេលវេលា ការប្រមូល និងប្រើប្រាស់នូវទិន្នន័យដើម្បីវិភាគពីចំណុចខ្លាំង និងចំណុចខ្សោយរបស់សាលារៀន ការផ្តួចផ្តើមអភិវឌ្ឍអភិក្រមចំណាយដោយផ្អែកលើលទ្ធផលបំពេញការងារ ការបិទផ្សាយលទ្ធលផសិក្សារបស់សិស្សដោយតម្លាភាព ការរៀបចំកិច្ចបញ្ជិកាគណនេយ្យហិរញ្ញវត្ថុ បញ្ជីសារពើភ័ណ្ឌ និងបញ្ជីគ្រប់គ្រងវត្តមានបុគ្គលិកបានត្រឹមត្រូវ ការបិទផ្សាយតារាងតម្លាភាពហិរញ្ញវត្ថុ សម្ភារៈ ទ្រព្យសម្បត្តិ និងមន្ត្រីអប់រំ។

៨. **ការពង្រឹងទំនាក់ទំនងជាមួយសហគមន៍** សំដៅលើការផ្សារភ្ជាប់កម្មវិធីបំណិនជីវិតមូលដ្ឋានទៅនឹងតម្រូវការសហគមន៍ ការបង្កើត និងរក្សាស្នាដៃសិស្សដើម្បីជំរុញឪពុកម្តាយ និងសហគមន៍ឱ្យចូលរួមឧបត្ថម្ភ និងគាំទ្រការបង្កើតមូលនិធិសមធម៌អប់រំតាមរយៈភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន និងការផ្តល់ព័ត៌មានត្រឡប់ជាប្រព័ន្ធដល់សិស្ស គ្រូ មាតាបិតា និងសាលារៀន។

៩. **ក្រមសីលធម៌វិជ្ជាជីវៈ** សំដៅលើការប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈ ការពង្រឹងសាមគ្គីភាព និងការទទួលខុសត្រូវ ការគោរពវិន័យការងារ សីលធម៌រស់នៅល្អ គុណធម៌ និងយុត្តិធម៌។

១០. **លទ្ធផលគ្រប់គ្រង** សំដៅលើគ្រូបង្រៀនដែលយល់ដឹងកម្មវិធីសិក្សាតាមកម្រិតថ្នាក់ គ្រូបង្រៀនមានសមត្ថភាពលើវិធីសាស្ត្រ និងបច្ចេកទេសបង្រៀន និងរៀនតាមមុខវិជ្ជាបានត្រឹមត្រូវ អត្រាសិស្សបោះបង់ការសិក្សាទាបជាង ឬស្មើថ្នាក់ជាតិ បរិស្ថានសិក្សាកុមារមេត្រី អត្រាសិស្សឡើងថ្នាក់ស្មើ ឬខ្ពស់ជាងថ្នាក់ជាតិ សិស្សមានសមត្ថភាពសមស្របនឹងកម្រិតថ្នាក់ ការផ្គត់ផ្គង់ និងថែរក្សាសៀវភៅសិក្សាគោល។

**១១. ការអភិវឌ្ឍយុវជន** សំដៅលើរចនាសម្ព័ន្ធ និងកិច្ចដំណើរការក្រុមប្រឹក្សាកុមារ យុវជន ក្លឹបសិក្សាយ៉ាងតិចមួយក្នុងកងកាយរឹទ្ធិមួយ សកម្មភាពសង្គមដែលជំរុញ ឬសមស្រប ឬដឹកនាំ សកម្មភាពបណ្តុះបណ្តាលកុមារ យុវជន និងការបូកសរុប និងវាយតម្លៃការងារក្រុមប្រឹក្សាកុមារ យុវជន។

## ២.៣. តួនាទីគ្រូបង្រៀនក្នុងការដឹកនាំមេរៀនភាសាខ្មែរ

យោងតាមឯកសារបំប៉នសមត្ថភាពគ្រូបង្រៀននៅអនុវិទ្យាល័យ មុខវិជ្ជាភាសាខ្មែរឆ្នាំ២០១០ របស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ នៃក្រសួងអប់រំ យុវជន និង កីឡាបានបង្ហាញថា ក្នុងការបង្រៀនភាសាខ្មែរ គ្រូមានតួនាទី៥យ៉ាង៖

### ២.៣.១. អ្នកជំរុញទឹកចិត្តសិស្ស

រាល់សកម្មភាពរបស់មនុស្សស្ថិតនៅក្រោមការជំរុញប្រានៃឆន្ទៈ។ ឆន្ទៈជំរុញមនុស្សឱ្យធ្វើសកម្មភាពគ្រប់បែបយ៉ាង។ គ្រូត្រូវមានបំណិនក្នុងការជំរុញឆន្ទៈសិស្ស ពោលគឺមុនផ្តើមមេរៀន ក៏ដូចជាក្នុងពេលដឹកនាំមេរៀន គ្រូត្រូវចេះទាក់ទាញអារម្មណ៍របស់សិស្សឱ្យចូលរួមក្នុងការសិក្សាដោយប្រើប្រាស់ល្បិចប្លែកៗដូចជា :

- បង្ហាញពាក្យសម្តី ឬខ្លឹមសារប្លែកៗដើម្បីពញ្ញាក់ស្មារតីរបស់សិស្ស
- ប្រើឥរិយាបថ ឬអាកប្បកិរិយាថ្លុកកំប្លែងខ្លះៗ
- ទទួលស្គាល់ និងលើកទឹកចិត្តសិស្សដែលបានចូលរួមផ្តល់យោបល់
- ផ្លាស់ប្តូរសកម្មភាពបង្រៀនប្លែកៗ ល្បិចបង្រៀនទៅតាមស្ថានភាពសិស្ស (ស្ថានភាពចិត្តសាស្ត្រ និងចំណេះដឹង)
- ប្រែប្រួលពាក្យសម្តី និងអាកប្បកិរិយាជានិច្ចកាល ចៀសវាងភាពឯកសព្ទ (សំឡេងដដែលៗ) និងធ្វើតាមទម្លាប់ដដែលៗ។

### ២.៣.២. អ្នកផ្សព្វផ្សាយ

ការផ្សព្វផ្សាយនៅទីនេះ សំដៅទៅលើការផ្ដល់ពត៌មាន ឬចំណេះដឹងថ្មីឱ្យសិស្ស ទាំងផ្នែកចំណេះដឹងមូលដ្ឋាន ក៏ដូចជាបច្ចេកទេសបង្រៀនថ្មីៗ។ ការផ្សព្វផ្សាយអាចអនុវត្តបានតាមរយៈ

- ការបង្ហាញ ការជ្រើសរើស និងការបញ្ចូលខ្លឹមសារថ្មីៗក្នុងមេរៀនដើម្បីធ្វើឱ្យសិស្សស្វែងយល់ជាមួយគ្នា ដើម្បីឱ្យការផ្សព្វផ្សាយមានប្រសិទ្ធភាព គ្រូត្រូវពន្យល់ និងបកស្រាយបញ្ជាក់បន្ថែមឱ្យបានច្បាស់លាស់ផងដែរ
- ការពង្រីកខ្លឹមសារឱ្យបានទូលំទូលាយដោយធ្វើការពិនិត្យឡើងវិញជានិច្ចកាលលើខ្លឹមសារដែលធ្លាប់ប្រើប្រាស់ ព្រមទាំងរកខ្លឹមសារថ្មីៗមកបកស្រាយបន្ថែមទៀត
- ការជ្រើសរើសព័ត៌មាន ឬចំណេះដឹងដែលត្រូវផ្សព្វផ្សាយ(តើត្រូវផ្សព្វផ្សាយ ឬបង្រៀនអ្វីខ្លះ? នៅពេលណា? ចំនួនប៉ុន្មាន?)។

### ២.៣.៣. អ្នកផ្ដើមគំនិត និងដឹកនាំ

តួនាទីដឹកនាំតម្រូវឱ្យគ្រូមានគំនិតផ្ដួចផ្ដើមច្នៃប្រតិដ្ឋកម្រិតខ្ពស់ក្នុងការដឹកនាំសកម្មភាពថ្នាក់រៀនពិសេសគឺដឹកនាំសកម្មភាពសិស្សានុសិស្សតាមក្រុមនីមួយៗ។

សកម្មភាពដឹកនាំនេះរួមមាន៖

- ការជ្រើសរើសប្រធានបទ ពាក្យ ឃ្លា ល្បះដែលសិស្សពិបាកយល់ ហើយធ្វើការសម្របសម្រួលឱ្យមានភាពងាយស្រួល ដែលសិស្សអាចចាប់បានដោយមិនអនុវត្តរឹងស្ងួក
- ការបង្កើតបទបញ្ជា ឬសេចក្ដីណែនាំគួបផ្សំ និងការបកស្រាយឱ្យសិស្សយល់បាន
- ការជួយពន្យល់ និងឆ្លើយសំណួរក្នុងករណីសិស្សជួបការលំបាកពេលពិភាក្សាក្នុងក្រុម
- ការស្រាវជ្រាវ និងច្នៃប្រតិដ្ឋគំរូល្អៗសម្រាប់សិស្សអនុវត្តតាម
- ការផ្ដល់កិច្ចការ ឬលំហាត់ល្អៗសម្រាប់សិស្សអនុវត្ត
- ការរៀបចំក្រុមសិស្សសម្រាប់ធ្វើការងារតាមលទ្ធភាពជាក់ស្ដែងនៃមេរៀន និងថ្នាក់រៀន
- ការធ្វើកំណែតម្រូវក្នុងករណីចាំបាច់

### ២.៣.៤. ការវិភាគ

ការវិភាគមានសារៈសំខាន់បំផុត មុននឹងធ្វើសកម្មភាព គ្រូបង្រៀនត្រូវវិភាគឱ្យបានគ្រប់ជ្រុងជ្រោយនូវហេតុការណ៍ ដើម្បីធ្វើសម្មតិកម្មឱ្យបានសមរម្យ និងមានប្រសិទ្ធភាព។ តើគ្រូត្រូវវិភាគលើអ្វីខ្លះ?

- នៅពេលមានហេតុការណ៍មិនធម្មតា ឬចៃដន្យកើតឡើងក្នុងពេលកំពុងដឹកនាំមេរៀន គ្រូមិនគួរធ្វើប្រតិកម្មភ្លាមៗឡើយ ផ្ទុយទៅវិញគាត់ត្រូវធ្វើវិភាគឱ្យបានល្អិតល្អន់គ្រប់ជ្រុងជ្រោយ ដើម្បីរកមូលហេតុ ចំណុចខ្លាំង ចំណុចខ្សោយ និងផលវិបាកនៃហេតុការណ៍នោះ ទើបធ្វើប្រតិកម្មជាក្រោយ
- ស្ថិតចំពោះមុខប្រធានបទ ឬបញ្ញត្តិអ្វីមួយ មុននឹងយកទៅបង្រៀនសិស្ស គ្រូត្រូវវិភាគអត្ថន័យ ខ្លឹមសារ ពិនិត្យពីតម្រូវការរបស់សិស្ស (តើយល់ខ្លឹមសារអត្ថន័យហើយឬនៅ? តើមានប្រយោជន៍ឬទេ? តើសិស្សត្រូវការអ្វីខ្លះ? តើគួរផ្តល់អ្វីខ្លះ?...)
- ពេលសិស្សផ្តល់ចម្លើយ ឬពេលពិភាក្សា គ្រូត្រូវវិភាគឱ្យឃើញនូវចំណុចល្អ កំហុសឆ្គងរបស់សិស្ស ដើម្បីធ្វើការវាយតម្លៃ និងការកែលម្អឱ្យបានទាន់ពេលវេលា។

### ២.៣.៥. ការកែតម្រូវ

ក្រោយពីវិភាគរកឃើញចំណុចខ្លាំង ចំណុចខ្សោយណាមួយ គ្រូត្រូវធ្វើកំណែលម្អជាបន្ទាន់។ តើត្រូវធ្វើកំណែលម្អអ្វីខ្លះ? គ្រូគប្បីកែ :

- កំហុសរួមដែលតែងតែកើតមានឡើងជាញឹកញាប់ តាមរយៈការបង្ហាញអ្វីៗដែលត្រឹមត្រូវ
- កំហុសសិស្សម្នាក់ៗធ្វើខុស(កំណែជាបុគ្គល) តាមរយៈការពន្យល់បកស្រាយបំភ្លឺឱ្យសិស្សបានយល់(កែលម្អការខុសឆ្គងក្នុងចម្លើយរបស់សិស្ស)
- កំហុសដែលកើតមានឡើងចំពោះមុខក្នុងពេលកំពុងបង្រៀន
- កំហុសខ្លះដែលអាចផ្តល់ផលវិបាកទៅថ្ងៃក្រោយ ក្នុងករណីដែលសិស្សយល់មិនបានច្បាស់ ឬរៀនមិនបានល្អ ឧទាហរណ៍ ៖ កំហុសខ្ចីខ្ចាក្នុងការសរសេរ និងការនិយាយស្តី...។

## ២.៤. ការអនុវត្តតាមដំណាក់កាលផ្សេងៗនៃការបង្រៀនមុខវិជ្ជាភាសាខ្មែរ

ជាធម្មតា ការបង្រៀនភាសាខ្មែរ គ្រូអនុវត្តជា៥ដំណាក់កាល (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ នៃក្រសួងអប់រំ យុវជន និង កីឡា, ២០១០)។ ដំណាក់កាលទាំង៥នោះមានដូចជា ៖

### ២.៤.១. ការរៀបចំ

មុននឹងបង្រៀនមេរៀនមួយ គ្រូត្រូវរកឱ្យឃើញថា តើក្នុងមេរៀន(ប្រធានបទ) សិស្សបានចេះអ្វីខ្លះ(បុរេពុទ្ធិ)? ហើយអ្វីខ្លះដែលសិស្សមិនទាន់ចេះ? តើគួរបង្រៀនអ្វីខ្លះដល់សិស្ស?

ក្រៅពីរកឃើញចំណុចទាំងនេះហើយ គ្រូត្រូវដកស្រង់ខ្លឹមសារថ្មី បញ្ញត្តិថ្មីយកមករៀបចំដើម្បីបង្រៀនសិស្សទៅតាមលទ្ធភាពជាក់ស្តែងនៃថ្នាក់នីមួយៗ និងទៅតាមវិសេសភាពសិស្សក្នុងថ្នាក់ផង។

គួរកត់សម្គាល់ថា ក្នុងដំណាក់កាលត្រៀមនេះ គ្រូគប្បីស្រាវជ្រាវប្រភពឯកសារ និងសម្ភារៈឧបទេសឱ្យបានសមស្របដើម្បីធានាប្រសិទ្ធភាពនៃការបង្រៀន។ ជាមួយគ្នានេះ គ្រូគប្បីរៀបចំកិច្ចតែងការបង្រៀនឱ្យមានភាពពេញលេញ និងងាយស្រួលអនុវត្តផងដែរ។

### ២.៤.២. ការដឹកនាំមេរៀន

គ្រូគប្បីតាំងខ្លួនជាអ្នកបង្កសកម្មភាព និងជំរុញសិស្សឱ្យធ្វើសកម្មភាពដោយខ្លួនឯងផ្ទាល់។ គ្រូមិនត្រូវតាំងខ្លួនជា"មេនៃថ្នាក់រៀនមួយ" ដោយគិតតែពីនិយាយ បង្គាប់បញ្ជា គំរាមកំហែងឱ្យសិស្សស្តាប់បង្គាប់ និងអនុវត្តតាមឡើយ។

ដើម្បីបង្កបរិយាកាសឱ្យបានល្អ គ្រូត្រូវប្រកាន់ឥរិយាបថដូចខាងក្រោម :

- ឈ្លាសវៃក្នុងការរៀបចំសិស្ស ធ្វើឱ្យសិស្សធ្វើសកម្មភាពទៅតាមលទ្ធភាពផ្ទាល់ខ្លួនដើម្បីស្វែងយល់ខ្លឹមសារដោយខ្លួនឯង
- ត្រូវប្រើប្រាស់ភាសាទន់ភ្លន់ ឃ្លាល្បះងាយស្តាប់ និងច្បាស់លាស់ មិនគំរោះគំរើយ មិនគំរាមកំហែងពេលនិយាយទៅកេសិស្ស
- ត្រូវនិយាយ ឬអនុវត្តសកម្មភាពជាជំហានៗ ពីងាយស្រួលទៅពិបាក ពីរូបីទៅអរូបី

- ត្រូវចេះណែនាំសិស្សឱ្យប្រើប្រាស់សម្ភារៈឧបទេសប្រកបដោយភាពច្នៃប្រតិដ្ឋ ទៅតាមគុណភាពសម្ភារៈដែលត្រូវប្រើប្រាស់( ទំហំ ពណ៌សម្បុរ...)
- ត្រូវសរសេរពាក្យថ្មី ពាក្យគន្លឹះ បញ្ញត្តិថ្មីៗលើក្តារខៀនក្នុងករណីចាំបាច់
- ត្រូវលើកទឹកចិត្តរាល់ការងារប្រឹងប្រែងរបស់សិស្ស ដោយចេះសម្រួលពាក្យ សម្របសម្រួលចម្លើយ និងពង្រីអត្ថន័យបន្ថែមឱ្យពេញលេញ នៅពេលសិស្សគ្មានលទ្ធភាពឆ្លើយ គ្រូត្រូវជួយពន្យល់បន្ថែម ឬកែលម្អសំណួររបស់ខ្លួនឡើងវិញ
- ត្រូវប្រើសំណួរឱ្យបានសមស្របតាមកម្រិតយល់ដឹងរបស់សិស្ស និងខ្លឹមសារដែលត្រូវបង្រៀនដោយគោរពទៅតាក្បួនចំណាត់ថ្នាក់នៃសំណួរផង។

**២.៤.៣. ការប្រតិបត្តិ**

ពេលបង្រៀនមេរៀនចប់ ដើម្បីពង្រឹងចំណេះដឹង និងទ្រឹស្តី គ្រូត្រូវរៀបចំសកម្មភាពឱ្យសិស្សអនុវត្តជាក់ស្តែង។ ការប្រតិបត្តិនេះអាចជាបុគ្គល ឬជាក្រុមតូចៗ ដើម្បីឱ្យសិស្សមានលទ្ធភាពពង្រឹងស្មារតីជួយគ្នាទៅវិញទៅមកនៅពេលពិភាក្សាក្នុងក្រុម។

**២.៤.៤. វាយតម្លៃ**

វង្វាយតម្លៃគឺជាដំណាក់កាលសំខាន់មួយនៃការបង្រៀន។ អ្វីៗទាំងអស់នឹងរកឃើញនៅពេលវាយតម្លៃ។ លទ្ធផលនៃការបង្រៀនរបស់គ្រូ លទ្ធផលនៃការរៀនរបស់សិស្ស ការសម្រេច ឬមិនសម្រេចតាមវត្ថុបំណងនៃមេរៀនដែលកំណត់ពីមុន នឹងឃើញច្បាស់ក្រោយពីវង្វាយតម្លៃ។

ក្នុងការវាយតម្លៃគ្រូអាចៈ

- ពិនិត្យកិច្ចការសិស្សជាសមូហភាព( គ្រូ និងសិស្សពិនិត្យកិច្ចការជាមួយគ្នា)
- ឱ្យសិស្សពិនិត្យកិច្ចការរបស់គាត់ជាមួយសិស្សឯទៀត( សិស្សពិនិត្យកិច្ចការគ្នាទៅវិញទៅមក)
- ប្រើប្រាស់របៀបវាយតម្លៃប្លែកៗតាមរយៈធ្វើតេស្តដោយប្រើប្រាស់
    - សំណួរពហុជ្រើសរើស

- សំណួរផ្ទុផ្ទង
- សំណួរបំពេញល្បះ
- សំណួរល្បងប្រាជ្ញា។

### ២.៤.៥. ការពង្រីកចំណេះដឹង

នេះជាការផ្តល់ឱកាសឱ្យសិស្សមានលទ្ធភាពគិត និងប្រើប្រាស់បញ្ញត្តិដែលទើបទទួលបាននៅក្នុងជីវភាព ឬយកទៅប្រើប្រាស់ក្នុងជីវភាព និងមុខវិជ្ជាផ្សេងៗទៀត។

ក្នុងការអនុវត្តដំណាក់កាលពង្រីកចំណេះដឹង គ្រូអាចៈ

- ផ្តល់លំហាត់អនុវត្តដែលមានខ្លឹមសារថ្មី និងទូលាយជាងមេរៀនមុន
- ប្រើប្រាស់សំណួរផ្ទាល់មាត់ដោយបញ្ចូលខ្លឹមសារថ្មីខ្លះៗ។

## ២.៥. សម្ភារៈឧបទេសសម្រាប់ដំណើរការបង្រៀន និងរៀនភាសាខ្មែរ

សម្ភារៈឧបទេសគឺជាធនធានទាំងឡាយដែលគ្រូ និងសិស្សយកមកប្រើប្រាស់សម្រាប់ការបង្រៀន និងរៀន ដើម្បីឱ្យខ្លឹមសារមេរៀនកាន់តែជាក់លាក់ច្បាស់លាស់ ងាយយល់ ងាយចាប់បាន ដែលអាចសម្រេចនូវវត្ថុបំណងមេរៀន។ សម្ភារៈត្រូវមានទាំងគ្រូទាំងសិស្ស ហើយសម្ភារៈឧបទេសមានលក្ខណៈទូលំទូលាយ និងច្រើនប្រភេទណាស់។ **(ចៅ លិន, ២០១១)**

ចំពោះការបង្រៀន និងរៀនភាសាខ្មែរ សម្ភារៈឧបទេសដែលបម្រើឱ្យដំណើរការ ត្រូវបានចែកចេញជាបួនប្រភេទដូចជាៈ

- **សម្ភារៈរូបី** ជាសម្ភារៈទាំងឡាយណាដែលទាមទារឱ្យគ្រូបង្រៀនចេះប្រើប្រាស់វត្ថុពិត ជាក់ស្តែង រុក្ខជាតិ សត្វ ធម្មជាតិ វត្ថុសិល្បៈ ទីកន្លែង បេតិកភណ្ឌ សម្ភារៈប្រពៃណី ទស្សនីយភាពពិត ដូចជាចម្រៀង វីដេអូជាដើម ដោយគ្រូចេះដឹកនាំសិស្សចុះសិក្សា សង្កេត ស្រាវជ្រាវ រិះរក ពន្យល់បង្ហាញជាក់ស្តែង ដើម្បីបង្កើនការយល់ដឹងអំពីបញ្ញត្តិ ខ្លឹមសារមេរៀនដែលទាក់ទងនឹងប្រធានបទ។ សម្ភារៈរូបី សំដៅលើប្រភេទសម្ភារៈដូចជា កែវ ថូ គ្រឿងអលង្ការ សម្ភារៈប្រើប្រាស់បុរាណ

ចម្លាក់ សិលាចារឹក ទីកន្លែងជាក់ស្តែង។ល។

- **សម្ភារៈពាក់កណ្តាលរូបី** សម្ភារៈរូបី ឬលក្ខណៈជាក់ស្តែងមិនអាចឆ្លើយតបទៅនឹងស្ថានភាពនៃការសិក្សាតាមតំបន់នានាបានឡើយ គឺទាមទារឱ្យគ្រូបង្រៀនចេះផលិត និងប្រើប្រាស់សម្ភារៈពាក់កណ្តាលរូបី។ សម្ភារៈពាក់កណ្តាលរូបី សំដៅលើប្រភេទសម្ភារៈមួយចំនួនដែលផលិតតំណាងពីរូបពិត វត្ថុពិត ឬទីកន្លែងពិត។ សម្ភារៈទាំងនេះមានដូចជា រូបថត ឬរូបភាពមនុស្ស សត្វ វត្ថុ រុក្ខជាតិ ធម្មជាតិ ទីកន្លែងដែលគ្រូផលិតឡើងសម្រាប់ជាជំនួយក្នុងការរៀន និងបង្រៀន។
- **សម្ភារៈអរូបី** ជាសម្ភារៈដែលមិនមែនជាក់ស្តែង មិនមែនជារូបថត ឬរូបភាពសម្គាល់ច្បាស់លាស់នោះទេ វាគ្រាន់តែត្រូវគាត់លើកមកជាតំណាង សន្មត ឬជាគ្រឿងសម្គាល់ឈ្មោះមនុស្ស សត្វ វត្ថុ រុក្ខជាតិ ទីកន្លែង...។ សម្ភារៈទាំងនោះ គ្រូផលិត ឬលើកឡើងជាជំនួយក្នុងការបង្រៀន និងរៀន។
- **សម្ភារៈអេឡិកត្រូនិក** ក្រៅពីសម្ភារៈសំខាន់ៗទាំងបីប្រភេទខាងលើនេះ លោកគ្រូ អ្នកគ្រូ ក៏ត្រូវមានសមត្ថភាពក្នុងការប្រើប្រាស់សម្ភារៈអេឡិកត្រូនិកទំនើបៗមួយចំនួនដូចជា៖
    - ➢ សម្ភារៈអេឡិកត្រូនិកសម្រាប់ធ្វើបទបង្ហាញ ជាសម្ភារៈដែលទាក់ទាញអារម្មណ៍អ្នកសិក្សាឱ្យចូលរួមបានជាច្រើន។ សម្ភារៈនេះទាមទារឱ្យមានការរៀបចំ និងចងក្រងខ្លឹមសារមេរៀន ឬប្រធានបទនានាតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានទំនើប ដោយប្រើប្រាស់កម្មវិធីមួយចំនួនរបស់កុំព្យូទ័រ ម៉ាស៊ីនបញ្ចាំង ព្រមទាំងសម្ភារៈមួយចំនួនទៀតដូចជា ឌីវីឌី ម៉ាញ៉េ វីដេអូជាដើម។
    - ➢ សម្ភារៈអេឡិកត្រូនិកសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ និងផ្តល់ព័ត៌មាន ជាសម្ភារៈដូចជាកុំព្យូទ័រ អ៊ីនធើណែត ហ្វេសប៊ុក តេឡេក្រាម អ៊ីមែល យូធូប និងទូរស័ព្ទជាដើម។ សម្ភារៈទាំងនេះទាមទារឱ្យគ្រូបង្រៀនត្រូវមានសមត្ថភាពគ្រប់គ្រាន់ និងចំណេះដឹងពីបច្ចេកវិទ្យាព័ត៌មានឱ្យបានច្បាស់លាស់។ ដើម្បីប្រើប្រាស់សម្ភារៈទាំងនេះឱ្យមានប្រសិទ្ធភាពទាមទារឱ្យគ្រូបង្រៀនត្រូវមានចំណេះដឹងផ្នែកភាសាបរទេសថែមទៀត។ នៅក្នុងកម្មវិធីទាំងនេះយើងអាចមើលឃើញឯកសារជាច្រើនជុំវិញពិភពលោក និងការចែករំលែក។ ការសិក្សា

ស្រាវជ្រាវអាចប្រើប្រាស់សម្ភារៈទាំងនេះ ធ្វើឱ្យគ្រូបង្រៀនមានការយល់ដឹងកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាពបន្ថែមទៀត។

## ២.៦. វិធីសាស្ត្របង្រៀនភាសាខ្មែរផ្នែកអំណាន

មុខវិជ្ជាភាសាខ្មែរមានលំនាំនៃការបង្រៀនប្លែកគ្នាអាស្រ័យទៅតាមសមត្ថភាពគោលនៃមេរៀន។ យោងតាមឯកសារបំប៉នសមត្ថភាពគ្រូបង្រៀននៅអនុវិទ្យាល័យមុខវិជ្ជាភាសាខ្មែរឆ្នាំ២០១០ របស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ នៃក្រសួងអប់រំ យុវជន និង កីឡាបានបង្ហាញថា ក្នុងការបង្រៀនភាសាខ្មែរផ្នែកអំណានមានលក្ខណៈដូចតទៅ៖

### ២.៦.១. លំនាំនៃការបង្រៀនសមត្ថភាពអាន(អំណាន)

- **ត្រៀមអំណាន**

១. បំផុសចំណេះដឹងតាមរយៈ

ក. សំណួរលើចំណងជើង

ខ. សំណួរលើរូបភាព

២. ឱ្យសិស្សស្វែងយល់ពាក្យពិបាកដោយប្រើ :

ក. ទីសេចក្តី

ខ. បទានុក្រមផ្នែកខាងក្រោយសៀវភៅសិស្ស

៣. រំលឹកបញ្ញត្តិដែលមានទំនាក់ទំនង ឬប្រើក្នុងអំណាននេះ

៤. ឱ្យសិស្សសាកល្បងទាយមើលថា តើអត្ថបទនេះនិយាយពីអ្វី?

- **អំណាន**

១. ឱ្យសិស្សអានសំណួរត្រិះរិះដែលស្ថិតនៅខាងក្រោយអត្ថបទ

២. ឱ្យសិស្សអានអត្ថបទដោយស្ងៀមស្ងាត់(យកល្អគ្រូគួរឱ្យសិស្សអាននៅផ្ទះ) តែក្នុងករណីនេះលោកគ្រូ អ្នកគ្រូគួរលៃពេលពន្យល់សិស្សឱ្យចប់ត្រឹមការត្រៀមអំណាននៅចុងម៉ោងមុន ហើយឱ្យ

សិស្សអានអត្ថបទនៅផ្ទះរៀងៗខ្លួនឱ្យហើយ។

៣. ឱ្យសិស្សឆ្លើយនូវសំណួរត្រិះរិះដែលមាននៅក្នុងសៀវភៅសិស្ស។ បើសិស្សមិនអាចឆ្លើយនូវសំណួរណាមួយ លោកគ្រូ អ្នកគ្រូជ្រើសរើសផ្នែកណាមួយឱ្យសិស្សអានវគ្គដែលមានចម្លើយនៅក្នុងអត្ថបទឡើងវិញ ឬសួរសំណួរលម្អិតបន្ថែម។

❖ **ក្រោយអំណាន**

ក. លោកគ្រូអ្នកគ្រូគួរជ្រើសរើសផ្នែកណាមួយឱ្យសិស្សអាន ដោយប្រើប្រាស់សំនៀងត្រឹមត្រូវ

ខ. លោកគ្រូអ្នកគ្រូគួរជ្រើសរើសផ្នែកណាមួយនៃវគ្គសន្ទនាឱ្យសិស្សដើរតួ

គ. ចែកសិស្សជាក្រុម :

- ក្រុមសិស្សពូកែខាងគំនូរ គូរផ្នែកណាមួយរបស់រឿង
- ក្រុមសិស្សពូកែតែងកាព្យ ឱ្យលើកជាពាក្យស្លោក ឬសរសេរជាកាព្យពីវគ្គទាក់ទងទៅនឹងខ្លឹមសារអត្ថបទ
- ក្រុមសិស្សខ្លះសង្ខេបអត្ថបទអំណានឡើងវិញ
- ក្រុមសិស្សឯទៀតរកបទចម្រៀង ឬអត្ថបទកាព្យណាមួយដែលទាក់ទងនឹងប្រធានបទ។

**២.៦.២. សង្ខេបប្លង់វិធីបង្រៀនអំណាន**

ប្លង់សង្ខេបនៃវិធីបង្រៀនអំណានមាន វត្ថុបំណង សម្ភារៈឧបទេស និងដំណើរការបង្រៀន (គរុនិស្សិតអក្សរសាស្ត្រខ្មែរជំនាន់ទី២០ក្រុម៤ , ២០១៥)។

**ក.វត្ថុបំណង**

- ចំណេះដឹង(វិជ្ជាសម្បទា)
- បំណិន(បំណិនសម្បទា)
- ឥរិយាបថ(ចរិយាសម្បទា)

**ខ. សម្ភារៈឧបទេស**

- សៀវភៅសិស្សទំព័រ...បោះពុម្ពលើកទី...ឆ្នាំ...

– សៀវភៅគ្រូទំព័រ...បោះពុម្ពលើកទី...ឆ្នាំ...

– ...................................................................

**គ. ដំណើរការបង្រៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| – គ្រូជាអ្នកណែនាំ | **ជំហានទី៣**<br>(មេរៀនប្រចាំថ្ងៃ)<br>ក.ត្រៀមអំណាន<br>– ពន្យល់ចំណងជើង(ពាក្យ ឃ្លា និង ពង្រីកន័យ)<br>– សិក្សារូបភាព(អត្ថន័យរូបភាព)<br>– សិក្សាពាក្យគន្លឹះ។<br>ខ. អំណាន<br>– ឱ្យសិស្សអានសំណួរត្រិះរិះ រួចអានអត្ថបទ ហើយឆ្លើយសំណួរត្រិះរិះ។ ក្នុងករណីសិស្សឆ្លើយមិនត្រូវ គ្រូត្រូវបង្ហាញឃ្លា ឬបន្ទាត់ណាដែលជាចម្លើយ។ គ្រូត្រូវសរសេរចម្លើយរបស់សិស្សលើក្ដារ ខៀន។<br>គ. ក្រោយអំណាន(ការងារក្រុម) | – សិស្សជាអ្នកចូលរួម |

| | | |
|---|---|---|
| | សង្ខេបលើខ្លឹមសារអត្ថបទអំណាន តែងកំណាព្យ ការសម្តែងតួ...។ | |

## ២.៧. ការរៀបចំសិស្សក្នុងដំណើរការបង្រៀន និងរៀនអំណាន

រាល់ការបង្រៀន និងរៀន លោកគ្រូ អ្នកគ្រូអាចរៀបចំសកម្មភាពសិស្សជាក្រុមធំ ក្រុមតូច ដៃគូ បុគ្គលទៅតាមលទ្ធភាពជាក់ស្តែង និងខ្លឹមសារមេរៀននីមួយៗដែលបានកំណត់ទុក។ យើងអាចចែករូបភាពសិស្សជាបួនផ្នែកដូចខាងក្រោម (ឯកសារបំប៉នសមត្ថភាពគ្រូបង្រៀននៅអនុវិទ្យាល័យមុខវិជ្ជាភាសាខ្មែរ,២០១០)៖

### ២.៧.១. ការងារក្រុមធំ(ក្រុមថ្នាក់ទាំងមូល)

ជាធម្មតា ការងារនេះតម្រូវឱ្យសិស្សក្នុងថ្នាក់ទាំងអស់ធ្វើសកម្មភាពរួមគ្នា។ ការងារនេះគ្រូច្រើនប្រើនៅពេលពន្យល់បញ្ញត្តិ លើកឧទាហរណ៍ និទានរឿង បង្ហាញរូបភាព ដោះស្រាយលំហាត់ គំរូសំណួរពង្រឹងចំណេះដឹង...។

### ២.៧.២. ការងារក្រុមតូច

ក្នុងពេលបង្រៀន លោកគ្រូអ្នកគ្រូគប្បីរៀបចំសិស្សជាក្រុមតូចៗដែលក្រុមនីមួយៗមានសិស្ស០៤នាក់ទៅ០៦នាក់ និងមានសិស្សពូកែលាយនឹងសិស្សខ្សោយ។

មុននឹងដាក់កិច្ចការទៅតាមក្រុមនីមួយៗ លោកគ្រូអ្នកគ្រូត្រូវកំណត់ពេលវេលា និងពន្យល់ណែនាំឱ្យច្បាស់មុននឹងក្រុមសិស្សចាប់ផ្តើមធ្វើកិច្ចការ។

ការរៀបចំក្រុមតូចៗនេះមានច្រើនវិធីទៅតាមខ្លឹមសារ ឬកិច្ចការដែលគ្រូដាក់ឱ្យដូវជា៖

- រៀបចំក្រុមទៅតាមប្រភេទសិស្សពូកែ សិស្សខ្សោយ ដើម្បីគ្រូងាយស្រួលជួយក្រុមសិស្សខ្សោយ
- រៀបចំក្រុមសិស្សប្រុស សិស្សស្រីដើម្បីឱ្យសិស្សងាយស្រួលក្នុងការពិភាក្សាបញ្ចេញចំណេះដឹងមានស្រាប់ដោយមិនខ្មាសអៀន

- រៀបចំសិស្សពូកែលាយនឹងសិស្សខ្សោយដើម្បីឱ្យសិស្សពូកែជួយសិស្សខ្សោយ សិស្សពូកែពង្រឹងសមត្ថភាពខ្លួនឯង សិស្សខ្សោយពិនិត្យសង្កេត និងធ្វើតាមសិស្សពូកែ សិស្សខ្សោយអាចពង្រឹង និងអភិវឌ្ឍសមត្ថភាពខ្លួនឯង ហើយឈានទៅពូកែដែរ
- រៀបចំសិស្សទៅតាមប្រធានបទ កិច្ចការដែលត្រូវបានកំណត់ដោយឱ្យសិស្សជ្រើសរើសក្រុមទៅតាមប្រធានបទទាំងនោះ តែគ្រូត្រូវកំណត់ក្រុមនីមួយៗឱ្យមានសិស្សពូកែយ៉ាងតិចបំផុត
- រៀបចំក្រុមសិស្សទៅតាមការស្ម័គ្រចិត្តដែលគាត់ចូលចិត្ត និងជ្រើសរើសដោយខ្លួនឯងដោយគ្រូដាក់កិច្ចការដូចៗគ្នាទៅតាមក្រុមនីមួយៗ តែគ្រូក៏ត្រូវកំណត់ឱ្យមានសិស្សពូកែតាមក្រុមនីមួយៗដែរ
- រៀបចំក្រុមសិស្សធ្វើកិច្ចការលើប្រធានបទផ្សេងៗគ្នា ក្រោយមកគ្រូបំបែកក្រុមធ្វើកិច្ចការមុន ហើយបង្កើតជាក្រុមតូចៗផ្សេងពីមុនដោយសមាជិកក្រុមនីមួយៗបំបែកទៅគ្រប់ក្រុមដែលបង្កើតថ្មី។

### ២.៧.៣. ការងារជាដៃគូ

ជាទូទៅ ការងារជាដៃគូ គ្រូបែងចែកឱ្យសិស្សចាប់ដៃគូពីរៗសម្រាប់ធ្វើសកម្មភាព។ ពេលខ្លះ គ្រូផ្ដល់លទ្ធភាពឱ្យសិស្សជ្រើសរើសដៃគូដោយសេរី និងស្ម័គ្រចិត្ត។ ការងារជាដៃគូ សិស្សច្រើនធ្វើសកម្មភាពនៅពេលដើរតួសន្ទនាដូរកិច្ចការគ្នាកែ សួរឆ្លើយ និយាយព្រឹត្តិការណ៍ ហេតុការណ៍ និទានរឿងឱ្យដៃគូស្ដាប់។

### ២.៧.៤. ការងារបុគ្គល

ជាការងាររបស់សិស្សម្នាក់ៗដែលគ្រូបានប្រគល់ឱ្យ ហើយសិស្សត្រូវបំពេញកិច្ចការដោយខ្លួនឯងផ្ទាល់ ដោយប្រើប្រាស់ចំណេះដឹងដែលបានពីគ្រូ គ្រួសារ និងសហគមន៍ ហើយជឿជាក់លើសមត្ថភាពចំណេះដឹងរបស់ខ្លួន។ ការងារបុគ្គលនេះ សិស្សច្រើនធ្វើនៅពេលអានអត្ថបទ ធ្វើកិច្ចការដែលគ្រូដាក់ឱ្យសង្កេតរូបភាព វត្ថុពិតជាក់ស្ដែង បញ្ចេញយោបល់ឆ្លើយនឹងសំណួរ គូររូប...។

សរុបមក សិស្សមានលទ្ធភាពធ្វើសកម្មភាពសិក្សាគ្រប់ទីកន្លែង និងមានទំនាក់ទំនងជាមួយមនុស្សគ្រប់ប្រភេទ គ្រប់វិស័យ។

## ២.៨. បំណែងចែកខ្លឹមសារ និងម៉ោងសិក្សាអំណាននៅមធ្យមសិក្សាបឋមភូមិ

យោងតាមតារាងឧបសម្ព័ន្ធបំណែងចែកខ្លឹមសារ និងម៉ោងសិក្សាមុខវិជ្ជាភាសាខ្មែរនៅមធ្យមសិក្សាបឋមភូមិថ្នាក់ទី៧ ទី៨ និងទី៩ របស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៦បានបង្ហាញពីខ្លឹមសារ និងម៉ោងសិក្សាអំណាននៅមធ្យមសិក្សាបឋមភូមិដូចតទៅ៖

| ថ្នាក់ទី | ចំនួនអំណានដែលត្រូវសិក្សា | រយៈពេលសរុបនៃអំណានដែលត្រូវសិក្សា | រយៈពេលសរុបនៃមេរៀន |
|---|---|---|---|
| ៧ | ២៦ | ៥៤ម៉ោង | ២២៦ម៉ោង |
| ៨ | ២៤ | ៥៦ម៉ោង | ២២៨ម៉ោង |
| ៩ | ២៦ | ៥៦ម៉ោង | ២២៨ម៉ោង |

យោងតាមផលធៀបរយៈពេលសរុបនៃអំណានដែលត្រូវសិក្សា និងចំនួនអំណានសរុបដែលត្រូវសិក្សាក្នុងតារាងខាងលើយើងឃើញថា ជាមធ្យមមេរៀនអំណានមួយត្រូវសិក្សាក្នុងរយៈពេល២ម៉ោង។

## ២.៩. ការរៀបចំមេរៀន ឬកិច្ចតែងការបង្រៀន

មានការលើកឡើងផ្សេងគ្នាចំពោះការរៀបចំមេរៀន និងការធ្វើកិច្ចតែងការ។ Spatt, M, Pulvemess, A., & Williams, M.(2005) បានលើកឡើងថា ការធ្វើកិច្ចតែងការគឺជាការកត់ចំណាំដែលជួយគ្រូបានគិតទុកជាមុននូវវត្ថុបំណងមេរៀន ដំណើរការបង្រៀន និងរបៀបដែលគ្រូត្រូវបង្រៀនមេរៀនមួយ និងជាផ្លូវសម្រាប់ជួយគ្រូបានរៀបចំនូវសម្ភារៈសម្រាប់ជួយសិស្សក្នុងការធ្វើសកម្មភាព។ នៅក្នុងថ្នាក់រៀនភាសាអង់គ្លេសមួយ ដើម្បីឱ្យសកម្មភាពសិក្សារបស់សិស្សទទួលបានលទ្ធផលល្អ ពួកគាត់ត្រូវការអនុវត្តសកម្មភាពជាច្រើន ដូច្នេះនៅពេលធ្វើកិច្ចតែងការបង្រៀន គ្រូត្រូវតែដាក់បញ្ចូលសកម្មភាព

ឱ្យបានច្រើន សម្រាប់សិស្សអនុវត្ត (Woodward, 2001)។ Celce-Murcia (2001) និយាយថា កិច្ចតែងការបង្រៀនដែលល្អគឺត្រូវទាមទារឱ្យសកម្មភាពទាំងអស់មានទំនាក់ទំនងគ្នា ផ្សេងៗពីគ្នា និង មានភាពបត់បែន។ គ្រូបង្រៀនភាសាខ្មែរត្រូវតែយល់ និងដឹងពីគោលការណ៍នៃការបង្រៀន និងរៀនភាសាខ្មែរ ព្រមទាំងតម្រូវការរបស់សិស្ស និងស្ថាប័នរបស់ខ្លួន។ គ្រូបង្រៀនត្រូវចាំទុកក្នុងចិត្តជានិច្ចនូវវត្ថុបំណងមេរៀន នៅពេលរៀបចំសកម្មភាពបង្រៀនមេរៀននីមួយៗ។

## ២.១០. បរិមាណសិស្សក្នុងថ្នាក់

លោក Blatchford (2003) បានពន្យល់ថា មានយុទ្ធសាស្ត្រជាច្រើនសម្រាប់លើកកម្ពស់ស្តង់ដាអប់រំ។ អ្នកសិក្សារូបនេះក៏បានពន្យល់បន្ថែមទៀតថា ថ្នាក់តូចអាចនាំឱ្យគុណភាពការរៀន និងបង្រៀនប្រសើរឡើង។ នៅពេលដែលគាត់បានចុះទៅអង្កេតនៅថ្នាក់រៀនមួយដែលមានសិស្ស១៥នាក់ឃើញថា ស្ថានភាពទូទៅនៅក្នុងថ្នាក់រៀននោះគឺវិជ្ជមាន ដោយគ្រូតែងតែនិយាយលេងសើចជាមួយសិស្ស និង មានទំនាក់ទំនងផ្ទាល់ខ្លួនជាច្រើន។ ក្រៅពីនេះ អ្នកស្រាវជ្រាវក៏ចុះទៅអង្កេតថ្នាក់រៀនធំផ្សេងទៀតដែលមានសិស្សចំនួន៣០នាក់ ហើយបានរកឃើញថា រវាងថ្នាក់ទាំងពីរមានសភាពខុសគ្នាគួរឱ្យកត់សម្គាល់។ នៅក្នុងថ្នាក់តូចគ្រូបានចំណាយពេលតិចតួចនៅក្នុងការគ្រប់គ្រងថ្នាក់រៀន ប៉ុន្តែនៅក្នុងថ្នាក់ធំគ្រូព្យាយាមចំណាយពេលជាច្រើនដើម្បីទាញចំណាប់អារម្មណ៍សិស្សលើការងារដែលគ្រូដាក់។

ម្យ៉ាងទៀត នៅក្នុងថ្នាក់តូចគ្រូស្គាល់សិស្សម្នាក់ៗច្បាស់ ដែលអាចឱ្យគ្រូជួយសិស្សក្នុងការសិក្សាបានងាយស្រួល (Blatchford, 2003)។ Hong Thi Nguyen, Wendy Warren & Heather Fehring, (2014) បានធ្វើការសិក្សាមួយទៀត គឺបានធ្វើការអង្កេតថ្នាក់មួយចំនួននៅក្នុងសាលា HUTECH ក្នុងប្រទេសវៀតណាម ដែលក្នុងនោះថ្នាក់រៀនភាគច្រើនមានសិស្សច្រើនចាប់ពី៤០នាក់ ដល់ទៅ៥០នាក់។ ជាលទ្ធផលរកឃើញថា ក្នុងថ្នាក់រៀនដែលមានសិស្សតិចគឺការសិក្សារបស់សិស្សទទួលបានលទ្ធផលជាង ពីព្រោះនៅក្នុងថ្នាក់រៀនតូចគ្រូងាយស្រួលគ្រប់គ្រងរាល់សកម្មភាពទាំងឡាយដែលគ្រូដាក់ឱ្យសិស្សអនុវត្ត និងធ្វើ។

## ២.១១. ការលើកទឹកចិត្ត

ការលើកទឹកចិត្តត្រូវបានគាត់ចាត់ទុកថា ជាកត្តាដ៏ចម្បងមួយដែលជះឥទ្ធពលដល់ល្បឿន និងកម្រិតនៃការសិក្សារបស់សិស្ស (Gardner, 2006) ។ ជាឧទាហរណ៍Gardner (2006) បានលើកឡើងថា សិស្សដែលមានកម្រិតនៃការលើកទឹកចិត្តខ្ពស់តែងតែធ្វើបានល្អជាងសិស្សដែលមានកម្រិតការលើកទឹកចិត្តទាបជាង។ ប្រសិនបើសិស្សមានការលើកទឹកចិត្ត ពួកគាត់មានហេតុផលគ្រប់គ្រាន់ក្នុងការចូលរួមរាល់សកម្មភាពទាំងអស់។ (Elliot, S., Kratochil, T,. & Cook, J., 2000) មើលឃើញថាការលើទឹកចិត្តជាសភាពលក្ខណៈខាងក្នុងដែលជំរុញឱ្យយើងធ្វើសកម្មភាព ដើម្បីឆ្ពោះទៅរកគោលដៅដែលខ្លួនចង់បាន និងជំរុញឱ្យយើងព្យាយាមស្វែងរកចំណេះដឹង និងជំនាញថ្មីៗ។ ចំណែក (Petty, 1998) យល់ឃើញថា ប្រសិនបើសិស្សមិនចង់រៀន ប្រសិទ្ធភាពនៃការសិក្សារបស់ពួកគាត់ប្រាកដជាយឺត ឬក៏គ្មានទទួលបានលទ្ធផលអ្វីទាំងអស់។ ដូច្នេះ បើគ្រូបង្រៀនដឹងពីវិធីនៃការលើកទឹកចិត្តសិស្ស គ្រូអាចជួយបង្កើនការសិក្សារបស់សិស្សឱ្យប្រសើរជាងមុន។

(Stern, 2001)ដែលបានសិក្សាពីអាកប្បកិរិយារបស់មនុស្សបានបញ្ជាក់ថា ឥរិយាបទចំពោះប្រទេស ក្រុម និងភាសាបានជួយយើងយល់ថាហេតុអ្វីបានជាមនុស្សមួយចំនួនមានកម្លាំងចិត្តក្នុងការរៀនជាមួយអ្នកដទៃ។ បន្ទាប់ពីការធ្វើអង្កេតថ្នាក់រៀនមួយ អ្នកស្រាវជ្រាវបានជោគជ័យក្នុងការសិក្សា។ (Shalaway, 2005) លើកឡើងថា ការរៀបចំមេរៀនសម្រាប់បង្រៀនដោយផ្អែកលើចំណាប់អារម្មណ៍របស់សិស្សតែមួយមុខ គឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ គ្រូបង្រៀនចាំបាច់ត្រូវតែជួយជំរុញសិស្សឱ្យយល់ពីតម្លៃនៃការទទួលបាននូវជំនាញប្រើប្រាស់នោះថែមទៀត។ អ្នកសិក្សាជាច្រើនបានបែងចែកការជំរុញទឹកចិត្តជាពីរប្រភេទ៖ ខាងក្នុង និង ខាងក្រៅ និងបានឱ្យនិយមន័យចំពោះការជំរុញទឹកចិត្តខាងក្នុងថា ជាការធ្វើអ្វីមួយដោយសារការចូលចិត្តរបស់បុគ្គលនោះផ្ទាល់តែម្តង។ រីឯការជំរុញទឹកចិត្តខាងក្រៅថាកើតឡើងនៅពេលដែលមានកម្លាំងជំរុញពីខាងក្រៅអាចជាសម្ភារៈ ឬដើម្បីសម្រេចគោលដៅណាមួយ។ ជាទូទៅ សិស្សដែលមានកម្លាំងជំរុញខាងក្នុង ច្រើនទទួលបានលទ្ធផលនៃការសិក្សាខ្ពស់ជាងសិស្សដែលមានតែកម្លាំងជំរុញពីខាងក្រៅ (Ryan, M, R. & Deci, E, L., 2000)។

# ជំពូក ៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវស្ដីពី«**ស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ**» មានគោលបំណងឈ្វេងយល់ពីស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅកម្រិតមធ្យមសិក្សាបឋមភូមិ ព្រមទាំងរកឱ្យឃើញពីបញ្ហាប្រឈមដែលទាក់ទងនឹងការបង្រៀន និងរៀនសមត្ថភាពអំណានកម្រិតនៅមធ្យមសិក្សាបឋមភូមិ។ វិធីសាស្ត្រនៃការស្រាវជ្រាវគឺអនុវត្តតាមបែបបរិមាណវិស័យ។

## ៣.១. គម្រោងវិភាគ

អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរបីប្រភេទតាមបែបបរិមាណវិស័យ ដោយបន្សុំជាមួយសំណួរស្រាវជ្រាវទាំងពីរនៃប្រធានបទដែលលើកយកមកសិក្សា។ ស្របតាមផែនការនៃការបណ្ដុះបណ្ដាលបរិញ្ញាបត្រជាន់ខ្ពស់ និងកម្មវិធីសិក្សា ព្រមទាំងនិក្ខេបបទមានរយៈពេលកំណត់ច្បាស់លាស់ អ្នកសិក្សាស្រាវជ្រាវអាចបញ្ចប់ការសរសេរនិក្ខេបបទ និងឡើងការពារកិច្ចការស្រាវជ្រាវនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២០ តាមផែនការគ្រោងទុក។ ការចុះប្រមូលទិន្នន័យគឺធ្វើនៅសាលាមធ្យមសិក្សាបឋមភូមិក្នុងស្រុកសំរោង ខេត្តតាកែវ និងក្រុមគោលដៅបំពេញទិន្នន័យកម្រងសំណួរមានបីប្រភេទ គឺគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និងសិស្សានុសិស្ស។

## ៣.២. ការប្រមូលទិន្នន័យ

ក្រោយពីបានឆ្លងយោបល់ក្នុងក្របខ័ណ្ឌបច្ចេកទេសជាមួយគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរងរួចមក អ្នកសិក្សាស្រាវជ្រាវបានរៀបចំកម្រងសំណួរដើម្បីចុះប្រមូលទិន្នន័យ។ ក្នុងពេលចុះប្រមូលទិន្នន័យ អ្នកសិក្សាស្រាវជ្រាវមានការសហការល្អជាមួយគណៈគ្រប់គ្រងសាលារៀនដើម្បីចែកកម្រងសំណួរទៅតាមការជ្រើសរើសចំនួនសំណាកដែលបានគ្រោងទុក។

អ្នកសិក្សាស្រាវជ្រាវបានចុះទៅជួបនាយកសាលានីមួយៗដើម្បីជូនលិខិតឧទ្ទេសនាម និងសុំការអនុញ្ញាតជួបក្រុមគោលដៅដើម្បីផ្តល់កម្រងសំណួរដល់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និងសិស្សានុសិស្សដោយមានកំណត់ពេលវេលាជាក់លាក់។ ដោយស្ថិតក្នុងសម័យកូវីត ១៩ ការប្រមូលទិន្នន័យដោយបំពេញក្នុងកម្រងសំណួរ អ្នកសិក្សាស្រាវជ្រាវបានណែនាំឱ្យមានការក្សាគម្លាតសង្គមតាមការណែនាំរបស់ក្រសួងសុខាភិបាល។ ក្នុងការចុះប្រមូលទិន្នន័យ គឺបានប្រើប្រាស់ពេលវេលាសរុបចំនួន៣០ថ្ងៃ គិតចាប់ពីថ្ងៃចាប់ផ្តើម រហូតដល់ថ្ងៃដែលបានទទួលកម្រងសំណួរទាំងអស់ពីគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និងសិស្សានុសិស្ស។

## ៣.៣. ឧបករណ៍ស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរចំនួនបីប្រភេទក្នុងការចុះប្រមូលទិន្នន័យតាមបែបបរិមាណវិស័យពីគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និងសិស្សានុសិស្ស ដោយផ្អែកលើទ្រឹស្តីពាក់ព័ន្ធនានាដូចជា ការអនុវត្តកម្មវិធីសិក្សាវិធីសាស្ត្របង្រៀនអំណាន លំនាំនៃការបង្រៀនអំណាន ការប្រើប្រាស់សម្ភារៈឧបទេស ការវាយតម្លៃលទ្ធផលសិក្សាជាដើម។

### ៣.៣.១. កម្រិតចង្អុលបង្ហាញ

កម្រិតចង្អុលបង្ហាញគឺប្រើប្រាស់ក្នុងទម្រង់កម្រងសំណួរ ដើម្បីប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធទៅតាមការឆ្លើយតបក្នុងកម្រិតតួលេខជាក់លាក់។ កម្រិតចង្អុលបង្ហាញអាចបំពេញដោយគូសផ្ទាល់នៅលើកម្រងសំណួរ។ ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ គឺមានកម្រិតចង្អុលបង្ហាញចំនួន៥កម្រិត។

ការវាយតម្លៃស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តតាកែវ គឺប្រើតម្លៃបកស្រាយអត្ថន័យតម្លៃមធ្យមរបស់កម្រងសំណួរតាមបែបអត្រាវង្វាយតម្លៃកំណត់ពិន្ទុលើតម្លៃមធ្យមគឺយកតាមលំនាំកម្រិតពិន្ទុរបស់ Wannatawee , Worakham, & Panya (2017) ដោយបង្ហាញលទ្ធផល ដូចខាងក្រោម៖

Mean=៤.៥១ - ៥.០០ មានន័យថា កម្រិតស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិ នៅកម្រិតខ្ពស់បំផុត

Mean=៣.៥១ - ៤.៥០ មានន័យថា កម្រិតស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិ នៅកម្រិតខ្ពស់

Mean=២.៥១ - ៣.៥០ មានន័យថា កម្រិតស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិ នៅកម្រិតមធ្យម

Mean=១.៥១ - ២.៥០ មានន័យថា កម្រិតស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិ នៅកម្រិតទាប

Mean=១.០០ - ១.៥០ មានន័យថា កម្រិតស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិ នៅកម្រិតទាបបំផុត។

ម្យ៉ាងទៀត នេះជាការវិភាគទស្សនៈគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និងសិស្សានុសិស្សលើស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិ ដោយប្រើតម្លៃមធ្យមភាគ (mean) និងគម្លាតស្តង់ដា (standard deviation)។

**៣.៣.២. គម្រូងសំណួរ**

គោលបំណងនៃកម្រងសំណួរនេះ គឺដើម្បីសិក្សាឈ្វេងយល់ពីដំណើរការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅកម្រិតមធ្យមសិក្សាបឋមភូមិ និងរកឱ្យឃើញពីបញ្ហាប្រឈមដែលទាក់ទងនឹងការបង្រៀន និងរៀនសមត្ថភាពអំណាននៅកម្រិតមធ្យមសិក្សាបឋមភូមិ។ ទិន្នន័យដែលប្រមូលបាន គឺប្រើសម្រាប់តែការសិក្សាស្រាវជ្រាវនេះប៉ុណ្ណោះ។

### ៣.៣.២.១. កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលារៀន

នៅក្នុងកម្រងសំណួរនេះ អ្នកសិក្សាស្រាវជ្រាវបានរៀបចំជា៣ផ្នែកធំៗ។ ផ្នែកទី១ ព័ត៌មានទូទៅ ចែកចេញជា៧ចំណុចគឺ ទាក់ទងនឹង ១.តួនាទី ២.ទីកន្លែងបម្រើការងារ ៣.ភេទ ៤.អាយុ ៥.កម្រិតវប្បធម៌ ៦.បទពិសោធន៍ការងារ និង ៧.មុខវិជ្ជាឯកទេស។ ផ្នែកទី២ ដំណើរការនៃការបង្រៀន និងរៀនអំណាន ដែលចែកចេញជាពីរគឺ ១. ការអនុវត្តកម្មវិធីសិក្សា និង ២. វិធីសាស្ត្រ និងសកម្មភាពបង្រៀន និងរៀនអំណាន។ ផ្នែកទី៣ សំណូមពរ ឬមតិយោបល់បន្ថែម ទាក់ទងនឹងបញ្ហាលំបាក និងយុទ្ធសាស្ត្រដោះស្រាយបញ្ហាក្នុងដំណើរការបង្រៀន និងរៀនអំណាន។

### ៣.៣.២.២. កម្រងសំណួរសម្រាប់គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម

នៅក្នុងកម្រងសំណួរនេះ អ្នកសិក្សាស្រាវជ្រាវបានរៀបចំជា៣ផ្នែកធំៗ៖ ផ្នែកទី១ អំពីព័ត៌មានទូទៅរបស់គ្រូ ចែកចេញជា៧ចំណុចគឺ ១.ទីកន្លែងបម្រើការងារ ២.ភេទ ៣.អាយុ ៤.ក្របខ័ណ្ឌ ៥.កម្រិតវប្បធម៌ ៦.បទពិសោធន៍ការងារ និងទី៧.កម្រិតថ្នាក់ដែលត្រូវបង្រៀន ។ ផ្នែកទី២ ដំណើរការនៃការបង្រៀន និងរៀនអំណាន ដែលបែងចែកចេញជា៣ចំណុចសំខាន់ៗគឺ ១.ការអនុវត្តកម្មវិធីសិក្សា ២.វិធីសាស្ត្រ និងសកម្មភាពបង្រៀន និងរៀនអំណាន និងទី៣.ការវាយតម្លៃលទ្ធផល។ ផ្នែកទី៣ បញ្ហាប្រឈមនានាទាក់ទងនឹងការបង្រៀន និងរៀនអំណាន។

### ៣.៣.២.៣. កម្រងសំណួរសម្រាប់សិស្សានុសិស្ស

នៅក្នុងកម្រងសំណួរនេះ អ្នកសិក្សាស្រាវជ្រាវរៀបចំជា៣ផ្នែកធំៗ៖ ផ្នែកទី១ ព័ត៌មានទូទៅរបស់សិស្ស ចែកចេញជា៤ចំណុចគឺ ១.ឈ្មោះសាលា ២.កម្រិតថ្នាក់ ៣.ភេទ និងទី៤.អាយុ។ ផ្នែកទី២ ដំណើរការនៃការបង្រៀន និងរៀនអំណាន ដែលបែងចែកចេញជា៣ចំណុចសំខាន់ៗគឺ ១.ព័ត៌មានអំពីការសិក្សា ២.វិធីសាស្ត្រ និងសកម្មភាពបង្រៀន និងរៀនអំណាន និងទី៣.ការវាយតម្លៃលទ្ធផល។ ផ្នែកទី៣ បញ្ហាប្រឈមនានាទាក់ទងនឹងការបង្រៀន និងរៀនអំណាន។

## ៣.៤. ការជ្រើសរើសភាគសំណាក

ចំពោះការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រក្នុងការជ្រើសរើសសំណាកតាមគោលបំណងក្នុងការប្រមូលទិន្នន័យ ដោយដៅតែភាគសំណាកណាដែលអ្នកស្រាវជ្រាវយល់ថា ភាគសំណាកនោះអាចផ្តល់នូវទិន្នន័យបានជាក់លាក់ ច្បាស់លាស់ និងអាចឆ្លើយតបទៅនឹងប្រធានបទនេះបាន។ ដូច្នេះ ភាគសំណាកដែលអ្នកសិក្សាស្រាវជ្រាវយល់ថា អាចទទួលបានទិន្នន័យដែលអាចជឿទុកចិត្តបាននោះមានបីប្រភេទរួមមាន៖ គណៈគ្រប់គ្រងសាលារៀនចំនួន ០៦នាក់ គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គមចំនួន ១៨នាក់ និងសិស្សានុសិស្សថ្នាក់ទី ៧ ដល់ទី៩ ចំនួន ១៨០នាក់។

**ក្រុមគោលដៅទី១៖** ការសម្ភាសន៍ផ្ទាល់ និងឱ្យលោកនាយក ឬនាយិកា នាយករង ឬនាយិការង បំពេញកម្រងសំណួរបន្ថែម។ មូលហេតុដែលជ្រើសរើសនាយក ឬនាយិកា នាយករង ឬនាយិការងក្នុងការផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវនេះ ពីព្រោះតែពួកគាត់ក៏ជាអ្នកដែលអាចផ្តល់ព័ត៌មានទូទៅស្តីពីការបង្រៀន ការរៀនរបស់លោកគ្រូ អ្នកគ្រូ និងសិស្ស ជាពិសេសនាយកគឺជាអ្នកធ្វើអធិការកិច្ចផ្ទាល់នៅសាលា ក្នុងការតាមដានការអនុវត្តការងារប្រចាំថ្ងៃរបស់លោកគ្រូ អ្នកគ្រូ។

**ក្រុមគោលដៅទី២** គឺគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម ត្រូវបានសុំធ្វើការសម្ភាសន៍ និងសុំឱ្យបំពេញកម្រងសំណួរ ពីព្រោះពួកគាត់ខ្លះជាអ្នកបង្រៀនអំណានផ្ទាល់ ច្បាស់ណាស់ពួកគាត់ប្រាកដជាផ្តល់ព័ត៌មានបានល្អប្រសើរ។

**ក្រុមគោលដៅទី៣** គឺការជ្រើសរើសយកសិស្សចំនួន ១៨០ នាក់ មកធ្វើជាសំណាក និងសុំឱ្យបំពេញកម្រងសំណួរ ព្រោះតែពួកគាត់ជាអ្នកសិក្សាអំណាន ជាមួយគ្រូរបស់ពួកគាត់ផ្ទាល់។ ហេតុដូច្នេះ ពួកគាត់ប្រាកដជាអាចផ្តល់ព័ត៌មានបន្ថែមទាក់ទងនឹងប្រធានបទបានគ្រប់ជ្រុងជ្រោយសម្រាប់ឱ្យអ្នកសិក្សាស្រាវ ជ្រាវយកមកធ្វើការវិភាគ ។

តារាង៣.១. ចំនួនភាគសំណាក

| ឈ្មោះសាលា | គណៈគ្រប់គ្រង | គ្រូបង្រៀន | សិស្សានុសិស្ស |
| --- | --- | --- | --- |
| អនុវិ.ដំរីយកទឹក | ២ នាក់ | ៦ នាក់ | ៦០ នាក់ |
| អនុវិ.ថ្មដា | ២ នាក់ | ៦ នាក់ | ៦០ នាក់ |
| អនុវិ.អង្គជុំ | ២ នាក់ | ៦ នាក់ | ៦០ នាក់ |
| **សរុបរួម** | **៦** នាក់ | **១៨** នាក់ | **១៨០** នាក់ |

## ៣.៥. ការវិភាគទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រវិភាគទិន្នន័យតាមបែបបរិមាណវិស័យ។ ទិន្នន័យបែបបរិមាណវិស័យដែលប្រមូលបានពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាដំបូងត្រូវវិភាគដាច់ដោយឡែកទៅតាមប្រភេទភាគសំណាកនីមួយៗ ( គណៈគ្រប់គ្រងសាលា គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និងសិស្ស)។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវសំយោគបញ្ចូលគ្នាដោយផ្តោតសំខាន់ទៅការអនុវត្តកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន សកម្មភាពបង្រៀន និងរៀនអំណានជាក់ស្តែង ការប្រើប្រាស់សម្ភារៈបង្រៀន និងសម្ភារៈឧបទេស ការវាយតម្លៃលទ្ធផល បញ្ហាប្រឈមនានាទាក់ទងនឹងការបង្រៀន និងរៀនអំណាន។ ដើម្បីឆ្លើយតបនឹងចំណុចទាំងនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីកម្មវិធី SPSS សម្រាប់ស្វែងរកចំនួនមធ្យម និងគម្លាតស្តង់ដា និង Microsoft Excel សម្រាប់សង់តារាង និងបកស្រាយព័ត៌មាន។ បន្ទាប់មក អ្នកសិក្សាស្រាវជ្រាវបានលើកជាសំណូមពរចំពោះចំណុចខ្វះខាត និងកែលម្អចំណុចខ្វះខាតទាំងនោះឱ្យបានប្រសើរឡើង។

# ជំពូក ៤

# លទ្ធផល និងការពិភាក្សា

# ជំពូកទី៤

# លទ្ធផល និងការពិភាក្សា

## ៤.១. លទ្ធផលលើកម្រងសំណួររបស់គណៈគ្រប់គ្រងសាលារៀន

### ៤.១.១. ដំណើរការនៃការបង្រៀន និងរៀនអំណាន

ក. ការអនុវត្តកម្មវិធីសិក្សា

តារាង៤.១៖លទ្ធផលលើកម្រងសំណួររបស់គណៈគ្រប់គ្រងសាលារៀនទាក់ទងនឹងការអនុវត្តកម្មវិធីសិក្សា

| ល.រ | ការពិនិត្យតាមដាន និងកែលម្អការបង្រៀនអំណាន | តម្លៃមធ្យម | គម្លាត ស្តង់ដា | កម្រិត វាស់វែង |
|---|---|---|---|---|
| ១ | បានណែនាំគ្រូធ្វើបំណែងចែកកម្មវិធីសិក្សា មុខវិជ្ជាភាសាខ្មែរបានច្បាស់លាស់តាមចំនួនម៉ោងកំណត់ របស់ក្រសួងអប់រំ(៦ម៉/១សប្តាហ៍) | 4.67 | 0.51 | ខ្ពស់បំផុត |
| ២ | បានពិនិត្យ និងចុះហត្ថលេខាលើបំណែងចែកកម្មវិធីសិក្សា ធ្វើតាមក្រុមមុខវិជ្ជាភាសាខ្មែរ(ផ្នែកអំណាន) | 4.33 | 0.51 | ខ្ពស់ |
| ៣ | បានត្រួតពិនិត្យកិច្ចតែងការបង្រៀនអំណានតាមកម្រិតថ្នាក់ជាប្រចាំ | 4.50 | 0.54 | ខ្ពស់ |
| ៤ | បានពិនិត្យតាមដានលើដំណើរការបង្រៀនរបស់គ្រូជាប្រចាំ | 4.50 | 0.54 | ខ្ពស់ |
| ៥ | បានផ្តល់មតិយោបល់ កែលម្អក្នុងការធ្វើថ្នាក់និទស្សន៍មុខវិជ្ជាភាសាខ្មែរ | 4.17 | 0.40 | ខ្ពស់ |
| ៦ | បានផ្តល់វគ្គបំប៉នសមត្ថភាពដល់គ្រូបង្រៀនអំណាន | 3.00 | 1.09 | មធ្យម |
| ៧ | បានពិនិត្យការប្រើប្រាស់សៀវភៅសិក្សាគោលភាសាខ្មែរគ្រប់កម្រិត | 4.00 | 0.00 | ខ្ពស់ |
| ៨ | បានចូលរួមការប្រជុំក្រុមបច្ចេកទេស ពិនិត្យតាមដាន និងកែលម្អការ អនុវត្តការបង្រៀនអំណានភាសាខ្មែរទៀងទាត់ | 4.17 | 0.40 | ខ្ពស់ |
| ៩ | បានបែងចែកកាលវិភាគឱ្យមានម៉ោងបណ្ណាល័យដើម្បីលើកកម្ពស់គុណភាពបង្រៀនអំណាន | 2.00 | 0.00 | ទាប |
| ១០ | រៀបចំបណ្ណាល័យ (ផ្តល់សម្ភារៈល្បែងសិក្សា)ឱ្យក្លាយជាទីមេត្រីសម្រាប់ការអាន | 3.67 | 0.81 | ខ្ពស់ |
| ១១ | បង្កើតឱ្យមានក្លឹបសិក្សាដើម្បីឱ្យសិស្សពូកែជួយសិស្សខ្សោយ(អំណាន) | 2.33 | 0.51 | ទាប |
| | **សរុបជាមធ្យម** | **3.75** | **0.48** | **ខ្ពស់** |

តាមតារាង៤.១ បានបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវទាក់ទងនឹងការពិនិត្យតាមដាន និងកែលម្អលើការអនុវត្តកម្មវិធីសិក្សា ដោយគណៈគ្រប់គ្រងសាលារៀនផ្តោតការយកចិត្តទុកដាក់ខ្លាំងលើការណែនាំគ្រូធ្វើបំណែងចែកកម្មវិធីសិក្សា ការត្រួតពិនិត្យកិច្ចតែងការបង្រៀន ការពិនិត្យតាមដានលើដំណើរការបង្រៀន ការពិនិត្យ និងចុះហត្ថលេខាលើបំណែងចែកកម្មវិធីសិក្សា ការធ្វើថ្នាក់និទស្សន៍មុខវិជ្ជាភាសាខ្មែរការប្រជុំក្រុមបច្ចេកទេស ការពិនិត្យការប្រើប្រាស់សៀវភៅសិក្សាគោលភាសាខ្មែរ និងការរៀបចំបណ្ណាល័យ(តម្លៃមធ្យម=៤.៦៧- ៣.៦៧)។

ចំណែកឯការពិនិត្យតាមដាន និងកែលម្អលើការអនុវត្តកម្មវិធីសិក្សាមួយចំនួនដែលគណៈគ្រប់គ្រងសាលារៀនយល់ថា មិនសូវអនុវត្តមានដូចជា ការបំប៉នសមត្ថភាពគ្រូបង្រៀនអំណាន ការបង្កើតឱ្យមានក្លឹបសិក្សាជួយសិស្សខ្សោយ(អំណាន) និងការបែងចែកកាលវិភាគឱ្យមានម៉ោងបណ្ណាល័យ(តម្លៃមធ្យម=៣.០០- ២.០០)។

ជាលទ្ធផលរួម គណៈគ្រប់គ្រងសាលារៀនបានយល់ស្របថា ការអនុវត្តកម្មវិធីសិក្សាគឺស្ថិតក្នុងកម្រិតខ្ពស់(តម្លៃមធ្យម=៣.៧៥)។

### ខ. វិធីសាស្ត្របង្រៀន

**តារាង៤.២៖ លទ្ធផលលើកម្រងសំណួររបស់គណៈគ្រប់គ្រងសាលារៀនទាក់ទងនឹងវិធីសាស្ត្របង្រៀន**

| ល.រ | លោកគ្រូ អ្នកគ្រូបង្រៀនអំណានភាសាខ្មែរបាន ៖ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | បង្ហាញវត្ថុបំណងមេរៀនអំណានច្បាស់លាស់ | 4.17 | 0.40 | ខ្ពស់ |
| ២ | ផ្តល់ការការណែនាំដល់សិស្ស លើចំណេះដឹងស្តីពីអំណាន | 4.17 | 0.40 | ខ្ពស់ |
| ៣ | វិធីសាស្ត្របង្រៀនអំណានមាននិយាមច្បាស់លាស់ | 4.17 | 0.40 | ខ្ពស់ |
| ៤ | ឱ្យសិស្សអានស្ងាត់ ខ្សឹប | 3.67 | 0.81 | ខ្ពស់ |
| ៥ | ឱ្យសិស្សអានឮៗម្នាក់ឯង ឬដៃគូ | 4.17 | 0.40 | ខ្ពស់ |
| ៦ | ឱ្យសិស្សអានឮ អានបណ្តាក់គ្នា(ជាក្រុមតូច) | 4.00 | 0.00 | ខ្ពស់ |
| ៧ | ឱ្យសិស្សអានស្នាប(សម្រាប់សិស្សពិការ) | 1.37 | 0.40 | ទាបបំផុត |

| | | | | |
|---|---|---|---|---|
| ៨ | គ្រូបានអានជាគំរូក្នុងការបញ្ចេញសំឡេងតាមអក្ខរក្រម | 3.83 | 0.40 | ខ្ពស់ |
| ៩ | ផ្លាស់ប្តូរវិធីសាស្ត្រ ដោយប្រើល្បែងសិក្សាពីអំណាន | 1.93 | 0.98 | ទាប |
| | **សរុបជាមធ្យម** | **3.49** | **0.47** | **មធ្យម** |

តាមតារាង៤.២ បានបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវទាក់ទងនឹងការពិនិត្យតាមដានលើវិធីសាស្ត្របង្រៀនអំណានរបស់គ្រូ ដោយគណៈគ្រប់គ្រងសាលារៀនផ្តោតការយកចិត្តទុកដាក់ និងយល់ស្របខ្លាំងលើវិធីសាស្ត្របង្រៀនអំណានរបស់គ្រូមួយចំនួនដូចជា ការបង្ហាញវត្ថុបំណងមេរៀនអំណាន ការណែនាំសិស្សលើចំណេះដឹងស្តីពីអំណាន វិធីសាស្ត្របង្រៀនអំណានមាននិយាមច្បាស់លាស់ ការឱ្យសិស្សអានឮៗម្នាក់ឯង ឬដៃគូ អានបណ្តាក់គ្នា អានស្ងាត់ ខ្សឹប ការអានជាគំរូដល់សិស្ស(តម្លៃមធ្យម= ៤.១៧- ៣.៦៧)។

ចំណែកឯវិធីសាស្ត្របង្រៀនអំណានរបស់គ្រូមួយចំនួនដែលគណៈគ្រប់គ្រងសាលារៀនយល់ថាមិនសូវអនុវត្តមានដូចជា ការផ្លាស់ប្តូរវិធីសាស្ត្រដោយប្រើល្បែងសិក្សាពីអំណាន ការឱ្យសិស្សអានស្ទាប (តម្លៃមធ្យម=១.៩៣- ១.៣៧)។

ជាលទ្ធផលរួម គណៈគ្រប់គ្រងសាលារៀនបានយល់ស្របថា ការអនុវត្តវិធីសាស្ត្របង្រៀនអំណានរបស់គ្រូ ស្ថិតក្នុងកម្រិតមធ្យម(តម្លៃមធ្យម=៣.៤៩)។

**គ. ដំណើរការ និងសកម្មភាពបង្រៀនអំណានភាសាខ្មែរ(អនុវត្តជាក់ស្តែង)**

**តារាង៤.៣ ៖ លទ្ធផលលើកម្រងសំណួររបស់គណៈគ្រប់គ្រងសាលារៀន ទាក់ទងនឹងការបង្រៀនអំណានជាក់ស្តែង**

| ល.រ | **លោកគ្រូ អ្នកគ្រូបង្រៀនអំណានភាសាខ្មែរបាន ៖** | តម្លៃមធ្យម | គម្លាត-ស្តង់ដា | កម្រិត-វាស់វែង |
|---|---|---|---|---|
| ១ | គ្រូបង្រៀនប្រើប្រាស់កិច្ចតែងការបង្រៀនអំណានថ្មីជាប្រចាំ | 3.17 | 0.98 | មធ្យម |
| ២ | គ្រូបង្រៀនមានទំនួលខុសត្រូវក្នុងការគោរពពេលវេលា | 4.00 | 0.00 | ខ្ពស់ |
| ៣ | គ្រូបង្រៀនបានស្រាវជ្រាវបន្ថែមលើការបង្រៀនអំណានភាសាខ្មែរ | 3.83 | 0.40 | ខ្ពស់ |

| | | | | |
|---|---|---|---|---|
| ៤ | គ្រូបង្រៀនអំណានមានសមត្ថភាពសបស្របតាមកម្រិតវិជ្ជាជីវៈ | 4.50 | 0.54 | ខ្ពស់ |
| ៥ | ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សមានតម្លាភាព និងផ្ទៀងផ្ទាត់ច្បាស់លាស់ | 4.17 | 0.40 | ខ្ពស់ |
| ៦ | មានការបែងចែកម៉ោងអំណាននៅបណ្ណាល័យ | 2.00 | 0.00 | ទាប |
| ៧ | សិស្សចូលចិត្តលើការសិក្សាអំណានភាសាខ្មែរ | 4.00 | 0.00 | ខ្ពស់ |
| ៨ | គ្រូបានណែនាំសិស្សឱ្យរៀនអានបន្ថែមនៅក្រៅម៉ោងសិក្សា នៅក្នុងបណ្ណាល័យ | 4.00 | 0.63 | ខ្ពស់ |
| ៩ | គ្រូបានបង្រៀនអំណានស្របតាមកម្មវិធីសិក្សា | 4.17 | 0.40 | ខ្ពស់ |
| ១០ | មានការរៀបចំទិវាជាតិអំណាន | 2.33 | 0.51 | ទាប |
| | **សរុបជាមធ្យម** | **3.61** | **0.39** | **ខ្ពស់** |

តាមតារាង៤.៣ បានបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវទាក់ទងនឹងការពិនិត្យតាមដានលើដំណើរការ និងសកម្មភាពបង្រៀនអំណានភាសាខ្មែរ(អនុវត្តជាក់ស្តែង)របស់គ្រូ ដោយគណៈគ្រប់គ្រងសាលារៀនផ្តោតការយកចិត្តទុកដាក់ និងយល់ស្របខ្លាំងលើដំណើរការ និងសកម្មភាពបង្រៀនអំណានភាសាខ្មែរមួយចំនួនរបស់គ្រូដូចជា គ្រូបង្រៀនមានសមត្ថភាពស្របតាមកម្រិតវិជ្ជាជីវៈ ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ការបង្រៀនស្របតាមកម្មវិធីសិក្សា ទំនួលខុសត្រូវរបស់គ្រូ ចំណូលចិត្តរបស់សិស្សលើការសិក្សាអំណាន ការណែនាំសិស្សឱ្យអានបន្ថែម ការស្រាវជ្រាវបន្ថែមលើការបង្រៀនអំណាន (តម្លៃមធ្យម=៤.៥០- ៣.៨៣)។

ចំណែកឯដំណើរការ និងសកម្មភាពបង្រៀនអំណានភាសាខ្មែរ(អនុវត្តជាក់ស្តែង) ដែលគណៈគ្រប់គ្រងសាលារៀនយល់ថា មិនសូវអនុវត្តមានដូចជា ការរៀបចំទិវាជាតិអំណាន ការបែងចែកម៉ោងអំណាននៅបណ្ណាល័យ(តម្លៃមធ្យម=២.៣៣- ២.០០)។

ជាលទ្ធផលរួម គណៈគ្រប់គ្រងសាលារៀនបានយល់ស្របថា ដំណើរការ និងសកម្មភាពបង្រៀនអំណានភាសាខ្មែរ(អនុវត្តជាក់ស្តែង) របស់គ្រូស្ថិតក្នុងកម្រិតខ្ពស់(តម្លៃមធ្យម=៣.៦១)។

### ៤.១.២. ទស្សនៈគណៈគ្រប់គ្រងសាលាចំពោះបញ្ហាប្រឈមក្នុងការជំរុញអំណាន

យោងតាមលទ្ធផលនៃការឆ្លើយសំណួរបើក និងការសម្ភាសបន្ថែមពីគណៈគ្រប់គ្រងសាលារៀនក្នុងក្របខ័ណ្ឌស្រាវជ្រាវនេះ គឺពួកគាត់បានបញ្ជាក់ថា សាលារបស់គាត់នៅមានបញ្ហាប្រឈមខ្លះៗទាំងពេលវេលា បច្ចេកទេស ការចូលរួមសហការរបស់អ្នកពាក់ព័ន្ធក្នុងការជំរុញសកម្មភាពអំណានភាសាខ្មែររបស់សិស្សនៅកម្រិតមធ្យមសិក្សាបឋមភូមិដូចជា គ្មានម៉ោងបណ្ណាល័យក្នុបំណែងចែកភារកិច្ច ខ្វះការបំប៉នសមត្ថភាពគ្រូលើផ្នែកវិធីសាស្ត្របង្រៀនអំណានថ្មីៗ សម្ភារៈឧបទេសបង្រៀនអំណានមិនសូវសម្បូរបែប មាតាបិតាមិនសូវតាមដានការអានរបស់កូន សិស្សខ្លះខ្សោយអំណានតាំងពីបឋមសិក្សា សិស្សមិនចេះស្រៈ និងព្យញ្ជនៈបានគ្រប់គ្នា សិស្សខ្លះឡើងថ្នាក់មិនឆ្លុះបញ្ចាំងពីចំណេះដឹងពិត គ្មានម៉ោងបង្រៀនអំណានដាច់ដោយឡែក។ល។

### ៤.១.៣. ទស្សនៈគណៈគ្រប់គ្រងសាលាចំពោះយុទ្ធសាស្ត្រក្នុងការជំរុញអំណាន

យោងតាមលទ្ធផលនៃការឆ្លើយសំណួរបើក និងការសម្ភាសបន្ថែមពីគណៈគ្រប់គ្រងសាលារៀនក្នុងក្របខ័ណ្ឌស្រាវជ្រាវនេះ គឺពួកគាត់បានបង្ហាញទស្សនៈខ្លះៗដែលយល់ថាជាយុទ្ធសាស្ត្រក្នុងការជំរុញអំណានភាសាខ្មែររបស់សិស្សនៅកម្រិតមធ្យមសិក្សាបឋមភូមិដូចជា រៀបចំឱ្យមានម៉ោងបណ្ណាល័យក្នុងបំណែងចែកភារកិច្ច ស្នើក្រសួងឱ្យរៀបចំបំប៉នវិធីសាស្ត្របង្រៀនថ្មីៗឱ្យបានច្រើន ផ្សព្វផ្សាយដល់មាតាបិតាសិស្សឱ្យតាមដានការអានរបស់កូន បង្កើតកម្មវិធីបំប៉នសិស្សខ្សោយអំណានតាំងពីបឋមសិក្សា ឱ្យសិស្សមិនចេះស្រៈ និងព្យញ្ជនៈបានបំប៉នបន្ថែមលើស្រៈ និងព្យញ្ជនៈពេលម៉ោងអំណាន ណែនាំគ្រូឱ្យបង្កើតសម្ភារៈឧបទេសបង្រៀនអំណានបន្ថែម ឱ្យសិស្សឡើងថ្នាក់ដោយផ្តោតលើគុណភាពជាជាងបរិមាណ ស្នើក្រសួងឱ្យមានម៉ោងបង្រៀនអំណានដាច់ដោយឡែក។ល។

## ៤.២. លទ្ធផលលើកម្រងសំណួររបស់គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គម

### ៤.២.១. ដំណើរការនៃការបង្រៀន និងរៀនអំណាន

ក. ការអនុវត្តកម្មវិធីសិក្សា

តារាង៤.៤៖ លទ្ធផលលើកម្រងសំណួររបស់គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គម ទាក់ទងនឹងការអនុវត្តកម្មវិធីសិក្សា

| ល.រ | លោកគ្រូ អ្នកគ្រូបង្រៀនអំណានភាសាខ្មែរបាន ៖ | តម្លៃមធ្យម | គម្លាត ស្តង់ដា | កម្រិត វាយតម្លៃ |
|---|---|---|---|---|
| ១ | បានរៀបចំបំណែងចែកកម្មវិធីសិក្សា មុខវិជ្ជាភាសាខ្មែរបានច្បាស់លាស់តាមចំនួនម៉ោងកំណត់របស់ក្រសួងអប់រំ(៦ម៉ោងក្នុង១សប្តាហ៍) | 4.57 | 0.53 | ខ្ពស់បំផុត |
| ២ | ការរៀបចំបំណែងចែកកម្មវិធីសិក្សា ធ្វើតាមក្រុមមុខវិជ្ជាភាសាខ្មែរផ្នែកអំណាន យ៉ាងតិច២ម៉ោងក្នុង១សប្តាហ៍ | 4.00 | 0.00 | ខ្ពស់ |
| ៣ | បានរៀបចំកិច្ចតែងការបង្រៀនអំណានជាប្រចាំតាមចំនួនម៉ោងកំណត់ | 4.29 | 0.48 | ខ្ពស់ |
| ៤ | កិច្ចតែងការបង្រៀនអំណានត្រូវបានត្រួតពិនិត្យជាប្រចាំពីគណៈគ្រប់គ្រងសាលារៀន | 4.00 | 0.00 | ខ្ពស់ |
| ៥ | បានអនុវត្តការបង្រៀនអំណានតាមចំនួនម៉ោងកំណត់ក្នុងបំណែងចែកកម្មវិធីសិក្សា | 4.14 | 0.37 | ខ្ពស់ |
| ៦ | បានរៀនវគ្គបំប៉នស្រាវជ្រាវបន្ថែមលើការបង្រៀនអំណានភាសាខ្មែរ | 1.86 | 0.69 | ទាប |
| ៧ | បានប្រើប្រាស់សៀវភៅសិក្សាគោលភាសាខ្មែរតាមកម្រិតថ្នាក់ | 4.57 | 0.53 | ខ្ពស់ |
| ៨ | ប្រជុំក្រុមបច្ចេកទេស ពិនិត្យតាមដាន និងកែលម្អការអនុវត្តបង្រៀនអំណានភាសាខ្មែរទៀងទាត់ | 4.00 | 0.00 | ខ្ពស់ |
| ៩ | សាលាបានបែងចែកកាលវិភាគឱ្យមានម៉ោងបណ្ណាល័យដើម្បីលើកកម្ពស់គុណភាពបង្រៀនអំណាន | 2.14 | 0.37 | ទាប |
| ១០ | ចំនួនម៉ោងនេះមិនសូវគ្រប់គ្រាន់សម្រាប់ការបង្រៀនអំណានស្របតាមកម្មវិធីសិក្សា | 4.14 | 0.37 | ខ្ពស់ |
| | **សរុបជាមធ្យម** | **3.77** | **0.33** | ខ្ពស់ |

តាមតារាង៤.៤ បានបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវទាក់ទងនឹងការអនុវត្តកម្មវិធីសិក្សា ដោយគ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គមផ្តោតការយកចិត្តទុកដាក់ខ្លាំងលើការរៀបចំបំណែងចែកកម្មវិធីសិក្សា ការប្រើប្រាស់សៀវភៅសិក្សាគោល ការរៀបចំកិច្ចតែងការបង្រៀនអំណាន ការអនុវត្តការបង្រៀនអំណាន

ការដាក់កិច្ចតែងការបង្រៀនឱ្យគណៈគ្រប់គ្រងសាលារៀនពិនិត្យ ការប្រជុំក្រុមបច្ចេកទេស(តម្លៃមធ្យម= ៤.៥៧- ៤.០០)។

ចំណែកឯការអនុវត្តកម្មវិធីសិក្សាមួយចំនួនដែលគ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គមយល់ថា មិនសូវអនុវត្តមានដូចជា ការបែងចែកកាលវិភាគឱ្យមានម៉ោងបណ្ណាល័យ និងការរៀនវគ្គបំប៉នស្រាវជ្រាវបន្ថែមលើការបង្រៀនអំណាន (តម្លៃមធ្យម=២.១៤-១.៨៦)។

ជាលទ្ធផលរួម គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គមបានយល់ស្របថា ការអនុវត្តកម្មវិធីសិក្សាគឺស្ថិតក្នុងកម្រិតខ្ពស់(តម្លៃមធ្យម=៣.៧៧)។

**ខ. វិធីសាស្ត្របង្រៀន**

**តារាង៤.៥៖ លទ្ធផលលើកម្រងសំណួររបស់គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គម ទាក់ទងនឹងការអនុវត្តវិធីសាស្ត្របង្រៀនអំណាន**

| ល.រ | វិធីសាស្ត្របង្រៀន | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | បង្ហាញវត្ថុបំណងមេរៀនអំណានច្បាស់លាស់ | 4.43 | 0.53 | ខ្ពស់ |
| ២ | ផ្តល់ការការណែនាំដល់សិស្ស លើចំណេះដឹងស្តីពីអំណាន | 4.29 | 0.48 | ខ្ពស់ |
| ៣ | អានក្នុងចិត្ត ឬអានស្ងាត់ | 3.71 | 0.48 | ខ្ពស់ |
| ៤ | អានខ្សឹប | 3.71 | 0.48 | ទាប |
| ៥ | សិស្សអានឮៗម្នាក់ឯង | 4.00 | 0.57 | ខ្ពស់ |
| ៦ | សិស្សអានឮអានបណ្តាក់គ្នា | 4.57 | 0.53 | ខ្ពស់បំផុត |
| ៧ | អានស្ទាប(សម្រាប់សិស្សពិការ) | 1.00 | 0.00 | ទាបបំផុត |
| ៨ | សិស្សអានម្នាក់ឯង | 3.71 | 0.48 | ទាប |
| ៩ | សិស្សអានជាដៃគូ | 3.29 | 0.48 | មធ្យម |
| ១០ | សិស្សអានជាក្រុមតូច | 3.57 | 0.53 | ខ្ពស់ |
| ១១ | សិស្សអានរួមគ្នាទាំងអស់ | 2.71 | 0.48 | មធ្យម |
| ១២ | ផ្លាស់ប្តូរវិធីសាស្ត្រដោយប្រើល្បែងសិក្សាពីអំណាន | 2.43 | 0.55 | ទាប |
| ១៣ | គ្រូបានពិនិត្យសិស្សក្នុងពេលអានជាក្រុម ឬជាដៃគូ ឬជាបុគ្គល | 4.71 | 0.48 | ខ្ពស់បំផុត |

| | | | | |
|---|---|---|---|---|
| ១៤ | គ្រូបានស្តាប់សិស្សអាន ព្រមទាំងបានជួយអានពាក្យពិបាក | 4.57 | 0.53 | ខ្ពស់បំផុត |
| ១៥ | គ្រូបានអានជាគំរូក្នុងការបញ្ចេញសំឡេង តាមអក្ខរក្រម | 4.29 | 0.48 | ខ្ពស់ |
| | **សរុបជាមធ្យម** | **3.66** | **0.47** | **ខ្ពស់** |

តាមតារាង៤.៥ បានបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវទាក់ទងនឹងការអនុវត្តវិធីសាស្ត្របង្រៀន ដោយគ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គមផ្តោតការយកចិត្តទុកដាក់ខ្លាំងលើ ការពិនិត្យសិស្សក្នុងពេលអាន ការឱ្យសិស្សអានឮអានបណ្តាក់គ្នា ការស្តាប់សិស្សអាន ព្រមទាំងបានជួយអានពាក្យពិបាក ការបង្ហាញវត្ថុបំណងមេរៀនអំណាន ការណែនាំដល់សិស្សលើចំណេះដឹងស្តីពីអំណាន ការអានជាគំរូក្នុងការបញ្ចេញសំឡេងតាមអក្ខរក្រម ការឱ្យសិស្សអានឮៗម្នាក់ឯង អានក្នុងចិត្ត ឬអានស្ងាត់ អានខ្សឹប ការឱ្យសិស្សអានជាក្រុមតូច(តម្លៃមធ្យម=៤.៧១-៣.៥៧)។

ចំណែកឯការអនុវត្តវិធីសាស្ត្របង្រៀនមួយចំនួនដែលគ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គមយល់ថាមិនសូវអនុវត្តមានដូចជា ឱ្យសិស្សអានជាដៃគូ ឱ្យសិស្សអានរួមគ្នាទាំងអស់ ការផ្លាស់ប្តូរវិធីសាស្ត្រដោយប្រើល្បែងសិក្សាពីអំណាន ការអានស្វាបសម្រាប់សិស្សពិការ (តម្លៃមធ្យម=៣.២៩-១.០០)។

ជាលទ្ធផលរួម គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គមបានយល់ស្របថា ការអនុវត្តវិធីសាស្ត្របង្រៀនគឺស្ថិតក្នុងកម្រិតខ្ពស់(តម្លៃមធ្យម=៣.៦៦)។

**គ. ស្ថានភាពអនុវត្តជាក់ស្តែងក្នុងដំណើរការ និងសកម្មភាពបង្រៀនអំណាន**

**តារាង៤.៦៖ លទ្ធផលលើកម្រងសំណួររបស់គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គម ទាក់ទងនឹងស្ថានភាពអនុវត្តជាក់ស្តែងក្នុងដំណើរការ និងសកម្មភាពបង្រៀនអំណាន**

| ល.រ | ស្ថានភាពអនុវត្តជាក់ស្តែងក្នុងដំណើរការ និងសកម្មភាព | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | ប្រើប្រាស់កិច្ចតែងការបង្រៀនអំណានថ្មីជានិច្ច | 2.57 | 0.53 | មធ្យម |
| ២ | អនុវត្តការបង្រៀនអំណានតាមដំណាក់កាលជាប្រចាំ(មុនពេល ក្នុងពេល និងក្រោយពេលអំណាន) | 4.43 | 0.53 | ខ្ពស់ |

| | | | | |
|---|---|---|---|---|
| ៣ | បង្ហាញការសិក្សាចំណងជើង សិក្សារូបភាព ទំនាក់ទំនងចំណងជើងនិងរូបភាពពេលត្រៀមអំណាន | 3.86 | 0.37 | ខ្ពស់ |
| ៤ | សិក្សាពន្យល់ន័យពាក្យពិបាកទាំងអស់នៅក្នុងអំណាន | 4.14 | 0.37 | ខ្ពស់ |
| ៥ | ផ្តល់ឱកាសឱ្យសិស្សពូកែ និងសិស្សខ្សោយបានអានអត្ថបទ និងឆ្លើយសំណួរស្មើៗគ្នាពេលអំណាន | 4.00 | 0.00 | ខ្ពស់ |
| ៦ | ផ្តល់ឱកាសឱ្យសិស្សពិភាក្សាក្រុម( គូររូបភាព សង្ខេបអត្ថបទ តែងកំណាព្យ រកពាក្យស្លោក សម្តែងតួ...)នៅក្រោយអំណាន | 3.43 | 0.53 | មធ្យម |
| ៧ | ប្រឡងអានអត្ថបទម៉ោងអំណានក្នុងសាលាដើម្បីដាក់ពិន្ទុ | 3.00 | 0.57 | មធ្យម |
| ៨ | ជួយសិស្សខ្សោយអំណាន ឬពិបាកក្នុងការអានពេលរៀនអំណាន | 3.86 | 0.37 | ខ្ពស់ |
| ៩ | ផ្តល់ការការណែនាំដល់សិស្ស លើចំណេះដឹងស្តីពីអំណាន | 4.14 | 0.37 | ខ្ពស់ |
| ១០ | ណែនាំសិស្សឱ្យអានអត្ថបទនៅផ្ទះត្រៀមមុនចូលមេរៀនអំណាន | 4.00 | 0.00 | ខ្ពស់ |
| ១១ | បំផុសសកម្មភាពឱ្យសិស្សអានសៀវភៅក្នុង និងក្រៅបណ្ណាល័យ | 3.71 | 0.48 | ខ្ពស់ |
| ១៣ | ដាក់កិច្ចការផ្ទះផ្នែកអំណានឱ្យសិស្សធ្វើក្នុងសប្តាហ៍នីមួយៗ | 3.43 | 0.53 | មធ្យម |
| ១២ | រៀបចំកម្មវិធីបំប៉នបន្ថែមចំពោះសិស្សខ្សោយអំណាន | 1.71 | 0.48 | ទាប |
| ១៤ | រៀបចំកម្មវិធីការប្រឡង ប្រកួតប្រជែងផ្នែកអំណានតាមកម្រិត | 1.43 | 0.53 | ទាបបំផុត |
| ១៥ | ព្យាយាមលើកទឹកចិត្តសិស្សនៅពេលបង្រៀនអំណាន | 4.57 | 0.53 | ខ្ពស់បំផុត |
| ១៦ | សិស្សមានបម្រុងប្រយ័ត្ន ក្នុងពេលអានមេរៀន | 4.57 | 0.53 | ខ្ពស់បំផុត |
| ១៧ | បានណែនាំសិស្សចូលអានសៀវភៅក្នុងបណ្ណាល័យជាប្រចាំ | 4.14 | 0.37 | ខ្ពស់ |
| | **សរុបជាមធ្យម** | **3.58** | **0.42** | **ខ្ពស់** |

តាមតារាង៤.៦ បានបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវទាក់ទងនឹងស្ថានភាពអនុវត្តជាក់ស្តែងក្នុងដំណើរការ និងសកម្មភាពបង្រៀនអំណាន ដោយគ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គមផ្តោតការយកចិត្តទុកដាក់ខ្លាំងលើការលើកទឹកចិត្តសិស្ស បម្រុងប្រយ័ត្នរបស់សិស្សក្នុងពេលអានមេរៀន ការអនុវត្តការ

បង្រៀនអំណានតាមដំណាក់កាល ការពន្យល់ន័យពាក្យពិបាកនៅក្នុងអំណាន ការណែនាំដល់សិស្សលើចំណេះដឹងស្តីពីអំណាន ការណែនាំសិស្សចូលអានសៀវភៅក្នុងបណ្ណាល័យ ការផ្តល់ឱកាសស្មើៗគ្នាចំពោះសិស្សពូកែ និងសិស្សខ្សោយ ការណែនាំសិស្សឱ្យអានអត្ថបទនៅផ្ទះ ការបង្ហាញការសិក្សាចំណេះដឹង សិក្សារូបភាព ទំនាក់ទំនងចំណេះដឹងនិងរូបភាព ការជួយសិស្សខ្សោយអំណានពេលរៀនអំណាន ការបំផុសសកម្មភាពឱ្យសិស្សអានសៀវភៅ (តម្លៃមធ្យម=៤.៥៧ - ៣.៧១)។

ចំណែកឯស្ថានភាពអនុវត្តជាក់ស្តែងក្នុងដំណើរការ និងសកម្មភាពបង្រៀនអំណានមួយចំនួនដែលគ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គមយល់ថាមិនសូវអនុវត្តមានដូចជា ការប្រើប្រាស់កិច្ចតែងការបង្រៀនអំណានថ្មីជានិច្ច ការបំប៉នបន្ថែមចំពោះសិស្សខ្សោយអំណាន ការរៀបចំកម្មវិធីការប្រឡង ប្រកួតប្រជែងផ្នែកអំណានតាមកម្រិត (តម្លៃមធ្យម=២.៥៧ - ១.៤៣)។

ជាលទ្ធផលរួម គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គមបានយល់ស្របថា ស្ថានភាពអនុវត្តជាក់ស្តែងក្នុងដំណើរការ និងសកម្មភាពបង្រៀនអំណានគឺស្ថិតក្នុងកម្រិតខ្ពស់(តម្លៃមធ្យម=៣.៥៨)។

**ឃ. ការប្រើប្រាស់សម្ភារៈបង្រៀន និងសម្ភារៈឧបទេសក្នុងការបង្រៀនអំណាន**

**តារាង៤.៧ ៖ លទ្ធផលលើកម្រងសំណួររបស់គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គម ទាក់ទងនឹងការប្រើប្រាស់សម្ភារៈបង្រៀន និងសម្ភារៈឧបទេសក្នុងការបង្រៀនអំណាន**

| ល.រ | ប្រភេទសម្ភារៈ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | សៀវភៅសិក្សាគោល(ភាសាខ្មែរ) | 5.00 | 0.00 | ខ្ពស់បំផុត |
| ២ | សៀវភៅគ្រូ | 3.71 | 0.48 | ខ្ពស់ |
| ៣ | បណ្ណរូបភាព/ ផ្ទាំងក្រដាសរ៉ាម | 3.43 | 0.53 | មធ្យម |
| ៤ | បណ្ណសំណួរ | 3.71 | 0.48 | ខ្ពស់ |
| ៥ | សៀវភៅរឿងអប់រំខ្លីៗ | 2.86 | 0.37 | មធ្យម |
| ៦ | វចនានុក្រមភាសាខ្មែរ | 3.86 | 0.37 | ខ្ពស់ |
| ៧ | ឯកសារជាភាសាខ្មែរសម្រាប់សិស្សអានក្នុងបណ្ណាល័យ | 2.86 | 0.37 | មធ្យម |
| | **សរុបជាមធ្យម** | **3.63** | **0.37** | **ខ្ពស់** |

តាមតារាង៤.៧ បានបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវទាក់ទងនឹងការប្រើប្រាស់សម្ភារៈបង្រៀន និងសម្ភារៈឧបទេសក្នុងការបង្រៀនអំណាន ដោយគ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គមផ្តោតការយកចិត្តទុកដាក់ខ្លាំងលើការប្រើប្រាស់ជាប្រចាំដូចជា សៀវភៅសិក្សាគោល(ភាសាខ្មែរ) វចនានុក្រមភាសាខ្មែរ សៀវភៅគ្រូ បណ្ណសំណួរ(តម្លៃមធ្យម=៥.០០ - ៣.៧១)។

ចំណែកឯការប្រើប្រាស់សម្ភារៈបង្រៀន និងសម្ភារៈឧបទេសក្នុងការបង្រៀនអំណានមួយចំនួនដែលគ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គមយល់ថា មិនសូវប្រើប្រាស់ជាប្រចាំមានដូចជា បណ្ណរូបភាព/ផ្ទាំងក្រដាសរ៉ាម សៀវភៅរឿងអប់រំខ្លីៗ ឯកសារជាភាសាខ្មែរសម្រាប់សិស្សអានក្នុងបណ្ណាល័យ(តម្លៃមធ្យម=៣.៤៣ - ២.៨៦)។

ជាលទ្ធផលរួម គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គមបានយល់ស្របថា ការប្រើប្រាស់សម្ភារៈបង្រៀន និងសម្ភារៈឧបទេសក្នុងការបង្រៀនអំណាន គឺស្ថិតក្នុងកម្រិតខ្ពស់(តម្លៃមធ្យម=៣.៦៣)។

**ង. ការវាយតម្លៃលទ្ធផល**

**តារាង៤.៨ ៖ លទ្ធផលលើកម្រងសំណួររបស់គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គម ទាក់ទងនឹងការវាយតម្លៃលទ្ធផលក្នុងការបង្រៀនអំណាន**

| ល.រ | ការវាយតម្លៃសមត្ថភាពអំណានរបស់សិស្សផ្តោតលើ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| | **ទម្រង់នៃការវាយតម្លៃ** | | | |
| ១ | សំណួរផ្ទាល់មាត់ក្នុងម៉ោងបង្រៀនអំណានជាប្រចាំ | 3.86 | 0.37 | ខ្ពស់ |
| ២ | សំណួរខ្លីៗពេលម៉ោងបង្រៀនអំណាន | 3.86 | 0.37 | ខ្ពស់ |
| ៣ | កិច្ចការផ្ទះមេរៀនសិក្សាអត្ថបទអំណាន | 3.86 | 0.37 | ខ្ពស់ |
| ៤ | ប្រឡងឆមាស | 3.43 | 0.53 | មធ្យម |
| ៥ | ប្រឡងប្រចាំខែ | 3.29 | 0.75 | មធ្យម |
| | **របៀបអាន** | | | |
| ១ | សិស្សអានលឿន ស្ទាត់ | 2.71 | 0.48 | មធ្យម |
| ២ | សិស្សអានយល់ន័យពាក្យ | 2.71 | 0.48 | មធ្យម |

| | | | | |
|---|---|---|---|---|
| ៣ | សិស្សអានប្រកបពាក្យពួៗ | 2.57 | 0.78 | មធ្យម |
| ៤ | សិស្សអានយល់ន័យអត្ថបទដើម្បីឆ្លើយសំណួរបានត្រឹមត្រូវ | 3.86 | 0.37 | ខ្ពស់ |
| ៥ | សិស្សអានលើកដាក់សំឡេង និងគោរពសញ្ញា ឃ្លា ប្រយោគត្រឹមត្រូវ | 3.00 | 0.57 | មធ្យម |
| | **សរុបជាមធ្យម** | **3.31** | **0.51** | **មធ្យម** |

តាមតារាង៤.៨ បានបង្ហាញចម្លើយ និងលទ្ធផលនៃការស្រាវជ្រាវទាក់ទងនឹងការវាយតម្លៃលទ្ធផលក្នុងការបង្រៀនអំណាន ដោយគ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គមបានឆ្លើយថា ការវាយតម្លៃលទ្ធផលក្នុងការបង្រៀនអំណាន ផ្តោតលើទម្រង់នៃការវាយតម្លៃដែលគ្រូយកមកអនុវត្តមានដូចជា សំណួរផ្ទាល់មាត់ និងសំណួរបំផុសក្នុងពេលបង្រៀនអំណាន ការដាក់កិច្ចការឱ្យសិស្សអាននៅផ្ទះ និងការប្រឡងប្រចាំខែ និងឆមាស មានលក្ខណៈប្រហាក់ប្រហែលគ្នា។ តែទម្រង់វាយតម្លៃដែលសូចនាករទទួលបានពិន្ទុខ្ពស់គឺ ការប្រើសំណួរផ្ទាល់មាត់ក្នុងម៉ោងបង្រៀនអំណានជាប្រចាំ និងសិស្សអានយល់ន័យអត្ថបទដើម្បីឆ្លើយសំណួរបានត្រឹមត្រូវ(តម្លៃមធ្យម=៣.៨៦)។

ចំណែកឯការវាយតម្លៃជាក់ស្តែងលើសមត្ថភាពអំណានផ្តោតលើរបៀបអាន ដែលផ្អែកលើលក្ខណៈវិនិច្ឆ័យមួយចំនួនដូចជា ការអានស្ទាត់ អានយល់ន័យពាក្យ និង អត្ថបទ អានប្រកបពាក្យពួៗ និងការអានគោរពតាមសញ្ញា ឃ្លាប្រយោគបានត្រឹមត្រូវ។ ក្នុងនោះ ការអានយល់ន័យអត្ថបទដើម្បីឆ្លើយសំណួរបានត្រឹមត្រូវគឺជាចំណុចដែលគ្រូឱ្យតម្លៃជាងគេ(តម្លៃមធ្យម=៣.៨៦) និងការអានលើកដាក់សំឡេង គោរពតាមសញ្ញាវណ្ណយុត្តិ ឃ្លា ប្រយោគបានត្រឹមត្រូវ (តម្លៃមធ្យម=៣.៨៦) ហើយការអានស្ទាត់ អានយល់ន័យរបស់ពាក្យ និងការអានប្រកបពាក្យជាចំណុចដែលគ្រូឱ្យតម្លៃជាមធ្យម (តម្លៃមធ្យម=២.៥៧)។

ជាលទ្ធផលរួម គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គមបានយល់ស្របថា ការវាយតម្លៃលទ្ធផលក្នុងការបង្រៀនអំណានស្ថិតក្នុងកម្រិតមធ្យម(តម្លៃមធ្យម=៣.៣១)។

### ៤.២.២. បញ្ហាប្រឈមក្នុងការបង្រៀនអំណាន

តារាង៤.៩ ៖ លទ្ធផលលើកម្រងសំណួររបស់គ្រូបង្រៀនវិទ្យាសាស្ត្រសង្គម ទាក់ទងនឹងបញ្ហាប្រឈមក្នុងការបង្រៀនអំណាន

| ល.រ | បញ្ហាប្រឈមនានា | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | ការរៀបចំកម្មវិធីបំប៉នបន្ថែមចំពោះសិស្សខ្សោយអំណាន | 4.14 | 0.37 | ខ្ពស់ |
| ២ | ការរៀបចំកិច្ចតែងការបង្រៀនអំណានជាប្រចាំតាមចំនួនម៉ោងកំណត់ | 3.86 | 0.37 | ខ្ពស់ |
| ៣ | ការរៀបចំបំណែងចែកកម្មវិធីសិក្សា មុខវិជ្ជាភាសាខ្មែរឱ្យបានច្បាស់លាស់តាមចំនួនម៉ោងកំណត់របស់ក្រសួងអប់រំ | 2.43 | 0.53 | ទាប |
| ៤ | ការស្រាវជ្រាវបន្ថែមលើការបង្រៀនអំណានភាសាខ្មែរ | 3.86 | 0.37 | ខ្ពស់ |
| ៥ | ការអនុវត្តការបង្រៀនអំណានតាមចំនួនម៉ោងកំណត់ក្នុងបំណែងចែកកម្មវិធីសិក្សា | 2.43 | 0.53 | ទាប |
| ៦ | ខ្លឹមសារអត្ថបទអំណានក្នុងសៀវភៅសិក្សាគោល(ភាសាខ្មែរ)មិនសូវសមស្របតាមកម្រិតយល់ដឹងរបស់សិស្ស និងរយៈពេលកំណត់ | 3.57 | 0.53 | ខ្ពស់ |
| ៧ | ចំនួនសិស្សនៅក្នុងថ្នាក់មិនតាមស្តង់ដាការបង្រៀនអំណានមានប្រសិទ្ធភាព | 3.71 | 0.75 | ខ្ពស់ |
| ៨ | ប្រើវិធីសាស្ត្រនិងសម្ភារៈបង្រៀនអំណានឱ្យសម្បូរបែប និងសមស្រប | 4.00 | 0.00 | ខ្ពស់ |
| ៩ | ផលិតសម្ភារៈបង្រៀន និងសម្ភារៈឧបទេសគ្រប់គ្រាន់បម្រើឱ្យការបង្រៀនអំណានបានត្រឹមត្រូវ | 3.86 | 0.37 | ខ្ពស់ |
| ១០ | សិស្សខ្លះខ្សោយអំណានប្រកបពាក្យមិនចេញ មិនចេះស្រៈនិងព្យញ្ជនៈបានគ្រប់គ្នា | 4.14 | 0.37 | ខ្ពស់ |
| | **សរុបជាមធ្យម** | **3.60** | **0.42** | **ខ្ពស់** |

តាមតារាង៤.៩ បានបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវទាក់ទងនឹងបញ្ហាប្រឈមក្នុងការបង្រៀនអំណាន ដោយគ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គមផ្តោតការយកចិត្តទុកដាក់ខ្លាំងលើបញ្ហាប្រឈមមួយចំនួនដូចជា សិស្សខ្លះខ្សោយអំណានប្រកបពាក្យមិនចេញ ការផលិតសម្ភារៈបង្រៀន និងសម្ភារៈឧបទេស ការប្រើវិធីសាស្ត្របង្រៀនអំណានឱ្យសម្បូរបែប ការរៀបចំកម្មវិធីបំប៉នបន្ថែម ការស្រាវជ្រាវបន្ថែមលើការបង្រៀនអំណានភាសាខ្មែរ ចំនួនសិស្សនៅក្នុងថ្នាក់មិនតាមស្តង់ដាការបង្រៀនអំណានមានប្រសិទ្ធភាព ខ្លឹមសារអត្ថបទអំណានក្នុងសៀវភៅសិក្សាគោលមិនសូវសមស្របតាមកម្រិតយល់ដឹងរបស់សិស្ស និងរយៈពេលកំណត់(តម្លៃមធ្យម=៤.១៤ - ៣.៥៧)។

ចំណែកឯបញ្ហាប្រឈមក្នុងការបង្រៀនអំណានមួយចំនួនដែលគ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គម យល់ថា មិនសូវជាប្រឈមខ្លាំងមានដូចជា ការរៀបចំបំណែងចែកកម្មវិធីសិក្សា ការអនុវត្តការបង្រៀនអំណានតាមចំនួនម៉ោងកំណត់(តម្លៃមធ្យម=២.៤៣)។

ជាលទ្ធផលរួម គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រសង្គមបានយល់ស្របថា បញ្ហាប្រឈមក្នុងការបង្រៀនអំណានគឺស្ថិតក្នុងកម្រិតខ្ពស់(តម្លៃមធ្យម=៣.៦០)។

## ៤.៣. លទ្ធផលលើកម្រងសំណួររបស់សិស្ស

### ៤.៣.១. ដំណើរការនៃការបង្រៀន និងរៀនអំណាន

### ក. ព័ត៌មានអំពីការសិក្សា

**តារាង៤.១០៖ លទ្ធផលលើកម្រងសំណួររបស់សិស្សានុសិស្ស ទាក់ទងនឹងការអនុវត្តកម្មវិធីសិក្សា**

| ល.រ | ការបរិយាយ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | ប្អូនរៀនមុខវិជ្ជាភាសាខ្មែរ ៦ម៉ោងក្នុង១សប្តាហ៍ | 4.77 | 0.42 | ខ្ពស់បំផុត |
| ២ | ប្អូនរៀនភាសាខ្មែរផ្នែកអំណានយ៉ាងតិច២ម៉ោងក្នុង១សប្តាហ៍ | 4.31 | 0.62 | ខ្ពស់ |
| ៣ | ប្អូនរៀនអំណានបានទៀងទាត់តាមកាលវិភាគជាប្រចាំ | 4.27 | 0.63 | ខ្ពស់ |
| ៤ | កាលវិភាគសិក្សារបស់ប្អូន មានម៉ោងបណ្ណាល័យសម្រាប់ប្អូនចូលពង្រឹងអំណានបន្ថែមទៀត | 2.16 | 0.61 | ទាប |
| ៥ | គ្រូមានទំនួលខុសត្រូវក្នុងការគោរពពេលវេលា | 4.33 | 0.47 | ខ្ពស់ |
| ៦ | ចំនួនម៉ោងបង្រៀនអំណានមិនសូវគ្រប់គ្រាន់សម្រាប់ប្អូនៗ | 4.22 | 0.76 | ខ្ពស់ |
| | **សរុបជាមធ្យម** | **4.01** | **0.59** | **ខ្ពស់** |

តាមតារាង៤.១០ បានបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវទាក់ទៅទងនឹងព័ត៌មានអំពីការសិក្សាអំណានភាសាខ្មែរ ដែលសិស្សានុសិស្សយល់ស្របទាំងស្រុង និងឯកភាព ហើយបានបញ្ជាក់ពីការអនុវត្តជាប្រចាំ និងញឹកញាប់រួមមាន ការរៀនមុខវិជ្ជាភាសាខ្មែរ៦ម៉ោងក្នុង១សប្តាហ៍ ទំនួលខុសត្រូវរបស់គ្រូក្នុងការគោរពពេលវេលា ការរៀនអំណានយ៉ាងតិច២ម៉ោងក្នុង១សប្តាហ៍ ការរៀនអំណានតាមកាលវិភាគជាប្រចាំ ចំនួនម៉ោងបង្រៀនអំណានមិនសូវគ្រប់គ្រាន់ (តម្លៃមធ្យម=៤.៧៧ - ៤.២២)។

ចំណែកឯព័ត៌មានអំពីការសិក្សាអំណានភាសាខ្មែរដែលសិស្សយល់ថា គ្រូមិនសូវអនុវត្តគឺ ម៉ោងបណ្ណាល័យសម្រាប់សិស្សចូលពង្រឹងអំណានបន្ថែមទៀត (តម្លៃមធ្យម=២.១៦)។

ជាលទ្ធផលរួម សិស្សានុសិស្សបានយល់ស្របថា ព័ត៌មានអំពីការសិក្សាអំណានភាសាខ្មែរ ដែលគ្រូបានប្រើសកម្មភាពជាច្រើនក្នុងម៉ោងបង្រៀនជាក់ស្តែងស្ថិតក្នុងកម្រិតខ្ពស់(តម្លៃមធ្យម=៤.០១)។

**ខ. របៀបរៀនអំណានភាសាខ្មែរ**

**តារាង៤.១១៖ លទ្ធផលលើកម្រងសំណួររបស់សិស្សានុសិស្ស ទាក់ទងនឹងរបៀបរៀនអំណានភាសាខ្មែរ**

| ល.រ | សកម្មភាពរៀន | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | ស្តាប់ការបង្ហាញវត្ថុបំណងមេរៀនអំណានច្បាស់លាស់ | 4.06 | 0.70 | ខ្ពស់ |
| ២ | ស្តាប់ការណែនាំរបស់គ្រូស្តីពីរបៀបអាន មុននឹងអានអត្ថបទ | 4.07 | 0.63 | ខ្ពស់ |
| ៣ | អានក្នុងចិត្ត ឬអានស្ងាត់ ទាំងអស់គ្នា | 4.19 | 0.58 | ខ្ពស់ |
| ៤ | អានខ្សឹបដោយយកដៃចង្អុលតាមបន្ទាត់នៃប្រយោគក្នុងល្បះនីមួយៗ | 3.71 | 0.56 | ខ្ពស់ |
| ៥ | អានឮៗម្នាក់ឯង | 3.17 | 0.54 | មធ្យម |
| ៦ | អានឮបណ្តាក់គ្នា | 4.39 | 0.59 | ខ្ពស់ |
| ៧ | អានស្នាប(សម្រាប់សិស្សពិការ) | 1.00 | 0.00 | ទាបបំផុត |
| ៨ | អានជាដៃគូ | 3.08 | 0.59 | មធ្យម |
| ៩ | អានជាក្រុមតូច | 3.33 | 0.63 | មធ្យម |
| ១០ | អានរួមគ្នាទាំងអស់ | 2.37 | 0.52 | ទាប |
| ១១ | លេងល្បែងសិក្សា(ដើរតួ ប្រកួតអានពាក្យពិបាក ទាយពាក្យ) | 2.24 | 0.58 | ទាប |
| ១២ | អានតាមគ្រូ ជាក្រុម ឬជាដៃគូ ឬជាបុគ្គល | 3.49 | 0.63 | មធ្យម |
| ១៣ | ស្តាប់គ្រូអានពាក្យពិបាក រួចថាតាម | 4.08 | 0.53 | ខ្ពស់ |
| | **សរុបជាមធ្យម** | **3.32** | **0.55** | **មធ្យម** |

តាមតារាង៤.១១ បានបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវទាក់ទងនឹងរបៀបរៀនអំណានភាសាខ្មែរ ដែលសិស្សានុសិស្សយល់ស្របទាំងស្រុង និងឯកភាព ហើយបានបញ្ជាក់ពីការអនុវត្តជាប្រចាំ និង

ញឹកញាប់របស់គ្រូរួមមាន ការអានឮបណ្តាក់គ្នា ការអានក្នុងចិត្ត ឬអានស្ងាត់ ទាំងអស់គ្នា ការស្តាប់គ្រូអានពាក្យពិបាករួចថាតាម ការស្តាប់ការណែនាំរបស់គ្រូស្តីពីរបៀបអាន ការស្តាប់ការបង្ហាញវត្ថុបំណងមេរៀនអំណាន ការអានខ្សឹបដោយយកដៃចង្អុលតាមបន្ទាត់(តម្លៃមធ្យម=៤.៣៩ - ៣.៧១)។

ចំណែកឯរបៀបរៀនអំណានភាសាខ្មែរមួយចំនួនដែលសិស្សយល់ថា គ្រូមិនសូវអនុវត្តមានដូចជាការអានរួមគ្នាទាំងអស់ ការលេងល្បែងសិក្សា ការអានស្ងាប(តម្លៃមធ្យម=២.៣៧ - ១.០០)។

ជាលទ្ធផលរួម សិស្សានុសិស្សបានយល់ស្របថា គ្រូបានប្រើសកម្មភាពបង្រៀនអំណានភាសាខ្មែរក្នុងម៉ោងបង្រៀនជាក់ស្តែងដែលធ្វើឱ្យរបៀបរៀនអំណានភាសាខ្មែររបស់សិស្សស្ថិតក្នុងកម្រិតមធ្យម(តម្លៃមធ្យម=៣.៣២)។

### គ. សកម្មភាពបង្រៀនអំណានភាសាខ្មែរ

**តារាង៤.១២៖ លទ្ធផលលើកម្រងសំណួររបស់សិស្សានុសិស្ស ទាក់ទងនឹងសកម្មភាពបង្រៀនអំណានភាសាខ្មែរ**

| ល.រ | សកម្មភាពបង្រៀនអំណានភាសាខ្មែរ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | គ្រូបង្ហាញវត្ថុបំណងមេរៀននៃអត្ថបទ អំណានជាប្រចាំ | 3.89 | 0.65 | ខ្ពស់ |
| ២ | គ្រូបង្ហាញ ចំណងជើង សិក្សារូបភាព ទំនាក់ទំនងចំណងជើងនិងរូបភាពពេលត្រៀមអំណាន | 4.58 | 0.49 | ខ្ពស់បំផុត |
| ៣ | គ្រូពន្យល់ន័យពាក្យពិបាកទាំងអស់នៅក្នុងអំណាន | 4.64 | 0.48 | ខ្ពស់បំផុត |
| ៤ | គ្រូផ្តល់ឱកាសឱ្យសិស្សពូកែ និងសិស្សខ្សោយបានអានអត្ថបទ និងឆ្លើយសំណួរស្មើៗគ្នាពេលអំណាន | 3.74 | 0.43 | ខ្ពស់ |
| ៥ | គ្រូហៅសិស្សឡើងអានអត្ថបទផ្លាស់ប្តូរគ្នា | 4.64 | 0.48 | ខ្ពស់បំផុត |
| ៦ | គ្រូឱ្យសិស្សពិភាក្សាក្រុម(គូររូបភាព សង្ខេបអត្ថបទ តែងកំណាព្យ រកពាក្យស្លោក សម្តែងតួ...)នៅក្រោយអំណាន | 3.19 | 0.53 | មធ្យម |
| ៧ | គ្រូឱ្យសិស្សពូកែជួយសិស្សខ្សោយក្នុងការអានពិបាក ពេលរៀនអំណាន | 3.69 | 0.46 | ខ្ពស់ |

| | | | | |
|---|---|---|---|---|
| ៨ | គ្រូណែនាំសិស្សឱ្យអានអត្ថបទអំណាននៅផ្ទះត្រៀមមុនចូលមេរៀនអំណាន | 4.67 | 0.47 | ខ្ពស់បំផុត |
| ៩ | គ្រូតែងតែបំផុសសកម្មភាពឱ្យសិស្សអានសៀវភៅនៅបណ្ណាល័យ | 3.96 | 0.52 | ខ្ពស់ |
| ១០ | គ្រូជួយបំប៉នបន្ថែមចំពោះសិស្សខ្សោយអំណាននៅពេលចេញលេង | 2.23 | 0.62 | ទាប |
| ១១ | គ្រូដាក់កិច្ចការផ្ទះផ្នែកអំណានឱ្យសិស្សធ្វើក្នុងសប្តាហ៍នីមួយៗ | 4.06 | 0.56 | ខ្ពស់ |
| ១២ | គ្រូណែនាំសិស្សឱ្យចូលរួមការប្រឡង ប្រកួតប្រជែងផ្នែកអំណានតាមកម្រិត | 2.16 | 0.61 | ទាប |
| ១៣ | គ្រូលើកទឹកចិត្តសិស្សពេលបង្រៀនអំណាន | 4.68 | 0.46 | ខ្ពស់បំផុត |
| | **សរុបជាមធ្យម** | **3.85** | **0.52** | **ខ្ពស់** |

តាមតារាង៤.១២ បានបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវទាក់ទងទៅនឹងសកម្មភាពបង្រៀនអំណានភាសាខ្មែរ ដែលសិស្សានុសិស្សយល់ស្របទាំងស្រុង និងឯកភាព ហើយបានបញ្ជាក់ពីការអនុវត្តជាប្រចាំ និងញឹកញាប់របស់គ្រូរួមមាន ការលើកទឹកចិត្តសិស្ស ការណែនាំសិស្សឱ្យអានអត្ថបទអំណាននៅផ្ទះ ការពន្យល់ន័យពាក្យពិបាកនៅក្នុងអំណាន ការអានអត្ថបទផ្លាស់ប្តូរគ្នា ការបង្ហាញចំណងជើង សិក្សារូបភាព ទំនាក់ទំនងចំណងជើងនិងរូបភាព ការដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើក្នុងសប្តាហ៍នីមួយៗ ការបំផុសសកម្មភាពឱ្យសិស្សអានសៀវភៅនៅបណ្ណាល័យ គ្រូបង្ហាញវត្ថុបំណងមេរៀននៃអត្ថបទ អំណានជាប្រចាំ គ្រូផ្តល់ឱកាសឱ្យសិស្សពូកែ និងសិស្សខ្សោយបានអានអត្ថបទ និងឆ្លើយសំណួរស្មើៗគ្នាពេលអំណាន ការជួយសិស្សខ្សោយក្នុងការអានពិបាក (តម្លៃមធ្យម=៤.៦៨ - ៣.៦៩)។

ចំណែកឯ សកម្មភាពបង្រៀនអំណានមួយចំនួនដែលសិស្សយល់ថា គ្រូមិនសូវអនុវត្តមានដូចជាការបំប៉នបន្ថែមចំពោះសិស្សខ្សោយអំណាន ការណែនាំសិស្សឱ្យចូលរួមការប្រឡងប្រកួតប្រជែងផ្នែកអំណាន (តម្លៃមធ្យម=២.២៣ - ២.១៦)។

ជាលទ្ធផលរួម សិស្សានុសិស្សបានយល់ស្រប ថាគ្រូបានប្រើសកម្មភាពបង្រៀនអំណានភាសាខ្មែរជាច្រើនក្នុងម៉ោងបង្រៀនជាក់ស្តែងដែលស្ថិតក្នុងកម្រិតខ្ពស់(តម្លៃមធ្យម=៣.៨៥)។

### ឃ. ការប្រើប្រាស់សម្ភារៈក្នុងការបង្រៀន

**តារាង៤.១៣៖ លទ្ធផលលើកម្រងសំណួររបស់សិស្សានុសិស្ស ទាក់ទងនឹងការប្រើប្រាស់សម្ភារៈក្នុងការបង្រៀនអំណានភាសាខ្មែរ**

| ល.រ | ប្រភេទសម្ភារៈ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | សៀវភៅសិក្សាគោល(ភាសាខ្មែរ) | 4.83 | 0.37 | ខ្ពស់បំផុត |
| ២ | បណ្ណរូបភាព/ ផ្ទាំងក្រដាសរ៉ាម | 3.46 | 0.54 | មធ្យម |
| ៣ | បណ្ណសំណួរ | 4.36 | 0.48 | ខ្ពស់ |
| ៤ | សៀវភៅរឿងអប់រំខ្លីៗ | 3.17 | 0.51 | មធ្យម |
| ៥ | វចនានុក្រមភាសាខ្មែរ | 3.99 | 0.46 | ខ្ពស់ |
| ៦ | ឯកសារជាភាសាខ្មែរសម្រាប់សិស្សអានក្នុងបណ្ណាល័យ | 3.09 | 0.56 | មធ្យម |
| | **សរុបជាមធ្យម** | **3.81** | **0.48** | **ខ្ពស់** |

តាមតារាង៤.១៣ បានបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវទាក់ទងទៅនឹងការប្រើប្រាស់សម្ភារៈក្នុងការបង្រៀនអំណានភាសាខ្មែរ ដែលសិស្សានុសិស្សយល់ស្របទាំងស្រុង និងឯកភាព ហើយបានបញ្ជាក់ពីការប្រើប្រាស់ជាប្រចាំ និងញឹកញាប់របស់គ្រូរួមមាន សៀវភៅសិក្សាគោល(ភាសាខ្មែរ) បណ្ណសំណួរ វចនានុក្រមភាសាខ្មែរ (តម្លៃមធ្យម=៤.៨៣ - ៣.៩៩)។

ចំណែកឯការប្រើប្រាស់សម្ភារៈក្នុងការបង្រៀនអំណានភាសាខ្មែរមួយចំនួនដែលសិស្សយល់ថា គ្រូមិនសូវប្រើប្រាស់បានញឹកញាប់ជាប្រចាំមានដូចជា បណ្ណរូបភាព/ ផ្ទាំងក្រដាសរ៉ាម សៀវភៅរឿងអប់រំខ្លីៗ ឯកសារជាភាសាខ្មែរសម្រាប់សិស្សអានក្នុងបណ្ណាល័យ (តម្លៃមធ្យម=៣.៤៦ - ៣.០៩)។

ជាលទ្ធផលរួម សិស្សានុសិស្សបានយល់ស្របថា គ្រូបានប្រើប្រាស់សម្ភារៈក្នុងការបង្រៀនអំណានភាសាខ្មែរជាច្រើនក្នុងម៉ោងបង្រៀនជាក់ស្តែងដែលស្ថិតក្នុងកម្រិតខ្ពស់(តម្លៃមធ្យម=៣.៨១)។

### ង. ការវាយតម្លៃលទ្ធផល

**តារាង៤.១៤៖ លទ្ធផលលើកម្រងសំណួររបស់សិស្សានុសិស្ស ទាក់ទងនឹងការវាយតម្លៃលទ្ធផលក្នុងការបង្រៀនអំណានភាសាខ្មែរ**

| ល.រ | របៀបវាយតម្លៃសមត្ថភាពអំណានរបស់គ្រូ | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | ឱ្យសិស្សប្រឡងអានអត្ថបទដាក់ពិន្ទុជាប្រចាំពេលម៉ោងបង្រៀនអំណាន | 3.07 | 0.68 | មធ្យម |
| ២ | ដាក់ពិន្ទុលើការអានលឿន និងស្ទាត់ | 2.66 | 0.94 | មធ្យម |
| ៣ | ដាក់ពិន្ទុលើការអានយល់ន័យពាក្យ | 3.83 | 0.69 | ខ្ពស់ |
| ៤ | ដាក់ពិន្ទុលើការអានប្រកបពាក្យឮៗ | 2.37 | 0.93 | ទាប |
| ៥ | ដាក់ពិន្ទុលើការអានយល់ន័យអត្ថបទ | 3.76 | 0.82 | ខ្ពស់ |
| ៦ | ដាក់ពិន្ទុលើការឆ្លើយសំណួរក្នុងអត្ថបទបានត្រឹមត្រូវ | 4.25 | 0.45 | ខ្ពស់ |
| ៧ | ដាក់ពិន្ទុលើការអានលើកដាក់សំឡេង និងគោរពសញ្ញា ឃ្លា ប្រយោគត្រឹមត្រូវ | 3.41 | 0.83 | មធ្យម |
| ៨ | ការដាក់ពិន្ទុមានតម្លាភាព និងយុត្តិធម៌ | 4.63 | 0.48 | ខ្ពស់បំផុត |
| | **សរុបជាមធ្យម** | **3.49** | **0.73** | **មធ្យម** |

តាមតារាង៤.១៤ បានបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវទាក់ទងទៅនឹងរបៀបវាយតម្លៃសមត្ថភាពអំណាន ដែលសិស្សានុសិស្សយល់ស្របទាំងស្រុង និងឯកភាព ហើយបានបញ្ជាក់ពីការអនុវត្តជាប្រចាំ និងញឹកញាប់របស់គ្រូរួមមាន ការដាក់ពិន្ទុមានតម្លាភាព និងយុត្តិធម៌ ការដាក់ពិន្ទុលើការឆ្លើយសំណួរក្នុងអត្ថបទ ការដាក់ពិន្ទុលើការអានយល់ន័យពាក្យ ការដាក់ពិន្ទុលើការអានយល់ន័យអត្ថបទ (តម្លៃមធ្យម=៤.៦៣ - ៣.៧៦)។

ចំណែកឯរបៀបវាយតម្លៃសមត្ថភាពអំណានមួយចំនួនដែលសិស្សយល់ថា គ្រូមិនសូវអនុវត្តបានញឹកញាប់មានដូចជា ការដាក់ពិន្ទុលើការអានលឿន និងស្ទាត់ ការដាក់ពិន្ទុលើការអានប្រកបពាក្យឮៗ (តម្លៃមធ្យម=២.៦៦ - ២.៣៧)។

ជាលទ្ធផលរួម សិស្សានុសិស្សបានយល់ស្របថា គ្រូបានប្រើរបៀបវាយតម្លៃសមត្ថភាពអំណានក្នុងម៉ោងបង្រៀនជាក់ស្តែងដែលស្ថិតក្នុងកម្រិតមធ្យម(តម្លៃមធ្យម=៣.៤៩)។

### ៤.៣.២. បញ្ហាប្រឈមក្នុងការរៀនអំណាន

**តារាង៤.១៥៖ លទ្ធផលលើកម្រងសំណួររបស់សិស្សានុសិស្សទាក់ទងនឹងបញ្ហាប្រឈមនានាក្នុងការរៀនអំណានភាសាខ្មែរ**

| ល.រ | ការបរិយាយបញ្ហាប្រឈម | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិតវាស់វែង |
|---|---|---|---|---|
| ១ | ចំនួនម៉ោងបង្រៀនអំណានមិនសមស្របនៅក្នុងសៀវភៅសិក្សាគោល | 2.77 | 0.89 | មធ្យម |
| ២ | ចំនួនម៉ោងសិក្សាមុខវិជ្ជាភាសាខ្មែរមិនគ្រប់គ្រាន់សម្រាប់ឱ្យសិស្សចេះ | 2.72 | 0.98 | មធ្យម |
| ៣ | បណ្ណាល័យមិនមានសៀវភៅគ្រប់គ្រាន់សម្រាប់សិស្សអានគ្រប់កម្រិត | 3.50 | 0.92 | មធ្យម |
| ៤ | សកម្មភាពបង្រៀនអំណានរបស់គ្រូពិបាកធ្វើឱ្យប្អូនឆាប់ចេះអាន | 2.71 | 0.90 | មធ្យម |
| ៥ | សម្ភារៈផ្សេងៗសម្រាប់បង្រៀនអំណានមិនគ្រប់គ្រាន់ | 3.54 | 0.97 | ខ្ពស់ |
| ៦ | សៀវភៅសិក្សាគោលភាសាខ្មែរសម្រាប់បង្រៀនអំណានមិនគ្រប់គ្រាន់ | 2.58 | 0.96 | មធ្យម |
| ៧ | អត្ថបទអំណានក្នុងសៀវភៅសិក្សាគោលពិបាកក្នុងការយល់ | 3.52 | 0.91 | ខ្ពស់ |
| ៨ | អត្ថបទអំណានក្នុងសៀវភៅសិក្សាគោលមិនសមស្របនឹងពេលកំណត់(ពេលខ្លី) | 3.57 | 0.87 | ខ្ពស់ |
| | **សរុបជាមធ្យម** | **3.11** | **0.92** | **មធ្យម** |

តាមតារាង៤.១៥ បានបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវទាក់ទងនឹងបញ្ហាប្រឈមក្នុងការរៀនអំណាន ដោយសិស្សានុសិស្សផ្ដោតការយកចិត្តទុកដាក់ខ្លាំងលើបញ្ហាប្រឈមមួយចំនួនដូចជា អត្ថបទអំណានក្នុងសៀវភៅសិក្សាគោលមិនសមស្របនឹងរយៈពេលកំណត់(ពេលខ្លី) សម្ភារៈផ្សេងៗសម្រាប់បង្រៀនអំណានមិនគ្រប់គ្រាន់ អត្ថបទអំណានក្នុងសៀវភៅសិក្សាគោលពិបាកក្នុងការយល់(តម្លៃមធ្យម= ៣.៥៧ - ៣.៥២)។

ចំណែកឯបញ្ហាប្រឈមក្នុងការរៀនអំណានមួយចំនួនដែលសិស្សានុសិស្សយល់ថា មិនសូវជាប្រឈមខ្លាំងមានដូចជា បណ្ណាល័យមិនមានសៀវភៅគ្រប់គ្រាន់សម្រាប់សិស្សអានគ្រប់កម្រិត ចំនួនម៉ោងបង្រៀនអំណានមិនសមស្របនៅក្នុងសៀវភៅសិក្សាគោល ចំនួនម៉ោងសិក្សាមុខវិជ្ជាភាសាខ្មែរមិនគ្រប់គ្រាន់សម្រាប់ឱ្យសិស្សចេះ សកម្មភាពបង្រៀនអំណានរបស់គ្រូ សៀវភៅសិក្សាគោលភាសាខ្មែរសម្រាប់បង្រៀនអំណានមិនគ្រប់គ្រាន់(តម្លៃមធ្យម=៣.៥០ - ២.៥៨)។

ជាលទ្ធផលរួម សិស្សានុសិស្សបានយល់ស្របថា បញ្ហាប្រឈមក្នុងការរៀនអំណានគឺស្ថិតក្នុងកម្រិតមធ្យម(តម្លៃមធ្យម=៣.១១)។

## ៤.៤. លទ្ធផលរួមនៃការស្រាវជ្រាវ

### ៤.៤.១. ស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាន

**តារាង៤.១៦៖ លទ្ធផលរួមនៃដំណើរការបង្រៀន និងរៀនអំណាន**

| ល.រ | ខ្លឹមសារ | គណៈគ្រប់គ្រង | | គ្រូបង្រៀន | | សិស្សានុសិស្ស | | សរុបតម្លៃមធ្យម | អត្ថន័យ |
|---|---|---|---|---|---|---|---|---|---|
| | | Mean | St. D | Mean | St. D | Mean | St. D | | |
| ១ | ការអនុវត្តកម្មវិធីសិក្សា | ៣.៧៥ | ០.៤៨ | ៣.៧៧ | ០.៣៣ | ៤.០១ | ០.៥៩ | ៣.៨៤ | ខ្ពស់ |
| ២ | វិធីសាស្ត្របង្រៀន | ៣.៤៩ | ០.៤៧ | ៣.៦៦ | ០.៤៧ | ៣.៣២ | ០.៥៥ | ៣.៤៩ | មធ្យម |
| ៣ | សកម្មភាពបង្រៀន និងរៀនជាក់ស្តែង | ៣.៦១ | ០.៣៩ | ៣.៥៨ | ០.៤២ | ៣.៨៥ | ០.៥២ | ៣.៦៨ | ខ្ពស់ |
| ៤ | ការប្រើប្រាស់សម្ភារៈ | | | ៣.៦៣ | ០.៣៧ | ៣.៨១ | ០.៤៨ | ៣.៧២ | ខ្ពស់ |
| ៥ | ការវាយតម្លៃលទ្ធផល | | | ៣.៣១ | ០.៥១ | ៣.៤៩ | ០.៧៣ | ៣.៤០ | មធ្យម |
| **សរុបរួម** | | | | | | | | **៣.៦២** | **ខ្ពស់** |

តាមតារាង៤.១៦ បានបង្ហាញថា ស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ គឺស្ថិតក្នុងកម្រិតខ្ពស់(មធ្យមភាគពិន្ទុ=៣.៦២)។

សូចនាករនានាដែលគាំទ្រស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិនេះមានដូចជា ការអនុវត្តកម្មវិធីសិក្សា(មធ្យមភាគពិន្ទុ=៣.៨៤) វិធីសាស្ត្របង្រៀន(មធ្យមភាគពិន្ទុ=៣.៤៩) សកម្មភាពបង្រៀន និងរៀនជាក់ស្តែង(មធ្យមភាគពិន្ទុ=៣.៦៨) ការប្រើប្រាស់សម្ភារៈ(មធ្យមភាគពិន្ទុ=៣.៧២) និងការវាយតម្លៃលទ្ធផល (មធ្យមភាគពិន្ទុ=៣.៤០)។

#### ៤.៤.១.១. ការអនុវត្តកម្មវិធីសិក្សា

**តារាង៤.១៧ ៖ ការអនុវត្តកម្មវិធីសិក្សា**

| ល.រ | ភាគសំណាក | តម្លៃមធ្យម | គម្លាតស្តង់ដា | អត្ថន័យ |
|---|---|---|---|---|
| ១ | គណៈគ្រប់គ្រងសាលារៀន | ៣.៧៥ | ០.៤៨ | ខ្ពស់ |
| ២ | គ្រូបង្រៀនវិទ្យាសាស្ត្រសង្គម | ៣.៧៧ | ០.៣៣ | ខ្ពស់ |
| ៣ | សិស្សានុសិស្ស | ៤.០១ | ០.៥៩ | ខ្ពស់ |
| **សរុប** | | **៣.៨៤** | **០.៤៦** | **ខ្ពស់** |

តាមតារាង៤.១៧ បានបង្ហាញចម្លើយ និងលទ្ធផលនៃការស្រាវជ្រាវទាក់ទងនឹងការអនុវត្តកម្មវិធីសិក្សាអំណានភាសាខ្មែរ ដោយចម្លើយរួមរបស់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និងសិស្សានុសិស្ស គឺការអនុវត្តកម្មវិធីសិក្សាអំណានភាសាខ្មែរស្ថិតក្នុងកម្រិតខ្ពស់(មធ្យមភាគពិន្ទុ=៣.៨៤)។

តម្លៃមធ្យមជារួម(៣.៨៤)នេះមានន័យថា ការអនុវត្តកម្មវិធីសិក្សាអំណានភាសាខ្មែរនៅកម្រិតមធ្យមសិក្សាបឋមភូមិគឺអនុវត្តបានល្អ។ កម្រិតលទ្ធផលនេះ ឆ្លុះបញ្ចាំងតាមរយៈសូចនាករសំខាន់ៗជាច្រើនដូចជា ការពិនិត្យតាមដានលើដំណើរការបង្រៀនរបស់គ្រូជាប្រចាំ ការរៀបចំបំណែងចែកកម្មវិធីសិក្សាមុខវិជ្ជាភាសាខ្មែរតាមចំនួនម៉ោងកំណត់របស់ក្រសួងអប់រំ ការប្រើប្រាស់សៀវភៅសិក្សាគោលភាសាខ្មែរតាមកម្រិតថ្នាក់ ការរៀបចំកិច្ចតែងការបង្រៀនអំណានជាប្រចាំតាមចំនួនម៉ោងកំណត់ គ្រូមានទំនួលខុសត្រូវក្នុងការគោរពពេលវេលា ដែលបានអនុវត្តយ៉ាងរលូនតាមផែនការកំណត់ និងមានភាពស៊ីចង្វាក់គ្នារវាងគណៈគ្រប់គ្រង លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស។

ផ្ទុយមកវិញ តាមលទ្ធនៃការសិក្សា ក៏បានបញ្ជាក់នៅក្នុងសូចនាករមួយចំនួនដែលសាលាអនុវត្តនៅមានកម្រិតដូចជា ការបែងចែកកាលវិភាគឱ្យមានម៉ោងបណ្ណាល័យដើម្បីលើកកម្ពស់គុណភាពបង្រៀនអំណាន គ្មានវគ្គបំប៉នស្រាវជ្រាវបន្ថែមលើការបង្រៀនអំណានភាសាខ្មែរ គ្មានការបង្កើតឱ្យមានក្លឹបសិក្សា

ដើម្បីឱ្យសិស្សពូកែជួយសិស្សខ្សោយ(អំណាន) ដែលសូចនាករទាំងនេះបានជះឥទ្ធិពលអវិជ្ជមាន ធ្វើឱ្យដំណើរការបង្រៀន និងរៀនអំណានមានភាពខ្វះចន្លោះ បណ្តាលឱ្យលទ្ធផលនៃការសិក្សាអំណាននៅមានកម្រិត។

**៤.៤.១.២. ការអនុវត្តវិធីសាស្ត្របង្រៀន**

**តារាង៤.១៨ ៖ ការអនុវត្តវិធីសាស្ត្របង្រៀន**

| ល.រ | ភាគសំណាក | តម្លៃមធ្យម | គម្លាតស្តង់ដា | អត្ថន័យ |
|---|---|---|---|---|
| ១ | គណៈគ្រប់គ្រងសាលារៀន | ៣.៤៩ | ០.៤៧ | មធ្យម |
| ២ | គ្រូបង្រៀនវិទ្យាសាស្ត្រសង្គម | ៣.៦៦ | ០.៤៧ | ខ្ពស់ |
| ៣ | សិស្សានុសិស្ស | ៣.៣២ | ០.៥៥ | មធ្យម |
| **សរុប** | | **៣.៤៩** | **០.៤៩** | **មធ្យម** |

តាមតារាង៤.១៨ បានបង្ហាញចម្លើយ និងលទ្ធផលនៃការស្រាវជ្រាវទាក់ទងនឹងការអនុវត្តវិធីសាស្ត្របង្រៀនអំណានភាសាខ្មែរ ដោយចម្លើយរួមរបស់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និងសិស្សានុសិស្ស គឺការអនុវត្តវិធីសាស្ត្របង្រៀនអំណានភាសាខ្មែរស្ថិតក្នុងកម្រិតមធ្យម(មធ្យមភាគពិន្ទុ=៣.៤៩)។

តម្លៃមធ្យមជារួម(៣.៤៩)នេះមានន័យថា ការអនុវត្តវិធីសាស្ត្របង្រៀនអំណានភាសាខ្មែរនៅកម្រិតមធ្យមសិក្សាបឋមភូមិគឺអនុវត្តមិនទាន់បានល្អនៅឡើយទេ គឺបានត្រឹមមធ្យមប៉ុណ្ណោះ។ កម្រិតលទ្ធផលនេះ ឆ្លុះបញ្ចាំងតាមរយៈសូចនាករសំខាន់ៗជាច្រើនដូចជា ការបង្ហាញវត្ថុបំណងមេរៀនអំណានច្បាស់លាស់ គ្រូបានពិនិត្យសិស្សក្នុងពេលអានជាក្រុម ឬជាដៃគូ ឬជាបុគ្គល ការអានឮបណ្តាក់គ្នាដែលបានអនុវត្តយ៉ាងរលូនតាមផែនការកំណត់ និងមានភាពស៊ីចង្វាក់គ្នារវាងគណៈគ្រប់គ្រង លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស។

ផ្ទុយមកវិញ តាមលទ្ធនៃការសិក្សា ក៏បានបញ្ជាក់នៅក្នុងសូចនាករមួយចំនួនដែលសាលាអនុវត្ត នៅមានកម្រិតដូចជា ការផ្លាស់ប្តូរវិធីសាស្ត្រដោយប្រើល្បែងសិក្សាពីអំណាន ការលេងល្បែងសិក្សា(ដើរតួ ប្រកួតអានពាក្យពិបាក ទាយពាក្យ) ការអានស្ទាបសម្រាប់សិស្សពិការ ដែលសូចនាករទាំងនេះបានជះឥទ្ធិពលអវិជ្ជមានខ្លះ ធ្វើឱ្យដំណើរការបង្រៀន និងរៀនអំណានមានភាពខ្វះចន្លោះ បណ្តាលឱ្យលទ្ធផលនៃការសិក្សាអំណាននៅមានកម្រិត។

### ៤.៤.១.៣. ដំណើរការ និងសកម្មភាពបង្រៀន និងរៀនអំណាន(ជាក់ស្តែង)

**តារាង៤.១៩៖ ដំណើរការ និងសកម្មភាពបង្រៀន និងរៀនអំណាន(ជាក់ស្តែង)**

| ល.រ | ភាគសំណាក | តម្លៃមធ្យម | គម្លាតស្តង់ដា | អត្ថន័យ |
|---|---|---|---|---|
| ១ | គណៈគ្រប់គ្រងសាលារៀន | ៣.៦១ | ០.៣៩ | ខ្ពស់ |
| ២ | គ្រូបង្រៀនវិទ្យាសាស្ត្រសង្គម | ៣.៥៨ | ០.៤២ | ខ្ពស់ |
| ៣ | សិស្សានុសិស្ស | ៣.៨៥ | ០.៥២ | ខ្ពស់ |
| **សរុប** | | **៣.៦៨** | **០.៤៤** | **ខ្ពស់** |

តាមតារាង៤.១៩ បានបង្ហាញចម្លើយ និងលទ្ធផលនៃការស្រាវជ្រាវទាក់ទងនឹងដំណើរការ និងសកម្មភាពបង្រៀន និងរៀនអំណាន(ជាក់ស្តែង) ដោយចម្លើយរួមរបស់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និងសិស្សានុសិស្ស គឺដំណើរការ និងសកម្មភាពបង្រៀន និងរៀនអំណាន(ជាក់ស្តែង)ស្ថិតក្នុងកម្រិតខ្ពស់(មធ្យមភាគពិន្ទុ=៣.៦៨)។

តម្លៃមធ្យមជារួម(៣.៦៨)នេះមានន័យថា ដំណើរការ និងសកម្មភាពបង្រៀន និងរៀនអំណាន(ជាក់ស្តែង)នៅកម្រិតមធ្យមសិក្សាបឋមភូមិគឺអនុវត្តបានល្អ។ កម្រិតលទ្ធផលនេះ ឆ្លុះបញ្ចាំងតាមរយៈសូចនាករសំខាន់ៗជាច្រើនដូចជា គ្រូបង្រៀនអំណានមានសមត្ថភាពសបស្របតាមកម្រិតវិជ្ជាជីវៈ អនុវត្តការបង្រៀនអំណានតាមដំណាក់កាលជាប្រចាំ(មុនពេល ក្នុងពេល និងក្រោយពេលអំណាន) គ្រូលើក

ទឹកចិត្តសិស្សពេលបង្រៀនអំណាន ដែលបានអនុវត្តយ៉ាងរលូនតាមផែនការកំណត់ និងមានភាពស៊ីចង្វាក់គ្នារវាងគណៈគ្រប់គ្រង លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស។

ផ្ទុយមកវិញ តាមលទ្ធនៃការសិក្សា ក៏បានបញ្ជាក់នៅក្នុងសូចនាករមួយចំនួនដែលសាលាអនុវត្តនៅមានកម្រិតដូចជា រៀបចំកម្មវិធីបំប៉នបន្ថែមចំពោះសិស្សខ្សោយអំណាន ការរៀបចំកម្មវិធីការប្រឡងប្រកួតប្រជែងផ្នែកអំណានតាមកម្រិត ដែលសូចនាករទាំងនេះបានជះឥទ្ធិពលអវិជ្ជមាន ធ្វើឱ្យដំណើរការបង្រៀន និងរៀនអំណានមានភាពខ្វះចន្លោះ បណ្តាលឱ្យលទ្ធផលនៃការសិក្សាអំណាននៅមានកម្រិត។

### ៤.៤.១.៤. ការប្រើប្រាស់សម្ភារៈបង្រៀន និងសម្ភារៈឧបទេស

**តារាង៤.២០៖ ការប្រើប្រាស់សម្ភារៈបង្រៀន និងសម្ភារៈឧបទេស**

| ល.រ | ភាគសំណាក | តម្លៃមធ្យម | គម្លាតស្តង់ដា | អត្ថន័យ |
|---|---|---|---|---|
| ១ | គ្រូបង្រៀនវិទ្យាសាស្ត្រសង្គម | ៣.៦៣ | ០.៣៧ | ខ្ពស់ |
| ២ | សិស្សានុសិស្ស | ៣.៨១ | ០.៤៨ | ខ្ពស់ |
| **សរុប** | | **៣.៧២** | **០.៤២** | **ខ្ពស់** |

តាមតារាង៤.២០ បានបង្ហាញចម្លើយ និងលទ្ធផលនៃការស្រាវជ្រាវទាក់ទងនឹងការប្រើប្រាស់សម្ភារៈបង្រៀន និងសម្ភារៈឧបទេស ដោយចម្លើយរួមរបស់គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និងសិស្សានុសិស្ស គឺការប្រើប្រាស់សម្ភារៈបង្រៀន និងសម្ភារៈឧបទេស ស្ថិតក្នុងកម្រិតខ្ពស់(មធ្យមភាគពិន្ទុ= ៣.៧២)។

តម្លៃមធ្យមជារួម(៣.៧២)នេះមានន័យថា ការប្រើប្រាស់សម្ភារៈបង្រៀន និងសម្ភារៈឧបទេសអនុវត្តបានល្អ។ កម្រិតលទ្ធផលនេះ ឆ្លុះបញ្ចាំងតាមរយៈសូចនាករសំខាន់ៗជាច្រើនដូចជា សៀវភៅសិក្សាគោល(ភាសាខ្មែរ) វចនានុក្រមភាសាខ្មែរ សៀវភៅគ្រូ បណ្ណសំណួរ បណ្ណរូបភាព/ ផ្ទាំងក្រដាសផ្ទាំង ដែលបានអនុវត្តយ៉ាងរលូនតាមផែនការកំណត់ និងមានភាពស៊ីចង្វាក់គ្នារវាងគណៈគ្រប់គ្រង លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស។

ផ្ទុយមកវិញ តាមលទ្ធនៃការសិក្សា ក៏បានបញ្ជាក់នៅក្នុងសូចនាករមួយចំនួនដែលសាលាអនុវត្ត នៅមានកម្រិតដូចជា សៀវភៅរឿងអប់រំខ្លីៗ ឯកសារជាភាសាខ្មែរសម្រាប់សិស្សអានក្នុងបណ្ណាល័យ ដែលសូចនាករទាំងនេះបានជះឥទ្ធិពលអវិជ្ជមាន ធ្វើឱ្យដំណើរការបង្រៀន និងរៀនអំណានមានភាពខ្វះចន្លោះ បណ្តាលឱ្យលទ្ធផលនៃការសិក្សាអំណាននៅមានកម្រិត។

### ៤.៤.១.៥. ការវាយតម្លៃលទ្ធផលសិក្សា

**តារាង៤.២១៖ ការវាយតម្លៃលទ្ធផលសិក្សា**

| **ល.រ** | **ភាគសំណាក** | **តម្លៃមធ្យម** | **គម្លាតស្តង់ដា** | **អត្ថន័យ** |
|---|---|---|---|---|
| ១ | គ្រូបង្រៀនវិទ្យាសាស្ត្រសង្គម | ៣.៣១ | ០.៥១ | មធ្យម |
| ២ | សិស្សានុសិស្ស | ៣.៤៩ | ០.៧៣ | មធ្យម |
| **សរុប** | | **៣.៤០** | **០.៦២** | **មធ្យម** |

តាមតារាង៤.២១ បានបង្ហាញចម្លើយ និងលទ្ធផលនៃការស្រាវជ្រាវទាក់ទងនឹងការវាយតម្លៃលទ្ធផលសិក្សាអំណាន ដោយចម្លើយរួមរបស់គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និងសិស្សានុសិស្ស គឺការវាយតម្លៃលទ្ធផលសិក្សាអំណាន ស្ថិតក្នុងកម្រិតមធ្យម(មធ្យមភាគពិន្ទុ=៣.៤០)។

តម្លៃមធ្យមជារួម(៣.៤៩)នេះមានន័យថា ការវាយតម្លៃ លទ្ធផលសិក្សាអំណាននៅកម្រិតមធ្យមសិក្សាបឋមភូមិគឺអនុវត្តមិនទាន់បានល្អនៅឡើយទេ គឺបានត្រឹមមធ្យមប៉ុណ្ណោះ។ កម្រិតលទ្ធផលនេះ ឆ្លុះបញ្ចាំងតាមរយៈសូចនាករសំខាន់ៗជាច្រើនដូចជា សំណួរផ្ទាល់មាត់ក្នុងម៉ោងបង្រៀនអំណានជាប្រចាំ

សំណួរខ្លីៗពេលម៉ោងបង្រៀនអំណាន កិច្ចការផ្ទះមេរៀនសិក្សាអត្ថបទអំណាន សិស្សអានយល់ន័យអត្ថបទដើម្បីឆ្លើយសំណួរបានត្រឹមត្រូវ ដែលបានអនុវត្តយ៉ាងរលូនតាមផែនការកំណត់ និងមានភាពស៊ីចង្វាក់គ្នារវាងគណៈគ្រប់គ្រង លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស។

ផ្ទុយមកវិញ តាមលទ្ធនៃការសិក្សា ក៏បានបញ្ជាក់នៅក្នុងសូចនាករមួយចំនួនដែលសាលាអនុវត្តនៅមានកម្រិតដូចជា ការប្រឡងប្រចាំខែ ការដាក់ពិន្ទុលើការអានប្រកបពាក្យឮៗ ការដាក់ពិន្ទុលើការអាន

លឿន និងស្ទាត់ ដែលសូចនាករទាំងនេះបានជះឥទ្ធិពលអវិជ្ជមាន ធ្វើឱ្យដំណើរការបង្រៀន និងរៀនអំណានមានភាពខ្វះចន្លោះ បណ្តាលឱ្យលទ្ធផលនៃការសិក្សាអំណាននៅមានកម្រិត។

### ៤.៤.២. បញ្ហាប្រឈមលើការបង្រៀន និងរៀនអំណាន

#### ៤.៤.២.១. បញ្ហាអវិជ្ជមាននានា(ចំណុចមិនសូវអនុវត្ត)

**តារាង៤.២២៖ បញ្ហាអវិជ្ជមាននានា(ចំណុចមិនសូវអនុវត្ត) លើការបង្រៀនអំណានភាសាខ្មែរ**

| ក្រុមគោលដៅ | បញ្ហាប្រឈម | តម្លៃមធ្យម | តារាង |
|---|---|---|---|
| គណៈគ្រប់គ្រងសាលា | ការផ្លាស់ប្តូរវិធីសាស្ត្រ ដោយប្រើល្បែងសិក្សាពីអំណាន | ១.៩៣ | ៤.២ |
| | ការបង្កើតឱ្យមានក្លឹបសិក្សាដើម្បីឱ្យសិស្សពូកែជួយសិស្សខ្សោយ(អំណាន) | ២.៣៣ | ៤.១ |
| | ការចែកកាលវិភាគឱ្យមានម៉ោងបណ្ណាល័យដើម្បីលើកកម្ពស់គុណភាពបង្រៀនអំណាន | ២.០០ | ៤.១ |
| គ្រូបង្រៀន | ការបែងចែកកាលវិភាគឱ្យមានម៉ោងបណ្ណាល័យដើម្បីលើកកម្ពស់គុណភាពបង្រៀនអំណាន | ២.១៤ | ៤.៤ |
| | ការរៀនវគ្គបំប៉នស្រាវជ្រាវបន្ថែមលើការបង្រៀនអំណានភាសាខ្មែរ | ១.៨៦ | ៤.៤ |
| | ការផ្លាស់ប្តូរវិធីសាស្ត្រដោយប្រើល្បែងសិក្សាពីអំណាន | ២.៤៣ | ៤.៥ |
| | ការរៀបចំកម្មវិធីបំប៉នបន្ថែមចំពោះសិស្សខ្សោយអំណាន | ១.៧១ | ៤.៦ |
| | រៀបចំកម្មវិធីការប្រឡង ប្រកួតប្រជែងផ្នែកអំណានតាមកម្រិត | ១.៤៣ | ៤.៦ |
| សិស្សានុសិស្ស | កាលវិភាគសិក្សាមានម៉ោងបណ្ណាល័យសម្រាប់ប្អូនចូលពង្រឹងអំណានបន្ថែម | ២.១៦ | ៤.១១ |
| | ការលេងល្បែងសិក្សា(ដើរតួ ប្រកួតអានពាក្យពិបាក ទាយពាក្យ) | ២.១៤ | ៤.១២ |
| | ការជួយបំប៉នបន្ថែមចំពោះសិស្សខ្សោយអំណាននៅពេលចេញលេង | ២.២៣ | ៤.១៣ |
| | គ្រូណែនាំសិស្សឱ្យចូលរួមការប្រឡង ប្រកួតប្រជែងផ្នែកអំណានតាមកម្រិត | ២.១៦ | ៤.១៣ |

តាមតារាងតួលេខខាងលើនេះ បានបង្ហាញចម្លើយរបស់គណៈគ្រប់គ្រងសាលា គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គ និងសិស្សានុសិស្សទាំងបីអនុវិទ្យាល័យ និងលទ្ធផលនៃការស្រាវជ្រាវ ទាក់ទងនឹងបញ្ហាអវិជ្ជមាននានា(ចំណុចមិនសូវអនុវត្ត)ដែលបញ្ហាប្រឈមក្នុងការបង្រៀន និងរៀនភាសាខ្មែរផ្នែកអំណានរបស់សិស្សនៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងក្របខ័ណ្ឌស្រាវជ្រាវនេះដូចជា៖

- គ្មានម៉ោងបណ្ណាល័យដើម្បីលើកកម្ពស់គុណភាពបង្រៀន និងរៀនអំណានអំណាន
- គ្មានវគ្គបំប៉នស្រាវជ្រាវបន្ថែមលើវិធីសាស្ត្រនៃការបង្រៀនអំណានភាសាខ្មែរ
- គ្មានការរៀបចំកម្មវិធីបំប៉នបន្ថែមចំពោះសិស្សខ្សោយអំណាន
- គ្មានការផ្លាស់ប្តូរវិធីសាស្ត្រ ដោយប្រើល្បែងសិក្សាពីអំណាន
- គ្មានការរៀបចំកម្មវិធីការប្រឡង ប្រកួតប្រជែងផ្នែកអំណានតាមកម្រិត

ម្យ៉ាងទៀត តាមរយៈចម្លើយរបស់គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម(តារាង៤.៩)បានបង្ហាញឱ្យឃើញពីបញ្ហាប្រឈមខ្ពស់ជាងគេមួយគឺ សិស្សខ្លះខ្សោយអំណានប្រកបពាក្យមិនចេញ មិនចេះស្រៈ និងព្យញ្ជនៈបានគ្រប់គ្នា(Meam=៤.១៤)។ ចំណែកឯចម្លើយរបស់សិស្សានុសិស្ស (តារាង៤.១៥)ក៏បានបង្ហាញឱ្យឃើញពីបញ្ហាប្រឈមខ្ពស់ជាងគេមួយគឺ អត្ថបទអំណានក្នុងសៀវភៅសិក្សាគោលមិនសមស្របនឹងរយៈពេលកំណត់(ពេលខ្លី) (Meam=៣.៥៧)។

#### ៤.៤.២.២. បញ្ហាប្រឈមរួមសំខាន់ៗ

ផ្អែកលើព័ត៌មានដែលទទួលបានពីគណៈគ្រប់គ្រងសាលា គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និង សិស្សានុសិស្សក្នុងក្របខ័ណ្ឌស្រាវជ្រាវខាងលើបានបង្ហាញថា មានបញ្ហាប្រឈមលើការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណានសំខាន់ៗជាច្រើនដែលត្រូវដោះស្រាយ។ បញ្ហាប្រឈមទាំងនោះមានដូចជា

- គ្មានម៉ោងបណ្ណាល័យដើម្បីលើកកម្ពស់គុណភាពបង្រៀនអំណាន

- គ្មានវគ្គបំប៉នស្រាវជ្រាវបន្ថែមលើវិធីសាស្ត្រនៃការបង្រៀនអំណានភាសាខ្មែរ
- គ្មានការរៀបចំកម្មវិធីបំប៉នបន្ថែមចំពោះសិស្សខ្សោយអំណាន
- គ្មានការផ្លាស់ប្តូរវិធីសាស្ត្រ ដោយប្រើល្បែងសិក្សាពីអំណាន
- គ្មានការរៀបចំកម្មវិធីការប្រឡង ប្រកួតប្រជែងផ្នែកអំណានតាមកម្រិត
- សិស្សខ្លះខ្សោយអំណានប្រកបពាក្យមិនចេញ មិនចេះស្រៈនិងព្យញ្ជនៈបានគ្រប់គ្នា
- ខ្លឹមសារអត្ថបទអំណានក្នុងសៀវភៅសិក្សាគោលមិនសូវសមស្របនឹងរយៈពេលកំណត់(ពេលខ្លី)

## ៤.៥. ការពិភាក្សា

### ៤.៥.១. ការពិភាក្សាលើសំណួរស្រាវជ្រាវទី១

តាមរយៈលទ្ធផលនៃសំណួរស្រាវជ្រាវទីមួយខាងលើ បង្ហាញពីការឆ្លើយតបទៅនឹងគោលបំណងស្រាវជ្រាវទីមួយ ដែលការសិក្សាស្រាវជ្រាវបានផ្តោតសំខាន់ទៅលើស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ។ លទ្ធផលជារួមបានបង្ហាញឱ្យឃើញថា ស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវបានបានយកចិត្តកម្រិតខ្ពស់ ដោយមើលទៅលើផ្នែកផ្សេងៗដូចជា ការអនុវត្តកម្មវិធីសិក្សា(**តារាង៤.១៧**) វិធីសាស្ត្របង្រៀន(**តារាង៤.១៨**) ដំណើរការ និងសកម្មភាពបង្រៀន និងរៀនអំណានជាក់ស្តែង(**តារាង៤.១៩**) ការប្រើប្រាស់ សម្ភារៈបង្រៀន និងសម្ភារៈឧបទេស(**តារាង៤.២០**) ការវាយតម្លៃលទ្ធផលសិក្សា(**តារាង៤.២១**)។

ការរកឃើញនេះយើងអាចនិយាយបានថា ស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិមានភាពវិជ្ជមានច្រើនជាងមុន បើប្រៀបធៀបនឹងការលើកឡើងផ្អែកតាមទំព័រហ្វេសប៊ុកផ្លូវការ MoEYS Cambodia របស់ក្រសួងអប់រំ យុវជន និងកីឡា នៅថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១៧ ស្តីពីវប្បធម៌អំណាននៅកម្ពុជា និងតួនាទីអំណានក្នុងវិស័យអប់រំ បានបញ្ជាក់ថា ការសិក្សាស្រាវជ្រាវតាមសាលាស្តីពីតេស្តស្តង់ដាថ្នាក់ទី៣(ឆ្នាំ២០១១) ស្រាវជ្រាវលើការអនុវត្តម៉ោង

បង្រៀនសាលាបឋមសិក្សាថ្នាក់ទី១ ដល់ទី៦(ឆ្នាំ២០១០) និងស្រាវជ្រាវលើការអនុវត្តម៉ោងបង្រៀនសាលាមធ្យមសិក្សាបឋមភូមិថ្នាក់ទី៧ ដល់ទី៩(ឆ្នាំ២០០៩)ឃើញថា ការអានរបស់សិស្សបានស្រុតចុះយ៉ាងខ្លាំង។

ភាពវិជ្ជមាននៃស្ថានភាពបង្រៀន និងរៀនអំណាននេះ បានឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់ខ្ពស់របស់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន សិស្សានុសិស្ស ក៏ដូចជាភាគីពាក់ព័ន្ធផ្សេងទៀត។ ជាពិសេសទៅទៀត លទ្ធផលទាំងនេះក៏បានឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការលើកស្ទួយអំណាននៅកម្ពុជា ក្នុងនោះរួមទាំងការបង្កើតឱ្យមានទិវាជាតិអំណាន ដោយបានចេញអនុក្រឹត្យលេខ ១២០អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីទិវាជាតិអំណាន កំណត់យកថ្ងៃទី១១ ខែមីនា រៀងរាល់ឆ្នាំជាទិវាជាតិអំណាននៃព្រះរាជាណាចក្រកម្ពុជា។

#### ៤.៥.២. ការពិភាក្សាលើសំណួរស្រាវជ្រាវទី២

នៅក្នុងសំណួរស្រាវជ្រាវទី២ទាក់ទងនឹងបញ្ហាប្រឈមជាក់ស្តែងលើការបង្រៀន និងរៀនសមត្ថភាពអំណាននៅសាលាមធ្យមសិក្សាបឋមភូមិ។ ជាលទ្ធផលបានឆ្លើយតបខ្ពស់ទៅនឹងសំណួរដែលបានកំណត់។ បញ្ហាទាំងនោះរកឃើញតាមរយៈចំណុចអវិជ្ជមានខ្លះៗដែលអ្នកពាក់ព័ន្ធមិនសូវបានអនុវត្ត នាំឱ្យតម្លៃមធ្យម(Mean)ទាបមានដូចជា មិនទាន់មានម៉ោងបណ្ណាល័យដើម្បីលើកកម្ពស់គុណភាពបង្រៀនអំណាន(**តារាង៤.១ តារាង៤.៤ និងតារាង៤.១១**) គ្មានការផ្លាស់ប្តូរវិធីសាស្ត្របង្រៀនដោយសារមិនមានវគ្គបំប៉នស្រាវជ្រាវបន្ថែមលើវិធីសាស្ត្រនៃការបង្រៀនអំណានភាសាខ្មែរ(**តារាង៤.២ តារាង៤.៤ តារាង៤.៥ និងតារាង៤.១២**) គ្មានការរៀបចំកម្មវិធីបំប៉នបន្ថែមចំពោះសិស្សខ្សោយអំណាន(**តារាង៤.១ តារាង៤.៦ និងតារាង៤.១៣**) គ្មានការរៀបចំកម្មវិធីការប្រឡង ប្រកួតប្រជែងផ្នែកអំណានតាមកម្រិត(**តារាង៤.៦ និងតារាង៤.១៣**)។

ក្រៅពីនេះ នៅមានកត្តាដែលជះឥទ្ធិពលអវិជ្ជមានផ្សេងទៀតដូចជា កត្តាសិស្សខ្លួនឯងខ្វះការយកចិត្តក្នុងការអាននាំឱ្យពួកគាត់ប្រកបពាក្យមិនចេញ មិនចេះស្រៈនិងព្យញ្ជនៈបានគ្រប់គ្នា(**តម្លៃមធ្យម=**

**៤.១៧ ក្នុងតារាង៤.៩**) ម្យ៉ាងទៀត ខ្លឹមសារអត្ថបទអំណានក្នុងសៀវភៅសិក្សាគោលហាក់មិនសូវសមស្របនឹងរយៈពេលកំណត់ ដោយអត្ថបទវែង តែរយៈពេលផ្តល់ឱ្យពេលខ្លី (**តម្លៃមធ្យម=៣.៥៧ ក្នុងតារាង ៤.១៥**) ។

ដូចនេះ បញ្ហាប្រឈមនានាដែលបានរកឃើញខាងលើ គឺជាគន្លឹះសំខាន់ដែលនាំទៅរកវិធានការដោះស្រាយចំគោលដៅ និងមានប្រសិទ្ធភាពក្នុងការលើកកម្ពស់សមត្ថភាពអំណានរបស់សិស្សនៅសាលាមធ្យមសិក្សាបឋមភូមិ។

# ជំពូក ៥

# សេចក្តីសន្និដ្ឋាន និង សំណូមពរ

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និង សំណូមពរ

## ៥.១. សេចក្តីសន្និដ្ឋាន

តាមរយៈការវិភាគ និងការពិភាក្សាលើលទ្ធផលនៃការស្រាវជ្រាវខាងលើនេះ យើងអាចសន្និដ្ឋានបានថា ស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ មានកម្រិតល្អច្រើនគួរឱ្យកត់សម្គាល់ ទាំងលើផ្នែកអនុវត្តកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន ដំណើរការសកម្មភាពបង្រៀន និងរៀនជាក់ស្តែង រួមទាំងការប្រើប្រាស់សម្ភារៈឧបទេស និងសម្ភារៈបង្រៀន និងការវាយតម្លៃលទ្ធផលសិក្សាអំណានភាសាខ្មែរ។ ស្ថានភាពវិជ្ជមាននេះ ក៏អាចឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងអនុវត្តគោលនយោបាយនៃទិវាជាតិអំណានបានមួយកម្រិតដែរ។ លទ្ធផលនេះមានការឆ្លើយតបបានល្អទៅនឹងអ្វីដែលអ្នកសិក្សាស្រាវជ្រាវកំពុងស្វែងរក ដើម្បីបានចូលរួមជាចំណែកដ៏តូចមួយក្នុងការកែលម្អស្ថានភាពបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាន នៅសាលាមធ្យមសិក្សាបឋមភូមិទាំងនេះឱ្យមានការរីកចម្រើនឡើង។

ទន្ទឹមនឹងនេះចំណុចល្អទាំងនេះ អ្នកស្រាវជ្រាវបានរកឃើញនូវចំណុចមួយចំនួនដែលគួរតែធ្វើឱ្យមានភាពប្រសើរឡើង។ ចំណុចទាំងនោះមានដូចជា មិនទាន់មានម៉ោងបណ្ណាល័យដើម្បីលើកកម្ពស់គុណភាពបង្រៀនអំណាន គ្មានវគ្គបំប៉នស្រាវជ្រាវបន្ថែមលើវិធីសាស្ត្របង្រៀនថ្មីៗស្តីពីអំណានភាសាខ្មែរ គ្មានការរៀបចំកម្មវិធីបំប៉នបន្ថែមចំពោះសិស្សខ្សោយអំណាន គ្មានការផ្លាស់ប្តូរវិធីសាស្ត្រ ដោយប្រើល្បែងសិក្សាពីអំណាន គ្មានការរៀបចំកម្មវិធីការប្រឡង ប្រកួតប្រជែងផ្នែកអំណានតាមកម្រិត សិស្សខ្លះខ្សោយអំណានប្រកបពាក្យមិនចេញ មិនចេះស្រៈនិងព្យញ្ជនៈបានគ្រប់គ្នា ខ្លឹមសារអត្ថបទអំណានក្នុងសៀវភៅសិក្សាគោលមិនសូវសមស្របនឹងរយៈពេលកំណត់(ពេលខ្លី)។

## ៥.២. សំណូមពរ

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ និងជួយបង្កើនគុណភាព និងប្រសិទ្ធភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាន នៅកម្រិតមធ្យមសិក្សាបឋមភូមិនាពេលបច្ចុប្បន្ន អ្នកសិក្សាស្រាវជ្រាវបានលើកជាសំណូមពរមួយចំនួនដូចខាងក្រោម ៖

### ៥.២.១. ចំពោះក្រសួងអប់រំ យុវជន និងកីឡា

- សូមរៀបចំបង្កើតឱ្យមានម៉ោងបណ្ណាល័យក្នុងបំណែងចែកភារកិច្ច ដើម្បីឱ្យថ្នាក់ក្រោមអនុវត្ត
- សូមរៀបចំវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របង្រៀនអំណានឱ្យបានញឹកញាប់
- សូមបង្កើនម៉ោងមុខវិជ្ជាភាសាខ្មែរបន្ថែម ឬបង្កើតម៉ោងអំណានដាច់ដោយឡែក

### ៥.២.២. ចំពោះមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត

- សូមអន្តរាគមន៍ និងពិនិត្យតាមដានជាប្រចាំទៅលើការបង្រៀន និងរៀនអំណានតាមសាលារៀន
- សូមពង្រឹង និងធ្វើអធិការកិច្ចឱ្យបានញឹកញាប់នៅតាមសាលារៀនដោយផ្តោតសំខាន់ទៅលើវិធីសាស្ត្របង្រៀនអំណាន ការប្រើប្រាស់សម្ភារៈឧបទេស ជាពិសេសការជួយសិស្សរៀនយឺតផ្នែកអំណាន

### ៥.២.៣. ចំពោះគណៈគ្រប់គ្រងសាលារៀន

- សូមពិនិត្យតាមដានការបង្រៀន និងរៀនអំណានឱ្យបានញឹកញាប់ និងទៀងទាត់
- សូមលើកទឹកចិត្តគ្រូបង្រៀនឱ្យរកវិធីសាស្ត្របង្រៀនអំណានថ្មីៗតាមរយៈការប្រជុំក្រុមបច្ចេកទេសប្រចាំខែនីមួយៗ

### ៥.២.៤. ចំពោះលោកគ្រូ អ្នកគ្រូ

- សូមស្វ័យសិក្សាស្រាវជ្រាវពីវិធីសាស្ត្របង្រៀនណាដែលថ្មីៗជាប្រចាំ ពង្រឹងចំណេះដឹង ជំនាញទៅលើអ្វីដែលខ្លួនមានស្រាប់
- សូមរៀបចំបង្កើត និងចូលរួមជួយបំប៉នសិស្សខ្សោយអំណានប្រកបដោយមនសិការវិជ្ជាជីវៈ

### ៥.២.៥. ចំពោះអាណាព្យាបាលសិស្ស និងសហគមន៍

- សូមចូលរួមសហការជាមួយសាលារៀនក្នុងការពិនិត្យតាមដាន និងយកចិត្តទុកដាក់លើការ សិក្សារបស់កូន ជាពិសេសគឺការផ្តល់ព័ត៌មានទៅវិញទៅមកជាមួយសាលារៀន ប្រកបដោយទំនុកចិត្ត
- សូមរួមចំណែកក្នុងការជួយឧបត្ថម្ភគាំទ្រទាំងថវិកា សម្ភារៈ ស្មារតី សកម្មភាពដល់ សាលារៀនតាមលទ្ធភាព ក្នុងគោលដៅរួមគ្នាពង្រឹង និងពង្រីកការអប់រំក្នុងមូលដ្ឋាន

### ៥.២.៦. ចំពោះសិស្សានុសិស្ស

- សូមពង្រឹងសមត្ថភាពរបស់ខ្លួនឱ្យស្ទាត់ជំនាញទៅលើផ្នែកអំណានភាសាខ្មែរ ដើម្បីងាយស្រួលក្នុងការសិក្សាមុខវិជ្ជាផ្សេងៗទៀតបានកាន់តែប្រសើរនិងអាចបន្តការសិក្សានៅកម្រិតឧត្តមសិក្សា ក្នុងគោលដៅឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន និងទៅអនាគត
- សូមរៀបគោលដៅជីវិត ដោយចាប់ផ្តើមពី ផែនការក្នុងការសិក្សាដូចជា ការរៀបចំកាលវិភាគ និងសេវាសិក្សាបន្ថែមប្រកបដោយស្វ័យភាព ដោយរៀបចំ ម៉ោងស្វ័យសិក្សា ការធ្វើកិច្ចការផ្ទះ និងការធ្វើគម្រោងស្រាវជ្រាវផ្សេងៗ។

## ៥.៣. ការស្រាវជ្រាវបន្ត

ការសិក្សាស្រាវជ្រាវមួយនេះបានធ្វើឡើងតែលើស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិចំនួនបី ក្នុងស្រុកសំរោង ខេត្តតាកែវប៉ុណ្ណោះ។ ដូច្នេះលទ្ធផលដែលរកឃើញមិនអាចឆ្លើយតបទៅគ្រប់សាលា ក្នុងស្រុក ឬក្នុងខេត្តឡើយ។ ហេតុនេះហើយអ្នកសិក្សាស្រាវជ្រាវក្រោយៗដែលមានបំណងចង់សិក្សាស្រាវជ្រាវបន្តលើប្រធានបទនេះ គួរតែពង្រីកដែនកំណត់ និងវិសាលភាពរបស់ខ្លួនឱ្យបានធំជាងនេះ ប្រសិនបើនៅតែមានបំណងចង់សិក្សានៅក្នុងខេត្តតាកែវដដែល។ ក្រៅពីនេះ អ្នកសិក្សាស្រាវជ្រាវក្រោយៗក៏អាចយកប្រធានបទនេះទៅសិក្សានៅតំបន់ទីប្រជុំជន ឬតំបន់ដាច់ស្រយាលនៅតាមបណ្តាខេត្តនានាផងដែរ ដោយសារតែគុណភាពសាសារៀន គុណភាពគ្រូបង្រៀន និងចំណេះដឹងភាសាខ្មែររបស់សិស្សនៅទីនោះអាចមានភាពខុសគ្នាឆ្ងាយពីស្ថានភាពនៅក្នុងសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវក្នុងក្របខ័ណ្ឌស្រាវជ្រាវនេះ។

# ឯកសារយោង

# ឯកសារយោង

ក្រសួងអប់រំ យុវជន និងកីឡា. (២០១០). *ឯកសារបំប៉នសមត្ថភាពគ្រូបង្រៀនមុខវិជ្ជាភាសាខ្មែរនៅអនុវិទ្យាល័យ.* ភ្នំពេញ. ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៤). *(ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨.* ភ្នំពេញ. ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៥). *ផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ.* ភ្នំពេញ. ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩). *ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣,.* ភ្នំពេញ. ក្រសួងអប់រំ យុវជន និងកីឡា

គរុនិស្សិតអក្សរសាស្ត្រខ្មែរជំនាន់ទី២០ក្រុម៤ . (២០១៥). *គរុនិស្សិតអក្សរសាស្ត្រវិធីបង្រៀន និងកិច្ចតែងការបង្រៀនភាសាខ្មែរ.* ភ្នំពេញ. វិទ្យាស្ថានជាតិអប់រំ

ជួន ណាត. (១៩៦៧). *វចនានុក្រមខ្មែរភាគ១ និងភាគ២បោះពុម្ពគ្រាទី៥.* ភ្នំពេញ. វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ នៃក្រសួងអប់រំ យុវជន និង កីឡា. (២០១០). *ឯកសារបំប៉នសមត្ថភាពគ្រូបង្រៀននៅអនុវិទ្យាល័យមុខវិជ្ជាភាសាខ្មែរ.* ភ្នំពេញ. ក្រសួងអប់រំ យុវជន និងកីឡា

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា. (២០១៥). *ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស,.* ភ្នំពេញ. ក្រសួងអប់រំ យុវជន និងកីឡា

មនោរម្យ អាំងហ្វូ. (២០១២). *អំណាន ឬ ការអាន.* ភ្នំពេញ: មនោរម្យ អាំងហ្វូ.

យូណេស្កូ. (២០១៥). *វិស័យអប់រំឆ្នាំ២០៣០ សេចក្តីប្រកាសទីក្រុងIncheon និងក្របខ័ណ្ឌសម្រាប់សកម្មភាពឆ្ពោះទៅរកការអប់រំមានគុណភាព បរិយាប័ន្ន សមធម៌ និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា.* Incheon.

រាជរដ្ឋាភិបាលកម្ពុជា. (២០០៨). *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា.* ភ្នំពេញ. កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា. (២០១៥). *អនុក្រឹត្យស្តីពីទិវាជាតិអំណាន,.* ភ្នំពេញ. កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា. (២០១៨). *យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤,*. ភ្នំពេញ.កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា. (២០១៩). *គោលនយោបាយជាតិស្តីពីភាសាខ្មែរ.* ភ្នំពេញ. កម្ពុជា

Blatchford, P. (2003). The class size debate. Is smaller better? Philadelphia: McGraw Hills Education.

Celce-Murcia, M. (2001). Teaching English as a second laguage. Boston: Heinle And Heinle.

Elliot, S., Kratochil, T., and Cook, J. (2000). Eduacational psychology. New York: McGraw-Hill.

Gardner, R. C. (2006). The social-educational model of second language acquisition. A research paradigm, 237-260.

Hong Thi Nguyen, Wendy Warren and Heather Fehring. (2014). Factors Affecting English Language Teaching and Learning in Higher education. English language teaching, 94-105.

Petty, G. (1998). Teaching today. English: Stanley Thornes.

Ryan, M, R. and Deci, E, L. (2000). Intrinsic and Exrinsic motivations: classic definitions and new directions. Contemporary Educational Psychology, 54-67.

Shalaway, L. (2005). Learning to teach not just beginners. New York: Scholastic.

Spatt, M, Pulvemess, A., and Williams, M. (2005). The KTK teaching knowledge test course. Cambridge: Cambridge.

Stern, H. (2001). Fumdamental concepts of language teaching. Oxford: Oxford University Press.

Woodward, T. (2001). Planning lessons and courses: Designing sequences of work for the language classroom. Cambridge: Cambridge University Press.

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ«ក»

## កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលារៀន

ខ្ញុំបាទឈ្មោះ **នូ សុខលៀប** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ។ ខ្ញុំបាទបានរៀបចំការសិក្សាស្រាវជ្រាវមួយទាក់ទងទៅនឹងប្រធានបទ « **ស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ** »ដើម្បីបញ្ចប់ការសិក្សា។

គោលបំណងនៃការប្រមូលទិន្នន័យ ដើម្បីឈ្វេងយល់ពីដំណើរការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាន ដែលផ្តោតលើបញ្ហាប្រឈមទាក់ទងនឹងបំណិននៃការអានរបស់សិស្សនៅមធ្យមសិក្សាបឋមភូមិ និងយុទ្ធសាស្ត្រក្នុងការដោះស្រាយបញ្ហាប្រឈមដើម្បីជំរុញការអនុវត្តការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណានឱ្យមានប្រសិទ្ធភាព។

ទិន្នន័យដែលប្រមូលបានមក គឺប្រើសម្រាប់តែការសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។ ក្នុងន័យនេះ សូមលោកនាយក នាយិកា លោកនាយករង នាយិការង មេត្តាជួយផ្តល់ព័ត៌មានពិតជាក់ស្តែង ដើម្បីឱ្យខ្ញុំបាទអាចមានទិន្នន័យ និងហេតុផលគ្រប់គ្រាន់តាមបែបវិទ្យាសាស្ត្រ ដើម្បីទាញអំណះអំណាងយកមកសិក្សា បកស្រាយទៅលើការសរសេរនិក្ខេបបទក្នុងការសិក្សាស្រាវជ្រាវ។

ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមរបស់លោក លោកស្រី ។

### ផ្នែកទី១៖ ព័ត៌មានទូទៅ

សូមលោក លោកស្រីបំពេញ ដោយគូសសញ្ញា ✓ ក្នុងប្រអប់ □ និងបំពេញចន្លោះតាមភាពជាក់ ស្តែងរបស់លោក លោកស្រី ដែលជ្រើសរើស ។

១. តួនាទី៖.............................................រយៈពេលក្នុងមុខតំណែង៖................................

២. បម្រើការងានៅ៖ អនុវិទ្យាល័យ............................ឃុំ/សង្កាត់៖..........................ស្រុកសំរោង ខេត្តតាកែវ

៣. ភេទ ☐ ប្រុស ☐ ស្រី

៤. អាយុ ☐ ២៥-៣០ ឆ្នាំ ☐ ៣១-៣៥ឆ្នាំ ☐ ៣៦-៤០ឆ្នាំ ☐ លើសពី៤០ឆ្នាំ

៥. កម្រិតវប្បធម៌៖ ☐ ទាបជាងបរិញ្ញាបត្រ ☐ បរិញ្ញាបត្រ ☐ បរិញ្ញាបត្រជាន់ខ្ពស់ ☐ បណ្ឌិត

៦. បទពិសោធន៍ការងារ៖ ☐ តិចជាង៥ឆ្នាំ ☐ ៥ឆ្នាំ ដល់ ១០ឆ្នាំ ☐ ១០ឆ្នាំ ដល់ ២០ឆ្នាំ ☐ ច្រើនជាង ២០ឆ្នាំ

៧. មុខវិជ្ជាឯកទេស៖.................................................................................

## ផ្នែកទី២៖ ដំណើរការនៃការបង្រៀន និងរៀនអំណាន

**ការណែនាំ៖** សំណួរខាងក្រោម គឺចង់ឆ្លុះបញ្ចាំងពីការងារគ្រប់គ្រងក្នុងការអនុវត្តកម្មវិធីសិក្សា និងដំណើរការបង្រៀនមុខវិជ្ជាភាសាខ្មែរ ដោយផ្តោតលើកត្តាប្រឈមនៃការបង្រៀនអំណាន និងភាពខុសប្លែកគ្នាជាមួយមុខវិជ្ជាផ្សេងទៀត ក្នុងក្របខ័ណ្ឌកម្មវិធីសិក្សាកម្រិតបឋមភូមិ។ សូមអានចំណុចនីមួយៗឱ្យបានច្បាស់លាស់ បន្ទាប់មកគូសសញ្ញា (✓) ទៅតាមកម្រិតនៃការពេញចិត្តរបស់លោក-លោកស្រី៖

១. មិនយល់ស្របទាល់តែសោះ

២. មិនយល់ស្រប

៣. មិនមានយោបល់

៤. យល់ស្រប

៥. យល់ស្របខ្លាំង

## ២.១. ការអនុវត្តកម្មវិធីសិក្សា

| ល.រ | ការបរិយាយ | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| | ការពិនិត្យតាមដាន និងកែលម្អការបង្រៀនអំណាន | ៥ | ៤ | ៣ | ២ | ១ |
| ២១ | បានណែនាំគ្រូធ្វើបំណែងចែកកម្មវិធីសិក្សា មុខវិជ្ជាភាសាខ្មែរបានច្បាស់លាស់តាមចំនួនម៉ោងកំណត់ របស់ក្រសួងអប់រំ(៦ម៉ោងក្នុង១សប្តាហ៍) | | | | | |
| ២ | បានពិនិត្យ និងចុះហត្ថលេខាលើបំណែងចែកកម្មវិធីសិក្សា ធ្វើតាមក្រុមមុខវិជ្ជាភាសាខ្មែរ(ផ្នែកអំណាន) | | | | | |
| ៣ | បានត្រួតពិនិត្យកិច្ចតែងការបង្រៀនអំណានតាមកម្រិតថ្នាក់ជាប្រចាំ | | | | | |
| ៤ | បានពិនិត្យតាមដាន លើដំណើរការបង្រៀនរបស់គ្រូ ជាប្រចាំ | | | | | |
| ៥ | បានផ្តល់មតិយោបល់ កែលម្អក្នុងការធ្វើថ្នាក់និទស្សន៍មុខវិជ្ជាភាសាខ្មែរ | | | | | |
| ៦ | បានផ្តល់វគ្គបំប៉នសមត្ថភាព ដល់គ្រូបង្រៀនអំណាន | | | | | |
| ៧ | បានពិនិត្យការប្រើប្រាស់សៀវភៅសិក្សាគោលភាសាខ្មែរគ្រប់កម្រិតថ្នាក់ | | | | | |
| ៨ | បានចូលរួមការប្រជុំក្រុមបច្ចេកទេស ពិនិត្យតាមដាន និងកែលម្អការ អនុវត្តការបង្រៀនអំណានភាសាខ្មែរទៀងទាត់ | | | | | |
| ៩ | បានបែងចែកកាលវិភាគឱ្យមានម៉ោងបណ្ណាល័យដើម្បីលើកកម្ពស់គុណភាពបង្រៀនអំណាន | | | | | |
| ១០ | ការរៀបចំបណ្ណាល័យ (ផ្តល់សម្ភារៈល្បែងសិក្សា)អោយក្លាយជាទីមេត្រីសម្រាប់ការអាន | | | | | |
| ១១ | បង្កើតឱ្យមានក្លឹបសិក្សា ដើម្បីឱ្យសិស្សពូកែជួយសិស្សខ្សោយការរៀន(អំណាន) | | | | | |

## ២.២. វិធីសាស្ត្រ និងសកម្មភាពបង្រៀន និងរៀនអំណាន

### ក. វិធីសាស្ត្របង្រៀន

| ល.រ | លោកគ្រូ អ្នកគ្រូបង្រៀនអំណានភាសាខ្មែរបាន ៖ | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| | | ៥ | ៤ | ៣ | ២ | ១ |
| ១ | បង្ហាញវត្ថុបំណងមេរៀនអំណានច្បាស់លាស់ | | | | | |
| ២ | ផ្តល់ការការណែនាំដល់សិស្ស លើចំណេះដឹងស្តីពីអំណាន | | | | | |
| ៣ | វិធីសាស្ត្របង្រៀនអំណានមាននិយាមច្បាស់លាស់ | | | | | |
| ៤ | ឱ្យសិស្សអានស្ងាត់ ខ្សឹប | | | | | |
| ៥ | ឱ្យសិស្សអានឮៗម្នាក់ឯង ឬដៃគូ | | | | | |
| ៦ | ឱ្យសិស្សអានឮ អានបណ្ដាក់គ្នា(ជាក្រុមតូច) | | | | | |
| ៧ | ឱ្យសិស្សអានស្ដាប(សម្រាប់សិស្សពិការ) | | | | | |
| ៨ | គ្រូបានអានជាគំរូក្នុងការបញ្ចេញសំឡេងតាមអក្ខរក្រម | | | | | |
| ៩ | ផ្លាស់ប្ដូរវិធីសាស្ត្រ ដោយប្រើល្បែងសិក្សាពីអំណាន | | | | | |

### ខ. ដំណើរការ និងសកម្មភាពបង្រៀនអំណានភាសាខ្មែរ(អនុវត្តជាក់ស្តែង)

| | | | | | | |
|---|---|---|---|---|---|---|
| ១ | គ្រូបង្រៀនប្រើប្រាស់កិច្ចតែងការបង្រៀនអំណានថ្មីជាប្រចាំ | | | | | |
| ២ | គ្រូបង្រៀនមានទំនួលខុសត្រូវក្នុងការគោរពពេលវេលា | | | | | |
| ៣ | គ្រូបង្រៀនបានស្រាវជ្រាវបន្ថែមលើការបង្រៀនអំណានភាសាខ្មែរ | | | | | |
| ៤ | គ្រូបង្រៀនមានសមត្ថភាពសបស្រេបតាមកម្រិតវិជ្ជាជីវៈ | | | | | |
| ៥ | ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សមានតម្លាភាព និងផ្ទៀងផ្ទាត់ច្បាស់លាស់ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៦ | មានការបែងចែកម៉ោងអំណាន នៅបណ្ណាល័យ | | | | | |
| ៧ | សិស្សចូលចិត្ត លើការសិក្សាអំណានភាសាខ្មែរ | | | | | |
| ៨ | គ្រូបានណែនាំសិស្សឱ្យមានការរៀនអានបន្ថែម នៅក្រៅម៉ោងសិក្សា នៅក្នុងបណ្ណាល័យ | | | | | |
| ៩ | ជារួម គ្រូបានបង្រៀនអំណានស្របតាមកម្មវិធីសិក្សា | | | | | |
| ១០ | មានការរៀបចំទិវាជាតិអំណាន | | | | | |

**សំណូមពរ ឬ មតិយោបល់បន្ថែម**

១. តើលោក-លោកស្រី មានជួបប្រទះការលំបាកអ្វីខ្លះ ក្នុងការជំរុញអំណានមុខវិជ្ជាភាសខ្មែរ?

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

២. ពេលជួបការលំបាកខាងលើ តើលោក-លោកស្រី បានដោះស្រាយយ៉ាងដូចម្តេចខ្លះ?

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

សូមអរគុណសម្រាប់ការចូលរួមរបស់លោក លោកស្រី!

# ឧបសម្ព័ន្ធ«ខ»

## កម្រងសំណួរសម្រាប់គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម

ខ្ញុំបាទឈ្មោះ **នូ សុខលៀប** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ។ ខ្ញុំបាទបានរៀបចំការសិក្សាស្រាវជ្រាវមួយទាក់ទងទៅនឹងប្រធានបទ « **ស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ** »ដើម្បីបញ្ចប់ការសិក្សា។

គោលបំណងនៃការប្រមូលទិន្នន័យ ដើម្បីឈ្វេងយល់ពីដំណើរការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាន ដែលផ្តោតលើបញ្ហាប្រឈមទាក់ទងនឹងបំណិននៃការអានរបស់សិស្សនៅមធ្យមសិក្សាបឋមភូមិ និងយុទ្ធសាស្ត្រក្នុងការដោះស្រាយបញ្ហាប្រឈមដើម្បីជំរុញការអនុវត្តការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណានឱ្យមានប្រសិទ្ធភាព។

ទិន្នន័យដែលប្រមូលបានមក គឺប្រើសម្រាប់តែការសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។ ក្នុងន័យនេះ សូមលោកគ្រូ អ្នកគ្រូមេត្តាជួយផ្តល់ព័ត៌មានពិតជាក់ស្តែង ដើម្បីឱ្យខ្ញុំបាទអាចមានទិន្នន័យ និងហេតុផលគ្រប់គ្រាន់តាមបែបវិទ្យាសាស្ត្រ ដើម្បីទាញអំណះអំណាងយកមកសិក្សា បកស្រាយទៅលើការសរសេរនិក្ខេបបទក្នុងការសិក្សាស្រាវជ្រាវ។

ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមរបស់លោកគ្រូ អ្នកគ្រូ។

### ផ្នែកទី១៖ ព័ត៌មានទូទៅ

សូមលោកគ្រូ អ្នកគ្រូបំពេញដោយគូសសញ្ញា ✓ ក្នុងប្រអប់ □ និងបំពេញចន្លោះតាមភាពជាក់ ស្តែងរបស់លោកគ្រូ អ្នកគ្រូដែលជ្រើសរើស ។

១. ឈ្មោះសាលា៖ អនុវិទ្យាល័យ............................ឃុំ ៖.............................ស្រុកសំរោង ខេត្តតាកែវ

២. ភេទ៖ □ ប្រុស □ស្រី

៣. អាយុ៖ □ ២០-៣០ ឆ្នាំ □៣១-៤០ឆ្នាំ □ ៤១-៥០ឆ្នាំ □ លើសពី៥០ឆ្នាំ

៤. ក្របខ័ណ្ឌ ៖ ☐ គ្រូបង្រៀនកម្រិតមូលដ្ឋាន ☐ គ្រូបង្រៀនកម្រិតឧត្តម

៥. កម្រិតវប្បធម៌៖ ☐ ទាបជាងបរិញ្ញាបត្រ ☐ បរិញ្ញាបត្រ

☐ បរិញ្ញាបត្រជាន់ខ្ពស់ ☐ បណ្ឌិត

៦. បទពិសោធការងារ៖ ☐ តិចជាង៥ឆ្នាំ ☐ ៥ឆ្នាំ ដល់ ១០ឆ្នាំ

☐ ១០ឆ្នាំ ដល់ ២០ឆ្នាំ ☐ ច្រើនជាង ២០ឆ្នាំ

៧. បង្រៀនថ្នាក់ទី៖ ☐ ក.៧ ☐ខ. ៨ ☐៩ ☐ ផ្សេងទៀត

## ផ្នែកទី២៖ ដំណើរការនៃការបង្រៀន និងរៀនអំណាន

**ការណែនាំ៖** នៅក្នុងបទពិសោធន៍នៃការបង្រៀនលើមុខវិជ្ជាភាសាខ្មែររបស់លោកគ្រូ អ្នកគ្រូកន្លងមក តើលោកគ្រូ អ្នកគ្រូបង្រៀនអំណាននៅកម្រិតមធ្យមសិក្សាបឋមភូមិមានដំណើរការយ៉ាងដូចម្តេច? សូមអានចំណុចនីមួយៗឱ្យបានច្បាស់លាស់ បន្ទាប់មកគូសសញ្ញា(✓) ទៅតាមកម្រិតនៃការពេញចិត្តរបស់លោកគ្រូ អ្នកគ្រូ ៖

កម្រិតចង្អុលបង្ហាញ៖

១. មិនយល់ស្របទាល់តែសោះ

២. មិនយល់ស្រប

៣. មិនមានយោបល់

៤. យល់ស្រប

៥. យល់ស្របខ្លាំង

### ២.១. ការអនុវត្តកម្មវិធីសិក្សា

| ល.រ | ការបរិយាយ | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| | | ៥ | ៤ | ៣ | ២ | ១ |
| ១ | បានរៀបចំបំណែងចែកកម្មវិធីសិក្សា មុខវិជ្ជាភាសាខ្មែរបានច្បាស់លាស់តាមចំនួនម៉ោងកំណត់របស់ក្រសួងអប់រំ(៦ម៉ោងក្នុង១សប្តាហ៍) | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | ការរៀបចំបំណែងចែកកម្មវិធីសិក្សា ធ្វើតាមក្រុមមុខវិជ្ជាភាសាខ្មែរផ្នែកអំណាន យ៉ាងតិច ២ម៉ោងក្នុង១សប្ដាហ៍ | | | | | |
| ៣ | បានរៀបចំកិច្ចតែងការបង្រៀនអំណានជាប្រចាំតាមចំនួនម៉ោងកំណត់ | | | | | |
| ៤ | កិច្ចតែងការបង្រៀនអំណានត្រូវបានត្រួតពិនិត្យជាប្រចាំពីគណៈគ្រប់គ្រងសាលារៀន | | | | | |
| ៥ | បានអនុវត្តការបង្រៀនអំណានតាមចំនួនម៉ោងកំណត់ក្នុងបំណែងចែកកម្មវិធីសិក្សា | | | | | |
| ៦ | បានរៀនវគ្គបំប៉ន ស្រាវជ្រាវបន្ថែមលើការបង្រៀនអំណានភាសាខ្មែរ | | | | | |
| ៧ | បានប្រើប្រាស់សៀវភៅសិក្សាគោលភាសាខ្មែរតាមកម្រិតថ្នាក់ | | | | | |
| ៨ | ប្រជុំក្រុមបច្ចេកទេស ពិនិត្យតាមដាន និងកែលម្អការអនុវត្តបង្រៀនអំណាន ភាសាខ្មែរ ទៀងទាត់ | | | | | |
| ៩ | សាលាបានបែងចែកកាលវិភាគឱ្យមានម៉ោងបណ្ណាល័យដើម្បីលើកកម្ពស់គុណភាព បង្រៀនអំណាន | | | | | |
| ១០ | ជារួម ចំនួនម៉ោងនេះគ្រប់គ្រាន់សម្រាប់ការបង្រៀនអំណានស្របតាមកម្មវិធីសិក្សា | | | | | |

## ២.២. វិធីសាស្រ្ត និងសកម្មភាពបង្រៀន និងរៀនអំណាន

### ក. វិធីសាស្រ្តបង្រៀន

| ល.រ | វិធីសាស្រ្តបង្រៀនអំណានភាសាខ្មែររបស់លោកគ្រូអ្នកគ្រូផ្ដោតលើ៖ | កម្រិតនៃការប្រតិបត្តិ | | | | |
|---|---|---|---|---|---|---|
| | | រៀងរាល់ពេល | ញឹកញាប់ | ម្ដងម្កាល | កម្រ | មិនដែលសោះ |
| ១ | បង្ហាញវត្ថុបំណងមេរៀនអំណានច្បាស់លាស់ | | | | | |
| ២ | ផ្ដល់ការការណែនាំដល់សិស្ស លើចំណេះដឹងស្ដីពីអំណាន | | | | | |
| ៣ | អានក្នុងចិត្ត ឬអានស្ងាត់ | | | | | |
| ៤ | អានខ្សឹប | | | | | |
| ៥ | សិស្សអានឮៗម្នាក់ឯង | | | | | |
| ៦ | សិស្សអានឮអានបណ្ដាក់គ្នា | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៧ | អានស្ទាប(សម្រាប់សិស្សពិការ) | | | | | |
| ៨ | សិស្សអានម្នាក់ឯង | | | | | |
| ៩ | សិស្សអានជាដៃគូ | | | | | |
| ១០ | សិស្សអានជាក្រុមតូច | | | | | |
| ១១ | សិស្សអានរួមគ្នាទាំងអស់ | | | | | |
| ១២ | ផ្លាស់ប្តូរវិធីសាស្ត្រ ដោយប្រើល្បែងសិក្សាពីអំណាន | | | | | |
| ១៣ | គ្រូបានពិនិត្យសិស្សក្នុងពេលអានជាក្រុម ឬជាដៃគូ ឬជាបុគ្គល | | | | | |
| ១៤ | គ្រូបានស្តាប់សិស្សអាន ព្រមទាំងបានជួយអានពាក្យពិបាក | | | | | |
| ១៥ | គ្រូបានអានជាគំរូក្នុងការបញ្ចេញសំឡេង តាមអក្ខរក្រម | | | | | |

**ខ. ស្ថានភាពអនុវត្តជាក់ស្តែងក្នុងដំណើរការ និងសកម្មភាពបង្រៀនអំណានភាសាខ្មែររបស់លោកគ្រូ អ្នកគ្រូ ៖**

| | | | | | | |
|---|---|---|---|---|---|---|
| ១ | ប្រើប្រាស់កិច្ចតែងការបង្រៀនអំណានថ្មីជានិច្ច | | | | | |
| ២ | អនុវត្តការបង្រៀនអំណានតាមដំណាក់កាលជាប្រចាំ(មុនពេល ក្នុងពេល និង ក្រោយពេលអំណាន) | | | | | |
| ៣ | បង្ហាញការសិក្សាចំណងជើង សិក្សារូបភាព ទំនាក់ទំនងចំណងជើងនិងរូបភាព ពេលត្រៀមអំណាន | | | | | |
| ៤ | សិក្សាពន្យល់ន័យពាក្យពិបាកទាំងអស់នៅក្នុងអំណាន | | | | | |
| ៥ | ផ្តល់ឱកាសឱ្យសិស្សពូកែ និងសិស្សខ្សោយបានអានអត្ថបទ និងឆ្លើយសំណួរ ស្មើៗគ្នាពេលអំណាន | | | | | |
| ៦ | ផ្តល់ឱកាសឱ្យសិស្សពិភាក្សាក្រុម(គូររូបភាព សង្ខេបអត្ថបទ តែងកំណាព្យ រកពាក្យស្លោក សម្តែងតួ...)នៅក្រោយអំណាន | | | | | |
| ៧ | ប្រឡងអានអត្ថបទម៉ោងអំណានក្នុងសាលាដើម្បីដាក់ពិន្ទុ | | | | | |
| ៨ | ជួយសិស្សខ្សោយអំណាន ឬពិបាកក្នុងការអានពេលរៀនអំណាន | | | | | |
| ៩ | ផ្តល់ការការណែនាំដល់សិស្ស លើចំណេះដឹងស្តីពីអំណាន | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ១០ | ណែនាំសិស្សឱ្យអានអត្ថបទនៅផ្ទះត្រៀមមុនចូលមេរៀនអំណាន | | | | | |
| ១១ | បំផុសសកម្មភាពឱ្យសិស្សអានសៀវភៅក្នុង និងក្រៅបណ្ណាល័យ | | | | | |
| ១២ | ដាក់កិច្ចការផ្ទះផ្នែកអំណានឱ្យសិស្សធ្វើក្នុងសប្ដាហ៍នីមួយៗ | | | | | |
| ១៣ | រៀបចំកម្មវិធីបំប៉នបន្ថែមចំពោះសិស្សខ្សោយអំណាន | | | | | |
| ១៤ | រៀបចំកម្មវិធីការប្រឡង ប្រកួតប្រជែងផ្នែកអំណានតាមកម្រិត | | | | | |
| ១៥ | ព្យាយាមលើកទឹកចិត្តសិស្សនៅពេលបង្រៀនអំណាន | | | | | |
| ១៦ | សិស្សមានបម្រុងប្រយ័ត្ន ក្នុងពេលអានមេរៀន | | | | | |
| ១៧ | បានណែនាំសិស្សចូលអានសៀវភៅក្នុងបណ្ណាល័យជាប្រចាំ | | | | | |

**គ. សម្ភារៈបង្រៀននិងការប្រើប្រាស់ សម្ភារៈឧបទេសក្នុងការបង្រៀនអំណាន៖(សូមគូសសញ្ញា (✓)តាមកម្រិត)**

| ល.រ | ប្រភេទសម្ភារៈ | កម្រិតនៃការប្រើប្រាស់ | | | | |
|---|---|---|---|---|---|---|
| | | រៀងរាល់ពេល | ញឹកញាប់ |ម្ដងម្កាល | កម្រ | មិនដែលសោះ |
| ១ | សៀវភៅសិក្សាគោល(ភាសាខ្មែរ) | | | | | |
| ២ | សៀវភៅគ្រូ | | | | | |
| ៣ | បណ្ណរូបភាព/ ផ្ទាំងក្រដាសរ៉ាម | | | | | |
| ៤ | បណ្ណសំណួរ | | | | | |
| ៥ | សៀវភៅរឿងអប់រំខ្លីៗ | | | | | |
| ៦ | វចនានុក្រមភាសាខ្មែរ | | | | | |
| ៧ | ឯកសារជាភាសាខ្មែរសម្រាប់សិស្សអានក្នុងបណ្ណាល័យ | | | | | |

## ២.៣. ការវាយតម្លៃលទ្ធផល

| ល.រ | ការវាយតម្លៃសមត្ថភាពអំណានរបស់សិស្ស ផ្ដោតលើ៖ | កម្រិតនៃការប្រតិបត្តិ | | | | |
|---|---|---|---|---|---|---|
| | | រៀងរាល់ពេល | ញឹកញាប់ | ម្ដងម្កាល | កម្រ | មិនដែលសោះ |
| ក | **ទម្រង់នៃការវាយតម្លៃ** | | | | | |
| ១ | សំណួរផ្ទាល់មាត់ក្នុងម៉ោងបង្រៀនអំណានជាប្រចាំ | | | | | |
| ២ | សំណួរខ្លីៗពេលម៉ោងបង្រៀនអំណាន | | | | | |
| ៣ | កិច្ចការផ្ទះមេរៀនសិក្សាអត្ថបទអំណាន | | | | | |
| ៤ | ប្រឡងប្រចាំខែ | | | | | |
| ៥ | ប្រឡងឆមាស | | | | | |
| ខ. | **របៀបអាន** | | | | | |
| ១ | សិស្សអានលឿន ស្ទាត់ | | | | | |
| ២ | សិស្សអានយល់ន័យពាក្យ | | | | | |
| ៣ | សិស្សអានប្រកបពាក្យពួៗ | | | | | |
| ៤ | សិស្សអានយល់ន័យអត្ថបទ ដើម្បីឆ្លើយសំណួរបានត្រឹមត្រូវ | | | | | |
| ៥ | សិស្សអានលើកដាក់សំឡេង និងគោរពសញ្ញា ឃ្លា ប្រយោគត្រឹមត្រូវ | | | | | |

**ផ្នែកទី៣៖ បញ្ហាប្រឈម**

តើលោកគ្រូ អ្នកគ្រូបង្រៀនអំណានភាសាខ្មែរនៅកម្រិតមធ្យមសិក្សាបឋមភូមិ មានបញ្ហាប្រឈមអ្វីខ្លះ? សូមអានចំណុចនីមួយៗឱ្យបានច្បាស់លាស់ បន្ទាប់មកគូសសញ្ញា (✓) ទៅតាមកម្រិតនៃការពេញចិត្តរបស់លោកគ្រូ អ្នកគ្រូ ៖

១. មិនយល់ស្របទាល់តែសោះ

២. មិនយល់ស្រប

៣. មិនមានយោបល់

៤. យល់ស្រប

៥. យល់ស្របខ្លាំង

| ល.រ | ការបរិយាយបញ្ហាប្រឈម | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| | | ៥ | ៤ | ៣ | ២ | ១ |
| ១ | ការរៀបចំកម្មវិធីបំប៉នបន្ថែមចំពោះសិស្សខ្សោយអំណាន | | | | | |
| ២ | ការរៀបចំកិច្ចតែងការបង្រៀនអំណានជាប្រចាំតាមចំនួនម៉ោងកំណត់ | | | | | |
| ៣ | ការរៀបចំបំណែងចែកកម្មវិធីសិក្សា មុខវិជ្ជាភាសាខ្មែរឱ្យបានច្បាស់លាស់តាមចំនួនម៉ោងកំណត់របស់ក្រសួងអប់រំ | | | | | |
| ៤ | ការស្រាវជ្រាវបន្ថែមលើការបង្រៀនអំណានភាសាខ្មែរ | | | | | |
| ៥ | ការអនុវត្តការបង្រៀនអំណានតាមចំនួនម៉ោងកំណត់ក្នុងបំណែងចែកកម្មវិធីសិក្សា | | | | | |
| ៦ | ខ្លឹមសារអត្ថបទអំណានក្នុងសៀវភៅសិក្សាគោល(ភាសាខ្មែរ)មិនសូវសមស្របតាមកម្រិតយល់ដឹងរបស់សិស្ស និងរយៈពេលកំណត់ | | | | | |
| ៧ | ចំនួនសិស្សនៅក្នុងថ្នាក់មិនតាមស្តង់ដាការបង្រៀនអំណានមានប្រសិទ្ធភាព | | | | | |
| ៨ | ប្រើវិធីសាស្ត្រនិងសម្ភារៈបង្រៀនអំណានឱ្យសម្បូរបែប និងសមស្រប | | | | | |
| ៩ | ផលិតសម្ភារៈបង្រៀន និងសម្ភារៈឧបទេសគ្រប់គ្រាន់បម្រើឱ្យការបង្រៀនអំណានបានត្រឹមត្រូវ | | | | | |
| ១០ | សិស្សខ្លះខ្សោយអំណានប្រកបពាក្យមិនចេញ មិនចេះស្រៈនិងព្យញ្ជនៈបានគ្រប់គ្នា | | | | | |

**បញ្ហាប្រឈមផ្សេងទៀត**

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

**សំណូមពរ ឬ មតិយោបល់បន្ថែម**

ក. ការអនុវត្តកម្មវិធីសិក្សា

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

ខ. វិធីសាស្ត្របង្រៀន

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

គ. ការរៀបចំ និងប្រើប្រាស់សម្ភារៈឧបទេសសម្រាប់ការបង្រៀនអំណាន

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

**សូមអរគុណសម្រាប់ការចូលរួមរបស់លោកគ្រូ អ្នកគ្រូ !**

# ឧបសម្ព័ន្ធ«គ»

## កម្រងសំណួរសម្រាប់សិស្ស

ខ្ញុំបាទឈ្មោះ **នូ សុខលៀប** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ។ ខ្ញុំបាទបានរៀបចំការសិក្សាស្រាវជ្រាវមួយទាក់ទងទៅនឹងប្រធានបទ « **ស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ** »ដើម្បីបញ្ចប់ការសិក្សា។

គោលបំណងនៃការប្រមូលទិន្នន័យ គឺដើម្បីឈ្វេងយល់ពីដំណើរការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាន ដែលផ្តោតលើបញ្ហាប្រឈមទាក់ទងនឹងបំណិននៃការអានរបស់សិស្សនៅមធ្យមសិក្សាបឋមភូមិ និងយុទ្ធសាស្ត្រក្នុងការដោះស្រាយបញ្ហាប្រឈមដើម្បីជំរុញការអនុវត្តការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណានឱ្យមានប្រសិទ្ធភាព។

ទិន្នន័យដែលប្រមូលបានមក គឺប្រើសម្រាប់តែការសិក្សាស្រាវជ្រាវនេះប៉ុណ្ណោះ។ ក្នុងន័យនេះ សូមប្អូនៗសិស្សានុសិស្សមេត្តាជួយផ្តល់ព័ត៌មានពិតជាក់ស្តែង។

ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមរបស់ប្អូនៗសិស្សានុសិស្ស។

### ផ្នែកទី១៖ ព័ត៌មានទូទៅ

សូមប្អូនបំពេញ ដោយគូសសញ្ញា ✓ ក្នុងប្រអប់ □ និងបំពេញចន្លោះតាមភាពជាក់ស្តែងរបស់ប្អូន ដែលជ្រើសរើស ។

១. ឈ្មោះសាលា៖ អនុវិទ្យាល័យ..............................

២. កម្រិតថ្នាក់ ៖ □ ថ្នាក់ទី៧ □ ថ្នាក់ទី៨ □ ថ្នាក់ទី៩

៣. ភេទ៖ □ ប្រុស □ ស្រី

៤. អាយុ៖ ..................................

## ផ្នែកទី២៖ ដំណើរការនៃការបង្រៀន និងរៀនអំណាន

**ការណែនាំ៖** នៅក្នុងការរៀនមុខវិជ្ជាភាសាខ្មែរកន្លងមក តើលោកគ្រូ អ្នកគ្រូរបស់ប្អូនបង្រៀនអំណាន មានដំណើរការយ៉ាងដូចម្តេច? សូមអានចំណុចនីមួយៗឱ្យបានច្បាស់លាស់ បន្ទាប់មកគូសសញ្ញា (✓) ទៅតាមកម្រិតនៃការពេញចិត្តរបស់ប្អូន ៖

**កម្រិតចង្អុលបង្ហាញ៖**

១. មិនយល់ស្របទាល់តែសោះ

២. មិនយល់ស្រប

៣. មិនមានយោបល់

៤. យល់ស្រប

៥. យល់ស្របខ្លាំង

### ២.១. ព័ត៌មានអំពីការសិក្សា

| ល.រ | ការបរិយាយ | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| | | ៥ | ៤ | ៣ | ២ | ១ |
| ១ | ប្អូនរៀនមុខវិជ្ជាភាសាខ្មែរ ៦ម៉ោងក្នុង១សប្តាហ៍ | | | | | |
| ២ | ប្អូនរៀនភាសាខ្មែរផ្នែកអំណានយ៉ាងតិច២ម៉ោងក្នុង១សប្តាហ៍ | | | | | |
| ៣ | ប្អូនរៀនអំណានបានទៀងទាត់តាមកាលវិភាគជាប្រចាំ | | | | | |
| ៤ | កាលវិភាគសិក្សារបស់ប្អូន មានម៉ោងបណ្ណាល័យសម្រាប់ប្អូនចូលពង្រឹងអំណានបន្ថែមទៀត | | | | | |
| ៥ | គ្រូមានទំនួលខុសត្រូវក្នុងការគោរពពេលវេលា | | | | | |
| ៦ | ចំនួនម៉ោងបង្រៀនអំណានមិនសូវគ្រប់គ្រាន់សម្រាប់ប្អូនៗ | | | | | |

## ២.២. វិធីសាស្រ្ត និងសកម្មភាពបង្រៀន និងរៀនអំណាន

### ក. តើប្អូនរៀនអំណានភាសាខ្មែរដោយរបៀបណា?

| ល.រ | សកម្មភាពរៀន | កម្រិតនៃការប្រតិបត្តិ | | | | |
|---|---|---|---|---|---|---|
| | | រៀង រាល់ ពេល | ញឹក ញាប់ | ម្ដង ម្កាល | កម្រ | មិន ដែល សោះ |
| ១ | ស្ដាប់ការបង្ហាញវត្ថុបំណងមេរៀនអំណានច្បាស់លាស់ | | | | | |
| ២ | ស្ដាប់ការណែនាំរបស់គ្រូស្ដីពីរបៀបអាន មុននឹងអានអត្ថបទ | | | | | |
| ៣ | អានក្នុងចិត្ត ឬអានស្ងាត់ ទាំងអស់គ្នា | | | | | |
| ៤ | អានខ្សឹបដោយយកដៃចង្អុលតាមបន្ទាត់នៃប្រយោគក្នុងល្បះនីមួយៗ | | | | | |
| ៥ | អានឮៗម្នាក់ឯង | | | | | |
| ៦ | អានឮបណ្ដាក់គ្នា | | | | | |
| ៧ | អានស្ទាប(សម្រាប់សិស្សពិការ) | | | | | |
| ៨ | អានជាដៃគូ | | | | | |
| ៩ | អានជាក្រុមតូច | | | | | |
| ១០ | អានរួមគ្នាទាំងអស់ | | | | | |
| ១១ | លេងល្បែងសិក្សា(ដើរតួ ប្រកួតអានពាក្យពិបាក  ទាយពាក្យ) | | | | | |
| ១២ | អានតាមគ្រូ ជាក្រុម ឬជាដៃគូ ឬជាបុគ្គល | | | | | |
| ១៣ | ស្ដាប់គ្រូអានពាក្យពិបាក រួចថាតាម | | | | | |

## ខ.តើការបង្រៀនអំណានភាសាខ្មែរ មានសកម្មភាពដូចម្តេចខ្លះ?

| ល.រ | សកម្មភាពបង្រៀន | កម្រិតនៃការប្រតិបត្តិ | | | | |
|---|---|---|---|---|---|---|
| | | រៀងរាល់ពេល | ញឹកញាប់ | ម្តងម្កាល | កម្រ | មិនដែលសោះ |
| ១ | គ្រូបង្ហាញវត្ថុបំណងមេរៀននៃអត្ថបទ អំណានជាប្រចាំ | | | | | |
| ២ | គ្រូបង្ហាញ ចំណងជើង សិក្សារូបភាព ទំនាក់ទំនងចំណងជើងនិងរូបភាពពេលត្រៀមអំណាន | | | | | |
| ៣ | គ្រូពន្យល់ន័យពាក្យពិបាកទាំងអស់នៅក្នុងអំណាន | | | | | |
| ៤ | គ្រូផ្តល់ឱកាសឱ្យសិស្សពូកែ និងសិស្សខ្សោយបានអានអត្ថបទ និងឆ្លើយសំណួរស្មើៗគ្នាពេលអំណាន | | | | | |
| ៥ | គ្រូហៅសិស្សឡើងអានអត្ថបទផ្លាស់ប្តូរគ្នា | | | | | |
| ៦ | គ្រូឱ្យសិស្សពិភាក្សាក្រុម( គូររូបភាព សង្ខេបអត្ថបទ តែងកំណាព្យ រកពាក្យស្លោក សម្តែងតួ...)នៅក្រោយអំណាន | | | | | |
| ៧ | គ្រូឱ្យសិស្សពូកែជួយសិស្សខ្សោយក្នុងការអានពិបាក ពេលរៀនអំណាន | | | | | |
| ៨ | គ្រូណែនាំសិស្សឱ្យអានអត្ថបទអំណាននៅផ្ទះត្រៀមមុនចូលមេរៀនអំណាន | | | | | |
| ៩ | គ្រូតែងតែបំផុសសកម្មភាពឱ្យសិស្សអានសៀវភៅនៅបណ្ណាល័យ | | | | | |
| ១០ | គ្រូជួយបំប៉នបន្ថែមចំពោះសិស្សខ្សោយអំណាននៅពេលចេញលេង | | | | | |
| ១១ | គ្រូដាក់កិច្ចការផ្ទះផ្នែកអំណានឱ្យសិស្សធ្វើក្នុងសប្តាហ៍នីមួយៗ | | | | | |
| ១២ | គ្រូណែនាំសិស្សឱ្យចូលរួមការប្រឡង ប្រកួតប្រជែងផ្នែកអំណានតាមកម្រិត | | | | | |
| ១៣ | គ្រូលើកទឹកចិត្តសិស្សពេលបង្រៀនអំណាន | | | | | |

គ. សម្ភារៈដែលគ្រូបង្រៀនគ្រូប្អូនប្រើប្រាស់ ក្នុងការបង្រៀន និងរៀនអំណាន៖(សូមគូសសញ្ញា (✓)តាមកម្រិត)

| ល.រ | ប្រភេទសម្ភារៈ | កម្រិតនៃការប្រើប្រាស់ | | | | |
|---|---|---|---|---|---|---|
| | | រៀងរាល់ពេល | ញឹកញាប់ |ម្តងម្កាល | កម្រ | មិនដែលសោះ |
| ១ | សៀវភៅសិក្សាគោល(ភាសាខ្មែរ) | | | | | |
| ២ | បណ្ណរូបភាព/ ផ្ទាំងក្រដាសរ៉ាម | | | | | |
| ៣ | បណ្ណសំណួរ | | | | | |
| ៤ | សៀវភៅរឿងអប់រំខ្លីៗ | | | | | |
| ៥ | វចនានុក្រមភាសាខ្មែរ | | | | | |
| ៦ | ឯកសារជាភាសាខ្មែរសម្រាប់សិស្សអានក្នុងបណ្ណាល័យ | | | | | |

## ២.៣. ការវាយតម្លៃលទ្ធផល

| ល.រ | របៀបនៃការវាយតម្លៃសមត្ថភាពអំណានរបស់គ្រូ ផ្តោតលើ៖ | ឯកភាពទាំងស្រុង | ឯកភាព | មិនច្បាស់លាស់ | មិនឯកភាព | មិនឯកភាពទាំងស្រុង |
|---|---|---|---|---|---|---|
| ១ | ឱ្យសិស្សប្រឡងអានអត្ថបទដាក់ពិន្ទុជាប្រចាំពេលម៉ោងបង្រៀនអំណាន | | | | | |
| ២ | ដាក់ពិន្ទុលើការអានលឿន និងស្ទាត់ | | | | | |
| ៣ | ដាក់ពិន្ទុលើការអានយល់ន័យពាក្យ | | | | | |
| ៤ | ដាក់ពិន្ទុលើការអានប្រកបពាក្យឮៗ | | | | | |
| ៥ | ដាក់ពិន្ទុលើការអានយល់ន័យអត្ថបទ | | | | | |
| ៦ | ដាក់ពិន្ទុលើការឆ្លើយសំណួរក្នុងអត្ថបទបានត្រឹមត្រូវ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៧ | ដាក់ពិន្ទុលើការអានលើកដាក់សំឡេង និងគោរពសញ្ញា ឃ្លា ប្រយោគត្រឹមត្រូវ | | | | | |
| ៨ | ការដាក់ពិន្ទុមានតម្លាភាព និងយុត្តិធម៌ | | | | | |

## ផ្នែកទី៣៖ បញ្ហាប្រឈម

តើប្អូនៗមានការលំបាកអ្វីខ្លះក្នុងការរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាន ?សូមអានចំណុចនីមួយៗ ឱ្យបានច្បាស់លាស់ បន្ទាប់មកគូសសញ្ញា (✓) ទៅតាមកម្រិតនៃការពេញចិត្តរបស់ប្អូន ៖

១. មិនយល់ស្របទាល់តែសោះ

២. មិនយល់ស្រប

៣. មិនមានយោបល់

៤. យល់ស្រប

៥. យល់ស្របខ្លាំង

| ល.រ | ការបរិយាយបញ្ហាប្រឈម | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| | | ៥ | ៤ | ៣ | ២ | ១ |
| ១ | ចំនួនម៉ោងបង្រៀនអំណានមិនសមស្របនៅក្នុងសៀវភៅសិក្សាគោល | | | | | |
| ២ | ចំនួនម៉ោងសិក្សាមុខវិជ្ជាភាសាខ្មែរមិនគ្រប់គ្រាន់សម្រាប់ឱ្យសិស្សចេះ | | | | | |
| ៣ | បណ្ណាល័យមិនមានសៀវភៅគ្រប់គ្រាន់សម្រាប់សិស្សអានគ្រប់កម្រិត | | | | | |
| ៤ | សកម្មភាពបង្រៀនអំណានរបស់គ្រូពិបាកធ្វើឱ្យប្អូនឆាប់ចេះអាន | | | | | |
| ៥ | សម្ភារៈផ្សេងៗសម្រាប់បង្រៀនអំណានមិនគ្រប់គ្រាន់ | | | | | |
| ៦ | សៀវភៅសិក្សាគោលភាសាខ្មែរសម្រាប់បង្រៀនអំណានមិនគ្រប់គ្រាន់ | | | | | |
| ៧ | អត្ថបទអំណានក្នុងសៀវភៅសិក្សាគោលពិបាកក្នុងការយល់ | | | | | |
| ៨ | អត្ថបទអំណានក្នុងសៀវភៅសិក្សាគោលមិនសមស្របនឹងរយៈពេលកំណត់(ពេលខ្លី) | | | | | |

បញ្ហាប្រឈមផ្សេងទៀត

..............................................................................................................................

..............................................................................................................................

..............................................................................................................................

.......................................................................................................................

**សំណូមពរ ឬ មតិយោបល់បន្ថែម**

១. តើប្អូនមានយោបល់ ឬសំណូមពរអ្វីខ្លះទាក់ទងនឹង៖

| ក. ការបង្រៀន | ខ.សម្ភារៈសម្រាប់បង្រៀន និងរៀន | គ. ការវាយតម្លៃ |
|---|---|---|
| .............................................. | .............................................. | .......................................... |
| .............................................. | .............................................. | .......................................... |
| .............................................. | .............................................. | .......................................... |
| .............................................. | .............................................. | .......................................... |
| ............................................. | ............................................. | .......................................... |

..............................................................................................................................

..............................................................................................................................

..............................................................................................................................

សូមអរគុណសម្រាប់ការចូលរួមរបស់ប្អូនៗ !

# ឧបសម្ព័ន្ធ«ឃ»

## លិខិតផ្សេងៗ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
វិទ្យាស្ថានជាតិអប់រំ
លរ......✓........វជអ

**បណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧**
**កាលបរិច្ឆេទទទួលនិក្ខេបបទស្រាវជ្រាវ**

| ជំពូក | ចំណងជើង | កាលបរិច្ឆេទ | ថ្ងៃកំណត់ |
|---|---|---|---|
| ១ | សេចក្តីផ្តើម | ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |
| ២ | រំលឹកទ្រឹស្តី | ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |
| ៣ | វិធិសាស្ត្រស្រាវជ្រាវ | ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |
| ៤ | វិភាគស៊ីជម្រៅលើលទ្ធផលរបកគំហើញ និងការ ពិភាក្សា | ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |
| ៥ | សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ | ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |

កំណត់សម្គាល់:

- ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២០ ទទួលនិក្ខេបបទ នៅគណៈកម្មការប្រតិបត្តិនៃការបណ្តុះបណ្តាល ថ្នាក់ក្រោយឧត្តម នៅវិទ្យាស្ថានជាតិអប់រំ។
- ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ **បទបង្ហាញសាកល្បង**ការពារការសរសេរនិក្ខេបបទ។
- ថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ពិធីការពារការនិក្ខេបបទរៀបចំដោយ គណៈកម្មការប្រតិបត្តិនៃការបណ្តុះបណ្តាលថ្នាក់ក្រោយឧត្តមនៅវិទ្យាស្ថានជាតិអប់រំ។

រាល់ចម្ងល់ពីការសរសេរនិក្ខេបបទស្រាវជ្រាវសូមទាក់ទងគណៈកម្មការប្រតិបត្តិនៃការបណ្តុះបណ្តាលថ្នាក់ក្រោយឧត្តមសម្រាប់កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ផ្នែក គ្រប់គ្រងអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា។ លោក បណ្ឌិត នួរ វីរ៉ា នាយករង វិទ្យាស្ថានជាតិអប់រំ និងលោក ចាប រតនា អនុប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការនៃវិទ្យាស្ថានជាតិអប់រំ ។

ថ្ងៃសុក្រ ០៤ រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមិនា ឆ្នាំ២០២០
**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ :......[illegible]......វជអ.[illegible]

# លិខិតអញ្ជើញ

**សូមអញ្ជើញ** ៖ **ទូ សុខលៀម**

**ដើម្បីចូលរួម** ៖ ធ្វើបទបង្ហាញស្តីពីវឌ្ឍនភាពនៃការសរសេរនិក្ខេបបទស្រាវជ្រាវ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧

**កាលបរិច្ឆេទ** ៖ ថ្ងៃ ព្រហស្បតិ៍ ១០កើត ខែ ស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
ថ្ងៃទី ៣០ ខែ កក្កដ ឆ្នាំ២០២០

**ពេលវេលា** ៖ ម៉ោង ៩ ព្រឹក តាម ZOOM

**ទីកន្លែង** ៖ វិទ្យាស្ថានជាតិអប់រំ

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២០
នាយកវិទ្យាស្ថានជាតិអប់រំ

**បណ្ឌិត.សេង សនក**

*ភ្ជាប់មកជាមួយនូវ៖*

- ✓ *ឯកសារបទបង្ហាញចំនួន០៣ច្បាប់*
- ✓ *របាយការណ៍សង្ខេបស្តីពីវឌ្ឍនភាពនៃការសរសេរនិក្ខេបបទដែលមានចុះហត្ថលេខាពីគ្រូដឹកនាំ និងគ្រូដឹកនាំរង០១ច្បាប់*
- ✓ *លទ្ធផលនៃការសរសេរនិក្ខេបបទ០១ច្បាប់*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**វិទ្យាស្ថានជាតិអប់រំ**
លេខ: ១០០ នជអ. ៥ក

គោរពជូន
**លោកប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្តតាកែវ**

**កម្មវត្ថុៈ** សំណើសុំអនុញ្ញាតឱ្យលោក **នូ សុខលៀប** ចុះកម្មសិក្សាស្រាវជ្រាវ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៅអនុវិទ្យាល័យគោលដៅចំនួន៣ក្នុងស្រុកសំរោង ខេត្តតាកែវ។
**យោងៈ** ផែនការបណ្ដុះបណ្ដាលនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានមេត្តាជ្រាបថា លោក **នូ សុខលៀប** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំពុងទទួលការបណ្ដុះបណ្ដាលនៅវិទ្យាស្ថានជាតិអប់រំ មានគម្រោងចុះស្រាវជ្រាវលើប្រធានបទស្ដីពី«**ស្ថានភាពនៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណាននៅសាលាមធ្យមសិក្សាបឋមភូមិចំនួនបីក្នុងស្រុកសំរោង ខេត្តតាកែវ**» ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សា។ លោក **នូ សុខលៀប** នឹងសម្ភាសន៍តាមប្រព័ន្ធ ONLINE ពីគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សថ្នាក់ទី៧ ទី៨ និងទី៩ ដែលកំពុងសិក្សានៅសាលា អនុវិទ្យាល័យគោលដៅចំនួន៣ ក្នុងស្រុកសំរោង ខេត្តតាកែវ ដែលប្រព្រឹត្តទៅចាប់**ពីថ្ងៃទី១៦ ខែកក្កដា ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០**។

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាជួយសម្រួលដោយក្ដីអនុគ្រោះ។
សូមលោកប្រធានទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ

ថ្ងៃពុធ ១០រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០
**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ :..............វជអ.

# លិខិតអញ្ជើញ

សូមគោរពអញ្ជើញ ៖ **និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧**

**ដើម្បីចូលរួម** ៖ ការពារនិក្ខេបបទ

**កាលបរិច្ឆេទ** ៖ ពីថ្ងៃសៅរ៍-អាទិត្យ ៨-៩កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ០៧:៣០នាទីព្រឹកដល់១៧:៣០រសៀល (មានភ្ជាប់ជូនកម្មវិធី)។

**ទីកន្លែង** ៖ វិទ្យាស្ថានជាតិអប់រំនៅអគារ H បន្ទប់ជាន់ទី១។

ថ្ងៃពុធ ៥កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុខណ្ណា

*ព័ត៌មានបន្ថែម ៖*

- *សម្លៀកបំពាក់សម្រាប់និស្សិត៖ បុរសអាវធំខ្មៅឬខៀវចាស់ និងខោខ្មៅ និងនិស្សិតនារីអាវប៉ាកស សំពត់ខ្មៅ ឬខៀវ។*
- *និស្សិតមានសិទ្ធិឡើងការពារនិក្ខេបបទបញ្ចប់ការសិក្សាលុះណាមានការឯកភាពពីលោកគ្រូដឹកនាំ និងដឹកនាំរង។*

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥-២៣) ២១៥/៥៨៨ គេហទំព័រ www.nie.edu.kh